លេខ៧
ឆ្នាំ២០១៩

# ព្រឹត្តិបត្រ

## កម្មវិធីកែទម្រង់
## ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ



# បុព្វកថា

រាជរដ្ឋាភិបាលកម្ពុជា តែងតែយកចិត្តទុកដាក់ និងកំណត់ការងារកែទម្រង់ គឺជាឧបករណ៍គោលនយោបាយគន្លឹះសម្រាប់ដោះស្រាយបញ្ហាប្រឈមនានា និងបង្កើតកាលានុវត្តភាពថ្មីៗ ឆ្ពោះទៅរកការអភិវឌ្ឍ និងវិបុលភាព។ ការងារកែទម្រង់ដ៏មានសារៈសំខាន់បី ដែលកំពុងបន្តតួនាទីជាសសរស្តម្ភសម្រាប់ធានាជោគជ័យនៃការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៦នេះគឺ ការកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ការកែទម្រង់រដ្ឋបាលសាធារណៈ និងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ចាប់តាំងពីការចាប់ផ្តើមដាក់ឱ្យអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅឆ្នាំ២០០៤ រហូតមកដល់ពេលនេះ រាជរដ្ឋាភិបាលកម្ពុជា សម្រេចបាននូវវឌ្ឍនភាពជាសារវ័ន្តជាច្រើនដែលបានជំរុញនាវាកម្ពុជាឆ្ពោះទៅឆាកអន្តរជាតិប្រកបដោយមោទនភាព។ សម្រាប់ឆ្នាំនេះ គឺជាពេលវេលាថ្មីមួយទៀតដែលកម្មវិធីកែទម្រង់ ត្រូវបានអនុវត្តនិងវាយតម្លៃលើសមិទ្ធកម្មការងារតាមរយៈកិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំដែលមានការចូលរួមពីគ្រប់ក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍដែលជាតួអង្គដ៏សំខាន់ក្នុងការជំរុញកិច្ចដំណើរការនៃកម្មវិធីកែទម្រង់ប្រកដបដោយប្រសិទ្ធភាពខ្ពស់ ព្រមទាំងការត្រៀមខ្លួនបោះជំហានទៅដំណាក់កាលថ្មីមួយទៀត ក្នុងឆ្នាំបន្តបន្ទាប់។

ជាក់ស្តែង រហូតមកដល់ដើមឆ្នាំ២០១៩នេះ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទទួលបានលទ្ធផលល្អប្រសើរ ទាំងក្នុងក្របខ័ណ្ឌសកម្មភាពកែទម្រង់របស់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសកម្មភាពកែទម្រង់របស់ក្រសួង-ស្ថាប័ន។ ការអនុវត្តដោយជោគជ័យនៃយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ដែលធ្វើឱ្យចំណូលកើនឡើងជាលំដាប់, ការគ្រប់គ្រងនិងការវិភាជថវិកាកាន់តែប្រសើរឡើងនិងចំគោលដៅនៃវិស័យអាទិភាព, ការបង្កើតបានជាមូលដ្ឋានសម្រាប់ការកត់ត្រាគណនេយ្យគ្រប់ជ្រុងជ្រោយ និងអាចផលិតរបាយការណ៍បានទាន់ពេលវេលាតាមរយៈការដាក់ឱ្យអនុវត្តជា បណ្តើរៗនូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS), ការដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញនៅគ្រប់ក្រសួង-ស្ថាប័ន និងតាមបណ្តារដ្ឋបាលរាជធានី-ខេត្តមួយចំនួន សុទ្ធសឹងជាសមិទ្ធកម្មជាក់លាក់ និងជាសមាសធាតុគន្លឹះសម្រាប់វាស់វែងនៅក្នុងរយៈពេលចុងក្រោយនេះ ។

ដោយឡែកនៅត្រីមាសទី១នេះ ក្របខ័ណ្ឌយុទ្ធសាស្ត្រសំខាន់ៗមួយចំនួនត្រូវបានដាក់អនុម័តឱ្យប្រើប្រាស់ ដែលក្នុងនោះមាន «យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣», «យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ២០១៩-២០២៥», «យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ ២០១៩-២០២៥» និង «ផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥» ។ ម្យ៉ាងវិញទៀត, ការដាក់ឱ្យអនុវត្តសាកល្បងនូវប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ការបង្កើនការផ្សព្វផ្សាយឯកសារថវិកាជាសាធារណៈ ការពង្រឹងតួនាទីស្ថាប័នសវនកម្ម និងអធិការកិច្ច, និងការពង្រឹងសមត្ថភាពមន្ត្រីក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាប្រចាំ បានជួយឱ្យការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កាន់តែមានប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព និងតម្លាភាព។ លើសពីនេះទៅទៀត, ការចូលរួមរបស់ក្រសួង-ស្ថាប័ន ក្នុងសកម្មភាព កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធាណៈ មានការរីកចម្រើនជាលំដាប់ ជាពិសេសយន្តការនៃការគ្រប់គ្រងចំណូល, ការរៀបចំថវិកាតាមប្រព័ន្ធថវិកាកម្មវិធី, ការអនុវត្តថវិកាតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ។

ជារួមយើងអាចវាយតម្លៃប្រកបដោយការជឿជាក់ថា កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកំពុងស្ថិតនៅលើគន្លងដែលយើងម្ចាស់ការបានទាំងស្រុង ហើយរាជរដ្ឋាភិបាលក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** បានជ្រើសរើសអភិក្រមអនុវត្ត ដែលមានភាពប្រាកដនិយម និងអាចអនុវត្តបាន ជាពិសេសផ្តល់នូវលទ្ធផលជាក់ស្តែងជាបន្តបន្ទាប់នៅតាមដំណាក់កាលនីមួយៗ។ បន្ថែមពីនេះ, ប្រព័ន្ធថវិកាយើងកាន់តែមានភាពជឿទុកចិត្ត និងជាឧបករណ៍សំខាន់សម្រាប់ទ្រទ្រង់ និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម, មានបុរេលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីធានាគណនេយ្យភាពហិរញ្ញវត្ថុ, មានក្របខណ្ឌថវិការកម្មវិធីច្បាស់លាស់ **ជាឧបករណ៍សម្រាប់ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល ។**

ជាចុងបញ្ចប់, ក្នុងនាមជាប្រធាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**គ.ហ.ស.**), ខ្ញុំសូមធ្វើការវាយតម្លៃខ្ពស់ និងផ្តល់មូលវិចារដ៏ថ្លៃថ្លាចំពោះសហការី នៃរាជរដ្ឋាភិបាលកម្ពុជា, ក្រសួង-ស្ថាប័ន, និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច

និងហិរញ្ញវត្ថុ ដែលបានផ្តល់កិច្ចសហការ និងចូលរួមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេសអគ្គលេខាធិការ-ដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលបានខិតខំបំពេញមុខងាររបស់ខ្លួនជាឧត្តមសេនាធិការជូន **គ.ហ.ស.** ទាំងការងារដឹកនាំ, សម្របសម្រួល, ផ្សព្វផ្សាយ, គាំទ្រ និងត្រួតពិនិត្យវាយតម្លៃវឌ្ឍនភាពកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ខ្ញុំក៏សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅជូនចំពោះដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលតែងតែយកចិត្តទុកដាក់ និងបន្តគាំទ្រក្នុងទិដ្ឋភាពបច្ចេក-ទេស និងហិរញ្ញវត្ថុ សម្រាប់គាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុឱ្យប្រព្រឹត្តទៅដោយរលូន និងមានសន្ទុះល្អទៅមុខ, ក្រសួង-ស្ថាប័នដែលជាតួអង្គចូលរួមយ៉ាងសកម្មក្នុងការរៀបចំ និងអនុវត្ត, ព្រមទាំងសហសេវិកនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ៕

ថ្ងៃពុធ ០១រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០១៩

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន**

**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

# **អារម្ភកថា**

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺមានគោលបំណងកែប្រែជាជំហានៗនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជាឱ្យស្របទៅនឹងឧត្តមានុវត្តន៍អន្តរជាតិ ដោយបាននិងកំពុងកសាង និងពង្រឹងសមាសភាពស្នូលទាំង ៤ រួមមាន “**ការកែលម្អប្រព័ន្ធ, ក្របខ័ណ្ឌគតិយុត្ត, យន្តការស្ថាប័ន និងធនធានមនុស្ស**”។ បច្ចុប្បន្ន កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបាននិងកំពុងអនុវត្តដំណាក់កាលទី៣ គឺ “**ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**” ក៏កំពុងមានវឌ្ឍនភាពល្អនិងទើបតែត្រូវបានបញ្ចប់ការប្រជុំវាយតម្លៃសមិទ្ធកម្មប្រចាំឆ្នាំ២០១៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នាចុងខែឧសភា ឆ្នាំ២០១៩ កន្លងទៅ។

នៅក្នុងដំណាក់កាលទី៣ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) បានកំណត់គោលដៅអាទិភាពចំនួន ០៣ ដោយរួមមាន÷ (១). ការពង្រឹងការគ្រប់គ្រងនិងអនុវត្តផែនការប្រមូលចំណូល, (២). ការពង្រឹង និងពង្រីកការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) និង (៣). ការពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធី ព្រមទាំងផ្តល់ថវិកាគាំទ្រការអនុវត្តផែនការសកម្មភាពរបស់ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅតាមក្រសួង-ស្ថាប័នផងដែរ។ **អ.គ.ហ.** ដែលជាសេនាធិការឱ្យគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងភារកិច្ចសម្របសម្រួលការរៀបចំ និងអនុវត្ត, បានផ្តួចផ្តើមឱ្យមានការផ្សព្វផ្សាយជាទម្រង់ផ្សេងៗ ដូចជា សិក្ខាសាលា, វីដេអូ, ការបណ្តុះបណ្តាល, គេហទំព័រ, បណ្តាញទំនាក់ទំនងសង្គម (Facebook, YouTube) និងព្រឹត្តិបត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងឧបករណ៍ផ្សព្វផ្សាយនានា ក្នុងគោលដៅលើកកម្ពស់ការយល់ដឹង និងគាំទ្រដល់ទិសដៅ និងចក្ខុវិស័យនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា។ ជាក់ស្តែង **អ.គ.ហ.** បានរចនា និងបោះពុម្ពផ្សាយនូវព្រឹត្តិបត្រកម្មកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចំនួន **៦លេខ** រួចមកហើយ។ ដោយឡែក ព្រឹត្តិបត្រលេខ **៧** សម្រាប់ឆ្នាំ២០១៩ នេះ ក៏ត្រូវបានរក្សានូវអភិក្រមនៃការរៀបចំជាមួយការបន្តកែលម្អលើគុណភាពនៃឯកសារជាមួយនឹងការច្នៃប្រឌិតខ្ពស់ ដែលក្នុងនោះរួមមាន ការប្រមូលផ្តុំនូវព្រឹត្តិការណ៍ថ្មីៗ និងបទពិសោធន៍របស់ប្រទេសផ្សេងៗ ពាក់ព័ន្ធនឹងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងអត្ថបទអំពីយុទ្ធសាស្ត្រថ្មីៗ ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលទើបតែត្រូវបានប្រកាសដាក់ឱ្យអនុវត្ត និងផ្សព្វផ្សាយ កាលពីថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**គ.ហ.ស.**) ព្រមទាំងមានការចូលរួមជាអត្ថបទដ៏មានតម្លៃពីក្រុមការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈនៃអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មួយចំនួនផងដែរ។

ទន្ទឹមនេះ, **អ.គ.ហ.** ជឿជាក់ថាព្រឹត្តបត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះ នឹងក្លាយជាឧបករណ៍ជំនួយស្មារតី និងតម្លៃបន្ថែមជូនមន្ត្រីរាជការ ជាពិសេសសាធារណជន ដែលចង់ឈ្វេងយល់អំពីបច្ចុប្បន្នកម្ម នៃកិច្ចដំណើរការកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់រាជរដ្ឋាភិបាល។ លើសពីនេះ **អ.គ.ហ.** សូមចូលរួមវាយតម្លៃខ្ពស់ ជូនចំពោះគ្រប់អង្គភាពពាក់ព័ន្ធ ដែលតែងតែចូលរួម និងគាំទ្រការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រោមរូបភាពផ្សេងៗ ដែលនេះគឺជាឧត្តមវិភាគទាន សម្រាប់ប្រជាជាតិខ្មែរ៕៚

ថ្ងៃអង្គារ ១៥កើត ខែ អាសាឍ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ២០១៩

**អគ្គលេខាធិការ**

**អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំ**

**ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**រស់ សីលវ៉ា**

# មាតិកា

*ព្រឹត្តិបត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ - លេខ៧ - ឆ្នាំ២០១៩*

## ព្រឹត្តិការណ៍


**ទំព័រទី ០១**
កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០១៨ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣

**ទំព័រទី ០៤**
ទស្សនកិច្ចសិក្សាស្តីពី "ក្របខ័ណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ (PEFA)"

**ទំព័រទី ០៥**
ប្រកាសដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈ (FMIS) ជាផ្លូវការ នៅក្រសួង-ស្ថាប័នចំនួន ១០ និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្តទាំង ២៥ និងប្រកាសបន្តអនុវត្តគម្រោង FMIS ទៅកាន់ក្រសួង-ស្ថាប័នចំនួន ១៧សម្រាប់ឆ្នាំ ២០១៩


## អត្ថបទ


**ទំព័រទី ១១**
វិធីសាស្ត្រព្យាករចំណូល របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

**ទំព័រទី ១៥**
វិសាលភាពស្ថាប័ននៃប្រព័ន្ធស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល
(Institutional Coverage of Government Finance Statistics)

**ទំព័រទី ២៨**
យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ ឆ្នាំ២០១៩-២០២៥

**ទំព័រទី ៣៣**
បទពិសោធក្នុងការកែទម្រង់របស់ប្រទេសហ្វីលីពីន

**ទំព័រទី ៣៨**
ភាពជាដៃគូថ្មីក្នុងការគាំទ្រកំណើនសេដ្ឋកិច្ចនៅកម្ពុជា

**ទំព័រទី ១៣**
យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣

**ទំព័រទី ១៩**
ការត្រួតពិនិត្យ ការរៀបចំ និងការកំណត់សូចនាករសមិទ្ធកម្មគន្លឹះ ផែនការសកម្មភាពដំណាក់កាលទី៣នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

**ទំព័រទី ៣១**
មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ ចូលរួមចំណែកពង្រឹងសមត្ថភាពស្ថាប័នរដ្ឋបាលស្រុក

**ទំព័រទី ៣៦**
ក្របខ័ណ្ឌលទ្ធផលរវាងរាជរដ្ឋាភិបាលកម្ពុជា និងសហភាពអឺរ៉ុបឆ្នាំ២០១៩-២០២០

**ទំព័រទី ៤១**
សញ្ញាណទូទៅ នៃ "វិសហមជ្ឈការ" នៅកម្ពុជា

## សុន្ទរកថា

### ទំព័រទី ៤៥

សុន្ទរកថារបស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

### ទំព័រទី ៥០

សុន្ទរកថាស្វាគមន៍ របស់ឯកឧត្តម **រស់ សីលវ៉ា** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

## ទស្សនៈ និងមតិ

### ទំព័រទី ៥៥

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**
ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

### ទំព័រទី ៥៥

ឯកឧត្តម George Edgar ឯកអគ្គរដ្ឋទូត និងជាប្រធានប្រតិភូសហភាពអឺរ៉ុបប្រចាំកម្ពុជា

### ទំព័រទី ៥៦

ឯកឧត្តម **វង្សី វិស្សុត**
រដ្ឋលេខាធិការប្រចាំការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានប្រចាំការគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

### ទំព័រទី ៥៦

ឃ្លាដកស្រង់ចេញពីសៀវភៅ Toward Next Generation Performance Budgeting



2018 Annual Review Meeting
PEFA
Philippine
Development Plan
2017-2022








# ផ្នែកទី១

# ព្រឹត្តិការណ៍

# កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០១៨ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣

*ថ្ងៃពុធ ១១រោច ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី ២៩ ខែឧសភា ឆ្នាំ២០១៩ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានរៀបចំកិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០១៨ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ និងប្រកាសដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រចំនួន បី រួមមាន យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០១៩-២០២៥, យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ ឆ្នាំ២០១៩-២០២៥ និងយុទ្ធសាស្ត្រគៀរគរចំណូល២០១៩-២០២៣ ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់ របស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។*

កិច្ចប្រជុំនេះ មានការចូលរួមពីឯកឧត្តម លោកជំទាវ ជាថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន ,សមាជិកក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័ន,ឯកឧត្តមអភិបាល នៃគណៈអភិបាលរាជធានី-ខេត្ត, ឯកអគ្គរាជទូត/ឯកអគ្គរដ្ឋទូត, តំណាងដៃគូអភិវឌ្ឍន៍ និងតំណាងអង្គការមិនមែនរដ្ឋាភិបាលដែលសរុបប្រមាណ ៥០០រូប។

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាកម្មវិធីកែទម្រង់រយៈពេលវែង ដែលមានចក្ខុវិស័យប្រកបដោយមហិច្ឆិតា និងប្រាកដនិយម ក្នុងគោលដៅផ្លាស់ប្តូរប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជាឆ្ពោះទៅឧត្តមានុវត្តន៍អន្តរជាតិ ដោយបាននិងកំពុងកសាង និងពង្រឹងសមាសធាតុស្នូលទាំង ៤រួមមាន ការកែលម្អប្រព័ន្ធ, ក្របខ័ណ្ឌគតិយុត្ត, យន្តការស្ថាប័ន និងធនធានមនុស្ស។ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺ ត្រូវបានរៀបចំឡើង តាមលំដាប់លំដោយស្របតាមបរិបទ នៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា។

ឯកឧត្តម **រស់ សីលវ៉ា** អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានរាយការណ៍ជូនអង្គប្រជុំអំពីវឌ្ឍនភាព នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំឆ្នាំ ២០១៨ ដូចតទៅ÷

ការអនុវត្តយុទ្ធសាស្ត្រគៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ សម្រេចតាមគោលដៅ ដែលបាន ដាក់ចេញដោយចំណូលចរន្ត (ទិន្នន័យបណ្តោះអាសន្ន) មានកំណើន ០,៥ ពិន្ទុភាគរយនៃផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) ដែលឆ្នាំ២០១៨នេះ សម្រេចបាន ១,៤៧ ពិន្ទុភាគ-






រយនៃ ផ.ស.ស. ជាមធ្យមពីឆ្នាំ ២០១៤ ដល់ឆ្នាំ ២០១៨ ចំណូលចរន្តកើនឡើងប្រមាណ ១,៣៥ ពិន្ទុភាគរយនៃ ផ.ស.ស. ។

គម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តជំហានទី១ នៅឆ្នាំ២០១៤ និងជំហានទី២ នៅឆ្នាំ២០១៧ ។ទន្ទឹមនេះ,ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានធ្វើការកែសម្រួលប្លង់គណនេយ្យថ្មីឱ្យស្របតាមស្តង់ដារអន្តរជាតិ ព្រមទាំងបានរៀបចំ និងដាក់ឱ្យអនុវត្តប្រកាសស្តីពី ការដាក់ឱ្យ អនុវត្តចំណាត់ថ្នាក់ទាំង ៧ រួមមាន÷ (១) ចំណាត់ថ្នាក់អង្គភាពប្រតិបត្តិនិងរដ្ឋបាល, (២) ចំណាត់ថ្នាក់ភូមិសាស្ត្រ, (៣) ចំណាត់ថ្នាក់សេដ្ឋកិច្ច, (៤) ចំណាត់ថ្នាក់កម្មវិធី, (៥)ចំណាត់ថ្នាក់មុខងារ, (៦)ចំណាត់ថ្នាក់គម្រោង និង (៧) ចំណាត់ថ្នាក់មូលនិធិ ដោយក្នុងនោះ ចំណាត់ថ្នាក់ថវិកាចំនួន ៥ អនុវត្តបានពេញលេញ និងចំនួន២ ទៀតបាននិងកំពុងជំរុញការអនុវត្ត។ បន្ថែមពីនេះ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានកំណត់ផែនការពង្រីកប្រព័ន្ធ FMIS ប្រកបដោយភាពច្បាស់លាស់សំដៅគាំទ្រការ អនុវត្តថវិកាកម្មវិធី និងប្រព័ន្ធគណនេយ្យភាពហិរញ្ញវត្ថុ នៅតាមក្រសួង-ស្ថាប័ន ដូចតទៅ÷

- ✓ ឆ្នាំ២០១៨÷ ក្រសួង-ស្ថាប័នចំនួន ១០ ត្រូវបានដាក់ឱ្យ ប្រើប្រាស់ប្រព័ន្ធ FMIS ជាផ្លូវការ ។
- ✓ ឆ្នាំ២០១៩÷ ក្រសួង-ស្ថាប័ន ចំនួន ១០បន្ថែម និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្តទាំង២៥ ត្រូវដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ FMIS ជាផ្លូវការ ។
- ✓ ឆ្នាំ២០២០÷ ក្រសួង-ស្ថាប័នចំនួន ១៧ បន្ថែមនឹងត្រូវដាក់ ឱ្យប្រើប្រាស់ប្រព័ន្ធ FMIS ជាផ្លូវការ ។

❖ ការអនុវត្តថវិកាកម្មវិធី ត្រូវបាននិងកំពុងដាក់ឱ្យអនុវត្តគ្រប់ក្រសួង-ស្ថាប័ន និងគ្រប់រដ្ឋបាលរាជធានី-ខេត្ត។ ជាវឌ្ឍនភាព, ចាប់ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៨ ក្រសួង-ស្ថាប័ន ទាំង ៣៩ ត្រូវបានដាក់ឱ្យអនុវត្តថវិកាកម្មវិធីសាកល្បងពេញលេញ រីឯរដ្ឋបាលរាជធានី-ខេត្តទាំង២៥ ត្រូវបានដាក់ឱ្យអនុវត្តថវិកាកម្មវិធីសាកល្បងពេញលេញចាប់ពីឆ្នាំ២០១៧ រហូតដល់ឆ្នាំ២០២១។

ឯកឧត្តម George Edgar ឯកអគ្គរដ្ឋទូត





និងប្រធានប្រតិភូសហភាពអឺរ៉ុបប្រចាំកម្ពុជា និងជាតំណាងដៃគូអភិវឌ្ឍន៍ សូមអបអរសាទរដល់រដ្ឋាភិបាលចំពោះការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យមឆ្នាំ ២០១៤-២០១៨ ប្រកបដោយភាពជោគជ័យ។ ដៃគូអភិវឌ្ឍន៍សង្ឃឹមថា យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ នឹងទទួលបានជោគជ័យដូចគ្នានឹងយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យមឆ្នាំ ២០១៤-២០១៨ ផងដែរព្រមទាំងនឹងបន្តធ្វើទំនើបកម្មគោលនយោបាយសារពើពន្ធ និងមិនមែនសារពើពន្ធ និងរដ្ឋបាលសារពើពន្ធនិងមិនមែនសារពើពន្ធ ដើម្បីគាំទ្រកំណើនសេដ្ឋកិច្ច និងធានាសមធម៌ក្នុងចំណោមអ្នកជាប់ពន្ធ។

តាងនាមឱ្យរាជរដ្ឋាភិបាល ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានប្រកាសដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រទាំងបី គឺ យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣, យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ ឆ្នាំ ២០១៩-២០២៥, និង យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ ២០១៩-២០២៥, និងសូមឱ្យគ្រប់អង្គភាពពាក់ព័ន្ធទាំងអស់អនុវត្តយុទ្ធសាស្ត្រទាំងបីនេះ ប្រកបដោយឆន្ទៈ, មនសិការ, និងការទទួលខុសត្រូវខ្ពស់ ។

ក្នុងស្មារតីនេះ, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** បានផ្តល់អនុសាសន៍ និងដាក់ចេញអាទិភាព សម្រាប់អាទិភាព និងតម្រង់ទិស ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងឆ្នាំ ២០១៩ នេះ និងបណ្តាឆ្នាំខាងមុខ ដូចខាងក្រោម÷

- រៀបចំផែនការសកម្មភាពសម្រាប់ការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣, យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥ និងយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ ឆ្នាំ ២០១៩-២០២៥ ព្រមទាំងជំរុញ និងតាមដានការអនុវត្តយុទ្ធសាស្ត្រទាំងបី ។
- ពង្រីក និងពង្រឹងការអនុវត្តការដាក់ឱ្យដំណើរការនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ



នៅតាមក្រសួង-ស្ថាប័ន ទន្ទឹមនឹងការជំរុញធ្វើស្វ័យប្រវត្តិកម្មការអនុវត្តថវិកា ដោយចាប់ផ្តើមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

- យកចិត្តទុកដាក់លើការកែលម្អគុណភាពនៃថវិកាកម្មវិធី ដោយផ្តោតលើសមិទ្ធកម្ម និងបន្តសាកល្បងដាក់ឱ្យអនុវត្តក្របខ័ណ្ឌហិរញ្ញវត្ថុរយៈពេលមធ្យម និងក្របខ័ណ្ឌថវិការយៈពេលមធ្យម។
- ពិនិត្យ និងកែលម្អនីតិវិធីអនុវត្តថវិកាទាំងក្នុង ក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងក្រសួង-ស្ថាប័នសាមី ដោយផ្តោតជាសំខាន់ លើការត្រួតពិនិត្យរបាយការណ៍អនុវត្ត ឬរបាយការណ៍លទ្ធផល និងបង្កើតឧបករណ៍ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការអនុវត្តថវិកា ។
- យកចិត្តទុកដាក់ឱ្យ បានខ្លាំងក្លាថែមទៀតលើ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ដោយពិនិត្យលទ្ធភាពឱ្យមានយុទ្ធសាស្ត្រ, គោលនយោបាយ ឬផែនការសកម្មភាពច្បាស់លាស់។
- បន្តពង្រឹងសមត្ថភាព ផ្នែកគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងផ្ទៃក្នុង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីទ្រទ្រង់ដល់ការងារកែទម្រង់ផង និងដើម្បីជំរុញប្រសិទ្ធភាពនៃការអនុវត្តកិច្ចការប្រចាំថ្ងៃផង។
- បន្តពង្រឹងការសម្របសម្រួលការងារ និងអនុវត្តការងារប្រទាក់ក្រឡាគ្នា រវាងកែទម្រង់ទាំងបី រួមមាន ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ការកែទម្រង់រដ្ឋបាលសាធារណៈ, និង វិមជ្ឈការ និងវិសហមជ្ឈការ។
- **អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវពិនិត្យឡើងវិញ និងបូក**




*ការអនុវត្តថវិកាកម្មវិធី ត្រូវបាននិងកំពុងដាក់ឱ្យអនុវត្តគ្រប់ក្រសួង-ស្ថាប័ន និងគ្រប់រដ្ឋបាលរាជធានី-ខេត្ត។ ជាវឌ្ឍនភាព, ចាប់ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៨ ក្រសួង-ស្ថាប័ន ទាំង៣៩ ត្រូវបានដាក់ឱ្យអនុវត្តថវិកាកម្មវិធីសាកល្បងពេញលេញ រីឯរដ្ឋបាលរាជធានី-ខេត្តទាំង២៥ ត្រូវបានដាក់ឱ្យអនុវត្តថវិកាកម្មវិធីសាល្បងពេញលេញ ចាប់ពីឆ្នាំ២០១៧ រហូតដល់ឆ្នាំ២០២១*

## សរុបការអនុវត្តផែនការសកម្មភាពរួម ដំណាក់កាលទី៣ និងត្រៀមរៀបចំផែនការសកម្មភាពរួមសម្រាប់ដំណាក់កាល ទី៤ ដោយផ្តោតលើខឿនទី៤ គឺ គណនេយ្យភាពសមិទ្ធកម្ម។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** បានវាយតម្លៃខ្ពស់ និងផ្តល់មូលវិចារដ៏ថ្លៃថ្លាចំពោះសហការី នៃរាជរដ្ឋាភិបាលកម្ពុជា, ក្រសួង-ស្ថាប័ន, និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទាំងអស់ ដែលបានខិតខំប្រឹងប្រែងអនុវត្តសកម្មភាពទាំងឡាយនៅក្រោមកម្មវិធីកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រហូតសម្រេចបានលទ្ធផលល្អប្រសើរ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់សហគមន៍អឺរ៉ុប, ធនាគារពិភពលោក, ធនាគារអភិវឌ្ឍន៍អាស៊ី, មូលនិធិរូបិយវត្ថុអន្តរជាតិ, អង្គការយូនីសេហ្វ, រដ្ឋាភិបាលបារាំង/AFD, រដ្ឋាភិបាលអូស្ត្រាលី, និងស្ថាប័នអន្តរជាតិផ្សេងទៀតដែលបាន និងគ្រោងបន្តផ្តល់ជំនួយហិរញ្ញវត្ថុនិងបច្ចេកទេស សម្រាប់គាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ នេះឱ្យប្រព្រឹត្តទៅដោយរលូន និងមានសន្ទុះល្អទៅមុខហើយនិងរំពឹងទុកចំពោះស្មារតី សហការបែបនេះក្នុងដំណាក់កាលបន្តបន្ទាប់ទៀត៕■

# ប្រកាសដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ជាផ្លូវការ នៅក្រសួង-ស្ថាប័នចំនួន ១០ និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្តទាំង ២៥ និងប្រកាសបន្តអនុវត្តគម្រោង FMIS ទៅកាន់ក្រសួង-ស្ថាប័នចំនួន ១៧ សម្រាប់ឆ្នាំ២០១៩

*លេខាធិការដ្ឋានក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) បានរៀបចំកម្មវិធី “ប្រកាសដាក់ ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ជាផ្លូវការ នៅក្រសួង-ស្ថាប័ន ចំនួន១០ និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្តទាំង២៥ និងប្រកាសបន្តអនុវត្តគម្រោង FMIS ទៅកាន់ក្រសួង-ស្ថាប័ន ចំនួន១៧ សម្រាប់ឆ្នាំ២០១៩” នៅព្រឹក ថ្ងៃចន្ទ ០៦រោច ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៩ នៅសាលប្រជុំអគារ “ឃ” ទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។*

កិច្ចប្រជុំនេះ មានការចូលរួមពីថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, តំណាងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្តទាំង២៥, តំណាងក្រសួង-ស្ថាប័ន និងតំណាងដៃគូអភិវឌ្ឍន៍សរុបប្រមាណ ២៣០ រូប។ កម្មវិធីនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងចំនួន ២ គឺ ទី១) ប្រកាសឱ្យក្រសួង-ស្ថាប័នចំនួន ១០បន្ថែម និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្តទាំង ២៥ ចាប់ផ្តើមធ្វើប្រតិបត្តិការផ្លូវការក្នុងការអនុវត្តថវិកា និងគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធ FMIS និង ទី២) ប្រកាសឱ្យក្រសួងស្ថាប័នដែលនៅ សេសសល់ ចំនួន ១៧ ចូលរួមសហការ អនុវត្តគម្រោង FMIS ប្រព្រឹត្តទៅដោយភាពរលូន និងជោគជ័យ តាមផែនការគ្រោងទុកដើម្បីត្រៀមប្រើប្រាស់ប្រព័ន្ធ FMIS ជាផ្លូវការក្នុងឆ្នាំ ២០២០។




ដោយប្រកាន់ខ្ជាប់នូវចក្ខុវិស័យច្បាស់

លាស់ និងប្រាកដប្រជា។ កម្ពុជាបាននិងកំពុងប្រែក្លាយប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដែលផ្តោតលើធាតុចូល និងមជ្ឈការ ទៅជាប្រព័ន្ធដែលផ្តោតលើលទ្ធផល និងវិមជ្ឈការស្របតាមបទដ្ឋានអន្តរជាតិ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** បានថ្លែងនៅក្នុងកម្មវិធីនេះផងដែរថា វឌ្ឍនភាពដ៏ធំធេង នៃការអនុវត្តគម្រោង FMIS តាំងពីឆ្នាំ២០១៤ រហូតមកដល់បច្ចុប្បន្ននេះគឺបានបង្កើតជាឆ្អឹងខ្នង និងបានចូលរួមចំណែកយ៉ាងខ្លាំងក្នុងការជំរុញឱ្យកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងយុទ្ធសាស្ត្រ កែទម្រង់ប្រព័ន្ធថវិកាកម្ពុជា បោះជំហានទៅមុខជាលំដាប់ជាមួយនឹងការចាក់គ្រឹះដ៏រឹងមាំ សម្រាប់ឈានទៅ សម្រេចគោលដៅនៅឆ្នាំ ២០២៥ គឺ “**គណនេយ្យភាពសមិទ្ធកម្ម**” ។ នេះគឺជាមោទនភាពសម្រាប់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជាព្រោះថាយើងធ្វើបានល្អប្រសើរ និងបានលឿនជាងបណ្តាប្រទេសមួយចំនួនក្នុងតំបន់ បើយោងតាមការវាយតម្លៃរបស់ធនាគារពិភពលោក។ “**វឌ្ឍនភាព និងសមិទ្ធផល**” នេះគឺបានកើតចេញពីការខិតខំប្រឹងប្រែងរបស់យើងទាំងអស់គ្នា ដោយឈរលើមូលដ្ឋាន ÷ ***ប្រមូលផ្តុំ, ពិភាក្សា និង ដោះស្រាយរួមគ្នាក្នុងស្មារតីជាក្រុមតែមួយ។***

*សម្រាប់ដើមឆ្នាំ២០១៩ នេះប្រព័ន្ធ FMIS បន្តដាក់ឱ្យដំណើរការមុខងារទាំង៤ ដែលមានស្រាប់ក្នុងចំណោមមុខងារទាំង ៦ របស់ប្រព័ន្ធរួមមាន មុខងារវិភាជន៍ថវិកា, មុខងារការទិញ, មុខងារគណនេយ្យត្រូវសង, និងមុខងារគណនេយ្យត្រូវទារ ដល់ក្រសួង-ស្ថាប័នចំនួន ១០ បន្ថែមទៀត។*

នៅឆ្នាំ២០១៩ នេះក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានដាក់ចេញនូវផែនការសកម្មភាព ក្នុងការសិក្សាលើការតម្រង់ទិស និងកែលម្អនីតិវិធីអនុវត្តការងារបច្ចុប្បន្នដោយតម្រឹមជាអតិបរមាជាមួយនឹងនីតិវិធីអនុវត្តការងារតាមប្រព័ន្ធ FMIS ដើម្បីឱ្យការអនុវត្តន៍មានអនុលោមភាពទៅនឹង “**យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥**”។

ក្នុងឱកាសនោះដែរ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ក៏បានផ្តាំផ្ញើដល់ក្រសួង-ស្ថាប័នដែលបានចាប់ផ្តើមចូលរួមអនុវត្តគម្រោង FMIS ក្នុងឆ្នាំ ២០១៩ នេះ ដូចតទៅ÷

- ថ្នាក់ដឹកនាំ និងមន្ត្រីអនុវត្តការងារថវិកា និងហិរញ្ញវត្ថុត្រូវចូលរួមអនុវត្តប្រកបដោយស្មារតីបុរេសកម្ម និងអន្តរសកម្ម រួមជាមួយនឹងឆន្ទៈខ្ពស់ ការភ្ញាក់រលឹក និង មានភាពម្ចាស់ការ ពិសេសពីថ្នាក់ដឹកនាំ និងសមាជិកនៃក្រុមការងារអនុវត្តគម្រោង FMIS ប្រចាំក្រសួង-ស្ថាប័ន
- ត្រៀមលក្ខណៈសម្រិតសម្រាំងមន្ត្រីដែលត្រូវប្រើប្រាស់ប្រព័ន្ធ FMIS ឱ្យត្រូវតាមតម្រូវការ និងជំនាញវិជ្ជាជីវៈជៀសវាងការយកមន្ត្រីដែលពុំមានការពាក់ព័ន្ធ ឬខុសមុខងារ ឬមន្ត្រីដែលជិតចូលនិវត្តន៍ព្រមទាំងជំរុញលើកទឹកចិត្តដល់មន្ត្រីក្រោមឱវាទក្នុងការចូលរួមនូវវគ្គបណ្តុះបណ្តាលនានា ដែលរៀបចំឡើងក្នុងក្របខណ្ឌ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពិសេសក្នុងគម្រោង FMIS
- ត្រូវគិតគូរ, វិភាគ និងកំណត់ឱ្យបានច្បាស់អំពីចំនួនថ្នាក់ដឹកនាំ និងមន្ត្រីដែល







ត្រូវចាត់តាំងជាអ្នកប្រើប្រាស់ប្រព័ន្ធ FMIS ដើម្បីបង្ការនូវការស្នើសុំបន្ថែម និងផ្លាស់ប្តូរអ្នកប្រើប្រាស់ប្រព័ន្ធ ដែលអាចបង្កភាពស្មុគស្មាញទាំងការរៀបចំវគ្គបណ្តុះបណ្តាល និង នៅពេលប្រើប្រាស់ប្រព័ន្ធ

- ត្រូវពិនិត្យលើមូលដ្ឋានច្បាប់ និងបទដ្ឋានគតិយុត្តចាំបាច់នានា ដែលត្រូវត្រៀមរៀបចំ កែលម្អសម្រាប់ទ្រទ្រង់ដល់ការប្រើប្រាស់ប្រព័ន្ធ FMIS ប្រកបដោយប្រសិទ្ធភាពខ្ពស់ ជាពិសេសការកាត់សម្រួលនីតិវិធីអនុវត្តការងារនៅក្នុងស្ថាប័នរបស់ខ្លួនដើម្បីកាត់បន្ថយនូវ ភាពស្មុគស្មាញដែលអាចកើតមាននៅពេលដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ FMIS និង
- ត្រូវត្រៀមរៀបចំកន្លែងការងារ និងក្រុមការងារអនុវត្តគម្រោង FMIS របស់ខ្លួន ដើម្បីចូលរួមសហការធ្វើការងារឱ្យបានជិតស្និទ្ធ ជាមួយក្រុមការងារគ្រប់គ្រង FMIS របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុធ្វើការរួមគ្នាជាក្រុម តែមួយ ក្នុងការសម្រេចឱ្យបានជោគជ័យតាមការដ្ឋាននីមួយៗ និងតាមផែនការដែលបានដាក់ចេញ។

សម្រាប់ដើមឆ្នាំ២០១៩ នេះប្រព័ន្ធ FMIS បន្តដាក់ឱ្យដំណើរការមុខងារទាំង៤ ដែលមានស្រាប់ក្នុងចំណោមមុខងារទាំង៦ របស់ប្រព័ន្ធរួមមាន **មុខងារវិភាជន៍ថវិកា, មុខងារការទិញ, មុខងារគណនីត្រូវសង និង មុខងារគណនីត្រូវទារ** ដល់ក្រសួង-ស្ថាប័នចំនួន ១០ បន្ថែមទៀតគឺ÷ (១) ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ, (២) ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, (៣) ក្រសួងពាណិជ្ជកម្ម, (៤) ក្រសួងសាធារណៈការ និងដឹកជញ្ជូន, (៥) ក្រសួងធនធានទឹក និងឧតុនិយម, (៦) ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, (៧) ក្រសួងអភិវឌ្ឍន៍ជនបទ, (៨) ក្រសួងព័ត៌មាន, (៩) ក្រសួងទេសចរណ៍ និង (១០) រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលរួមទាំងគ្រប់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្តទាំង ២៥៕■



# ទស្សនកិច្ចសិក្សាស្តីពី “ក្របខ័ណ្ឌចំណាយសាធារណៈ និងគណនេយ្យ-ភាពហិរញ្ញវត្ថុ (PEFA)”

*កាលពីថ្ងៃទី២៥ ដល់ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៩, ប្រតិភូអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ.) បានធ្វើដំណើរទស្សនកិច្ចសិក្សាស្តីពី “ក្របខ័ណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ (PEFA: Public Expenditure and Financial Accountability Framework)” នៅខេត្ត Luang Prabang នៃសាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ។*




តាមការអញ្ជើញរបស់ធនាគារពិភព-លោក (World Bank) ដោយមានការចូលរួមពីប្រតិភូនៃក្រសួងហិរញ្ញវត្ថុនៃប្រ-ទេសហ្វីលីពីន, ឥណ្ឌូនេស៊ី, មីយ៉ាន់ម៉ា, ប៉ាពួអាស៊ីនូវែលហ្គីណេ (Papua New Guiea), និងវៀតណាមព្រមទាំងតំណាងពីដៃគូអភិវឌ្ឍន៍ដែលមានសហគមន៍អឺរ៉ុប និងធនាគារពិភពលោកផងដែរ។

**ថ្ងៃទី១ “កម្មវិធីផ្លាស់ប្តូរបទពិសោធន៍អន្តរជាតិលើកិច្ច-ការ PEFA ”**

ទន្ទឹមនេះ, ប្រតិភូ **អ.គ.ហ.** បានចូល-រួមកម្មវិធីផ្លាស់ប្តូរបទពិសោធន៍អន្តរជាតិលើកិច្ចការ PEFA ដោយប្រតិភូនៃប្រទេសចំនួន ៤ រួមមាន ប្រទេសឡាវ, វៀតណាម, ហ្វីលីពីន និងឥណ្ឌូនេស៊ី ធ្វើការចែករំលែកនូវបទពិសោធន៍អំពីបញ្ហាប្រឈម, ដំ-ណោះស្រាយ, គំនិតផ្តួចផ្តើម និងឧត្តមា-នុវត្តន៍ ដែលបានប្រើប្រាស់ឧបករណ៍ PEFA ដើម្បីធ្វើការវាយតម្លៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដើម្បីកំណត់ភាពខ្លាំង និងភាពខ្សោយក្នុងគោលបំណងធ្វើទំនើបកម្មប្រព័ន្ធ

ហិរញ្ញវត្ថុ។

### ❖ បទពិសោធន៍ប្រទេសឡាវ

រដ្ឋាភិបាលឡាវ បានប្រើប្រាស់ឧបករណ៍ PEFA ដើម្បីធ្វើការវាយតម្លៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈក្នុងប្រទេសរបស់ខ្លួន, ដោយផ្អែកលើលទ្ធផលនៃការវាយតម្លៃ PEFA ក្នុងឆ្នាំ២០១៨ នេះបានឆ្លុះបញ្ចាំងពីទិដ្ឋភាពជាក់ស្តែងនូវស្ថានភាពនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ប្រទេសឡាវ។

### ❖ បទពិសោធន៍ឥណ្ឌូនេស៊ី

សម្រាប់រដ្ឋាភិបាលឥណ្ឌូនេស៊ីការប្រើប្រាស់ក្របខ័ណ្ឌវាយតម្លៃ PEFA ត្រូវបានទទួលស្គាល់ថាជាការគាំទ្រដល់ដំណើរការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលកន្លងមក ការ

*រចនាសម្ព័ន្ធ PEFA ត្រូវបានបែងចែកលទ្ធផលចុងក្រោយចំនួន ៣ (វិន័យថវិកា, យុទ្ធសាស្ត្រវិភាជន៍ថវិកា និងប្រសិទ្ធភាពការផ្តល់សេវាសាធារណៈ), សរសរស្តម្ភចំនួន ០៧, សូចនាករសមិទ្ធកម្មចំនួន ៣១ និងសមាសធាតុចំនួន ៩៤ សម្រាប់ក្របខ័ណ្ឌរដ្ឋបាលថ្នាក់ជាតិ ។*



វាយតម្លៃត្រូវបានអនុវត្តចំនួន ៣ លើក រួចមកហើយពោលគឺក្នុងឆ្នាំ ២០០៧, ឆ្នាំ២០១២, និងឆ្នាំ២០១៧ តាមរយៈលទ្ធផល នៃការវាយតម្លៃ PEFA នេះ បានជួយដល់រដ្ឋាភិបាលឥណ្ឌូនេស៊ី បង្កើតនូវប្រព័ន្ធការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលមានភាពល្អប្រសើរ ដែលអាចធ្វើការតាមដានត្រួតពិនិត្យ






និងវាយតម្លៃ ដើម្បីកំណត់ភាពខ្លាំង និងភាពខ្សោយនៃការអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

### ថ្ងៃទី២ និងទី៣ "វគ្គបណ្តុះបណ្តាល PEFA"

វគ្គបណ្តុះបណ្តាលស្តីពី PEFA ត្រូវបានរៀបចំឡើង នៅថ្ងៃទី ២៦-២៧ ខែមីនា ឆ្នាំ២០១៩ ដោយលេខាធិការដ្ឋាន PEFA ។ ក្របខ័ណ្ឌ PEFA ត្រូវបានបែងចែកជាពីររួមមាន PEFA សម្រាប់ថ្នាក់ជាតិ និង PEFA ថ្នាក់ក្រោមជាតិ ។

រចនាសម្ព័ន្ធ PEFA ត្រូវបានបែងចែកលទ្ធផលចុងក្រោយចំនួន ៣ (វិន័យថវិកា, យុទ្ធសាស្ត្រវិភាជន៍ថវិកា និងប្រសិទ្ធភាពការផ្តល់សេវាសាធារណៈ), សសរស្តម្ភចំនួន ០៧, សូចនាករសមិទ្ធកម្មចំនួន ៣១ និងសមាសធាតុចំនួន ៩៤ សម្រាប់ក្របខណ្ឌរដ្ឋបាលថ្នាក់ជាតិ ។ រីឯ សម្រាប់ក្របខ័ណ្ឌរដ្ឋបាលថ្នាក់ក្រោមជាតិលេខាធិការដ្ឋាន PEFA គឺដូចនឹងសូចនាករថ្នាក់ជាតិដែរ ប៉ុន្តែបន្ថែមមួយសូចនាករ "ភាពប៉ាន់ប្រមាណការផ្ទេរធនធានពីថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិ" និងសមាសធាតុចំនួន ៣ រួមមាន (ទី១) គម្លាតថវិកាប្រចាំឆ្នាំរវាងការផ្ទេរថវិកាសរុបជាក់ស្តែងពីច្បាប់ថវិកា ពីថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិ, (ទី២) គម្លាតប្រចាំឆ្នាំរវាងការផ្ទេរធនធានហិរញ្ញវត្ថុជាក់ស្តែង និងធនធានហិរញ្ញវត្ថុក្នុងច្បាប់ថវិកា, និង (៣) ភាពទាន់ពេលវេលានៃការផ្ទេរថវិកាក្នុងឆ្នាំពីថ្នាក់ជាតិ។

ជារួម សម្រាប់បទពិសោធន៍នៃការវាយតម្លៃ PEFA នៅកម្ពុជា សម្រាប់ថ្នាក់ជាតត្រូវប្រើប្រាស់ចំនួន ០២ លើកដោយលើក ទីមួយ ធ្វើឡើងក្នុងឆ្នាំ២០១០ ដែលប្រើប្រាស់ទិន្នន័យឆ្នាំ២០០៦, ២០០៧, និង ២០០៨ ហើយលើកទី២ នៅឆ្នាំ២០១៥ដោយប្រើប្រាស់ទិន្នន័យឆ្នាំ២០១១, ២០១២ និង ២០១៣ ។ ទោះបីជាយ៉ាងនេះក្តី, សម្រាប់ការវាយតម្លៃប្រព័ន្ធហិរញ្ញវត្ថុថ្នាក់ក្រោមជាតិនៅកម្ពុជា គឺពុំទាន់បានធ្វើការវាយតម្លៃនៅឡើយ ។ ឆ្លងតាមរយៈទស្សនកិច្ចសិក្សា រយៈពេល ៣ថ្ងៃ នេះ, បទពិសោធន៍ និងមេរៀនពីបណ្តាប្រទេសនានា ដើម្បីវាយតម្លៃ PEFA ថ្នាក់ក្រោមជាតិនៅឆ្នាំ ២០១៩ និងថ្នាក់ជាតិនៅឆ្នាំ២០២០ ក្នុងគោលបំណងពិនិត្យលើប្រព័ន្ធហិរញ្ញវត្ថុ ដើម្បីកំណត់ភាពខ្លាំង និងភាពខ្សោយដែលជាធាតុចូលយ៉ាងសំខាន់ក្នុងការរៀបចំក្របខណ្ឌផែនការសកម្មភាពរួម ដំណាក់កាលទី៤ "គណនេយ្យភាពសមិទ្ធកម្ម" ឆ្នាំ ២០២១-២០២៥ ៕■ *រៀបចំដោយ÷ អ.គ.ហ.*



113.0%
110.7%
105.9%
109.3%
10,516,195
11,640,021
11,888,929
13,339,518
14,347,021
15,193,250
16,606,429
18,152,554
2015
2016
2018 Annual Review Meeting
PEFA
Philippine
Development Plan
2017-2022




Press Conference
2018 Annual Review Meeting
Public Financial Management Reform Program - Stage 3



# ផ្នែកទី២

# អត្ថបទ

# វិធីសាស្ត្រព្យាករចំណូល របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

*អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានតួនាទីស្នូលពាក់ព័ន្ធនឹងការគ្រប់គ្រង, ត្រួតពិនិត្យ និងប្រមូលពន្ធអាករគ្រប់ប្រភេទលើទំនិញនាំចេញ និងនាំចូល, បង្ការ និងបង្ក្រាបបទល្មើសគយ, និងចូលរួមអនុវត្តគោលនយោបាយពាណិជ្ជកម្មអន្តរជាតិ ។*

ដើម្បីធានាប្រសិទ្ធភាពការប្រមូលពន្ធអាករគ្រប់ប្រភេទ ក៏ដូចជាការចូលរួមចំណែកធានានូវចីរភាពចំណូលថវិកាជាតិ ដែលនឹងត្រូវវិភាជទៅតាមអាទិភាពនៃគោលនយោបាយរបស់រាជរដ្ឋាភិបាល អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា បានកសាងយុទ្ធសាស្ត្រកំណែទម្រង់ និងទំនើបកម្មគយឆ្នាំ២០១៩-២០២៣ ដែលក្នុងនោះមានគោលដៅយុទ្ធសាស្ត្រមួយសំដៅពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូល។ ការកសាងគំរូព្យាករចំណូល ជាសកម្មភាពចូលរួមសំខាន់សម្រាប់ចង្អុលបង្ហាញពីលទ្ធភាពនៃការប្រមូលចំណូល និងជាមូលដ្ឋានដាក់ចេញនូវគោលនយោបាយសមស្របនានា។ ក្រុមការងារព្យាករចំណូលរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានជ្រើសរើសគំរូព្យាករតាមវិធីសាស្ត្រ Buoyancy មកប្រើប្រាស់។

វិធីសាស្ត្រនេះត្រូវបានរៀបចំឡើងដោយចែកចេញជា ០២ផ្នែកសំខាន់ៗ។ **ផ្នែកទី១** ជាផ្នែកដែលគណនាមេគុណទំនាក់ទំនង (Coefficient) ចេញពីការប៉ាន់ស្មាន (OLS Regression) រវាងតម្លៃចំណូលពន្ធអាករដែលប្រមូលបានប្រចាំឆ្នាំ និងតម្លៃតំណាងសម្រាប់គិតពន្ធអាករ (Proxy tax base) តាមឆ្នាំនីមួយៗ។ ផលិតផលក្នុងស្រុកសរុបប្រចាំឆ្នាំគិតក្នុងថ្លៃបច្ចុប្បន្ន (ផ.ស.ស. ថ្លៃបច្ចុប្បន្ន) ត្រូវបានកំណត់យកជាតម្លៃតំណាងសម្រាប់គិតពន្ធអាករ។ ទន្ទឹមនឹងនេះ គេក៏ត្រូវបំលែងទិន្នន័យធាតុចូលទាំងពីរនេះទៅជាទម្រង់លោការីត (Natural logarithm) មុននឹងធ្វើការប៉ាន់ស្មានមេគុណទំនាក់ទំនង ឬភាពរលាស់ (Elasticity) រវាងបម្រែបម្រួលចំណូលទៅនឹងបម្រែបម្រួល ផ.ស.ស ថ្លៃបច្ចុប្បន្ន ។ ផ្នែកនេះគេអាចហៅបានថាជាការព្យាករដែលមិនរងផលប៉ះពាល់ពីកត្តាហានិភ័យខាងក្រៅ (Baseline projections)។ ផ្នែកទី២ កែតម្រូវបន្ថែមទៅលើគំរូព្យាករ ។ ផ្នែកនេះត្រូវបានប៉ាន់ស្មានដោយការវាយតម្លៃ និងកំណត់ចេញជាតួលេខលើព័ត៌មានបែបគុណវិស័យលើការប្រែប្រួលជាបណ្តោះអាសន្នអាចមានដូចជា កំណែទម្រង់ស្ថាប័ន, បម្រែបម្រួលគោលនយោបាយ ឬអន្តរាគមន៍ផ្សេងៗក្នុងរយៈពេលខ្លី, និងបញ្ហាប្រឈមនានាពីកត្តាខាងក្រៅដែលអាចកើតឡើងជាយថាហេតុ មានដូចជាការប្រែប្រួលនិន្នាការនយោបាយពាណិជ្ជកម្មពិភពលោកដែលមានផលប៉ះពាល់ដល់សេដ្ឋកិច្ច និងពាណិជ្ជកម្មកម្ពុជា។

វិធីសាស្ត្រនេះត្រូវបានកំណត់ដូចខាងក្រោម÷

$$R^{f}_{t+1} = R_t * (1 + g^{f}_{t+1}) + Adjustment$$

## ការកៀរគរចំណូលក្នុងស្រុក និងកំណើនចំណូលចរន្ត



| ប្រភេទទិន្នន័យ/ព័ត៌មាន | ស្ថាប័នផលិត/ចងក្រង |
|---|---|
| ***ធាតុចូលសម្រាប់គំរូព្យាករ*** | |
| ១. ចំណូលពន្ធតាមប្រភេទទំនិញសំខាន់ៗ ឬតាមចំណូលប្រភេទពន្ធប្រចាំឆ្នាំ | អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា |
| ២. ផលិតផលក្នុងស្រុកសរុបគិតតាមថ្លៃបច្ចុប្បន្ន (ផ.ស.ស ថ្លៃបច្ចុប្បន្ន) | វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ និងអគ្គនាយដ្ឋានគោលនយោបាយ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ***កែតម្រូវបន្ថែមទៅលើគំរូព្យាករ*** | |
| ៣. ទិន្នន័យតាមវិស័យដែលពាក់ព័ន្ធ (សំណង់, វិនិយោគ, ទេសចរណ៍, ...) និងការពិភាក្សាជាមួយផ្នែកឯកជន | ក្រសួង/ ស្ថាប័នទទួលបន្ទុកតាមវិស័យ |
| ៤. កំណែទម្រង់របស់ស្ថាប័នដែលមានពាក់ព័ន្ធកិច្ចការប្រមូលចំណូល | អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា |
| ៥. កត្តាសេដ្ឋកិច្ច និងពាណិជ្ជកម្មខាងក្រៅ ឬ ពិភពលោកដែលជះឥទ្ធិពលដល់សេដ្ឋកិច្ច និងពាណិជ្ជកម្មកម្ពុជា | ស្ថាប័នអន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានា |

- $R^{f}_{t+1}$ : ការព្យាករក្នុងឆ្នាំខាងមុខ
- $R_t$ : តម្លៃប៉ាន់ស្មាន ឬជាក់ស្តែងចុងក្រោយរបស់ទិន្នន័យ ដែលត្រូវព្យាករនៅឆ្នាំ (t)
- $\hat{\beta}$ : មេគុណប៉ាន់ស្មានសម្រាប់ចំណូលតាមមុខទំនិញសំខាន់ៗ ឬតាមប្រភេទពន្ធអាករដោយត្រូវបានគណនា ឬប៉ាន់ស្មាន (OLS Regression) រវាងតម្លៃចំណូលតាមមុខទំនិញសំខាន់ៗ ឬតាមប្រភេទពន្ធអាករជាមួយ នឹងតម្លៃតំណាងសម្រាប់គិតពន្ធអាករ (Proxy tax base)

**តាងដោយ÷**

$Buoyancy_t = \Delta\% Revenue_t / \Delta\%GDP_t$

សម្រាប់ការគណនា ឬតាងដោយ:

$LnRevenuet=constant+ \alpha LnGDP_t + Error_t$ ប៉ាន់ស្មាន (OLS Regression)

- $g^{f}_{t+1}$ : ការព្យាករកំណើនរបស់តម្លៃតំណាងសម្រាប់គិតពន្ធអាករ (Proxy tax base)
- Adjustment : ផ្នែកកែតម្រូវបន្ថែមទៅលើគំរូព្យាករ។

ការរៀបចំគំរូព្យាករតាមវិធីសាស្ត្រ Buoyancy ត្រូវការទិន្នន័យជាធាតុចូលផ្ទាល់និងទិន្នន័យពាក់ព័ន្ធបន្ថែម ពីប្រភពផ្សេងៗ ជាប្រចាំសម្រាប់គាំទ្រដល់ការវិភាគ និងព្យាករ។ ទិន្នន័យធាតុចូលទាំងនោះមានដូចខាងក្រោម÷

ជារួម, អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា បានកំណត់យកវិធីសាស្ត្រ Buoyancy សម្រាប់ធ្វើការព្យាករចំណូលគយ ដោយហេតុថា÷ វិធីសាស្ត្រនេះធ្វើការព្យាករពីកម្រិតចំណូល ដែលអាចប្រមូលបានដោយគិតទាំងលើកត្តាកំណើននៃសេដ្ឋកិច្ច និងកត្តារួមផ្សំជាច្រើនទៀត ដូចជាកំណែទម្រង់ស្ថាប័ន, បម្រែបម្រួលគោលនយោបាយពន្ធ, បញ្ហាប្រឈមនានាពីកត្តាខាងក្រៅដែលអាចកើតឡើងជាយថាហេតុផងដែរ។ ហេតុនេះ វិធីសាស្ត្រ Buoancy ត្រូវ

*ការកសាងគំរូព្យាករចំណូល ជាសកម្មភាពចូលរួមសំខាន់សម្រាប់ចង្អុលបង្ហាញពីលទ្ធភាពនៃការប្រមូលចំណូល និងជាមូលដ្ឋានដាក់ចេញនូវគោលនយោបាយសមស្របនានា ។*

បានកត់សម្គាល់ថា មានលក្ខណៈសមស្របសម្រាប់រដ្ឋបាលប្រមូលចំណូលក្នុងការព្យាករ,វិភាគ និងវាយតម្លៃចំណូលតាមមុខទំនិញ ឬតាមប្រភេទពន្ធអាករ និងធ្វើជាមូលដ្ឋានក្នុងការរៀបចំគោលនយោបាយពន្ធនានា ។■

*រៀបចំដោយ÷ ក្រុមការងារកែទម្រង់នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា*

# យុទ្ធសាស្ត្រគៀរគរចំណូល ២០១៩-២០២៣

*ស្ថិតក្នុងបរិការណ៍សុខសន្តិភាព, ស្ថិរភាពនយោបាយ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចប្រកបដោយកំណើនខ្ពស់ និងរឹងមាំ រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តនូវយុទ្ធសាស្ត្រគៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ ប្រកបដោយជោគជ័យគួរជាទីមោទនៈ ។*



ជាមួយនឹងសមិទ្ធផលនេះ និងការផ្លាស់ប្តូរយ៉ាងលឿននៃរចនាសម្ព័ន្ធសេដ្ឋកិច្ច- សង្គមកម្ពុជា, រាជរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធសាស្ត្រគៀរគរចំណូល២០១៩-២០២៣ ដើម្បីបន្តកែទម្រង់ជាយុទ្ធសាស្ត្រមួយដំណាក់កាលទៀត ក្នុងការលើកកម្ពស់សមត្ថភាពរដ្ឋបាលប្រមូលចំណូល, ការបន្តពង្រឹងអភិបាលកិច្ច, លើកកម្ពស់គុណភាព ,ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការផ្តល់សេវា ព្រមទាំងការរៀបចំគោលនយោបាយសារពើពន្ធ និងមិនមែនសារពើពន្ធ ដើម្បីលើកម្ពស់បរិយាកាសធុរកិច្ច, ពង្រឹងភាពប្រកួតប្រជែង និងជំរុញការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ច។

យុទ្ធសាស្ត្រនេះជាឧបករណ៍ នៃគោលនយោបាយរបស់រាជរដ្ឋាភិបាលមួយយ៉ាងសំខាន់ ក្នុងការបន្តគៀរគរចំណូលប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពដើម្បីបំពេញតម្រូវការហិរញ្ញវត្ថុ របស់រាជរដ្ឋាភិបាលសម្រាប់ការអនុវត្តវិធានការកែទម្រង់ និងការងារអភិវឌ្ឍជាតិក្នុងវិស័យសំខាន់ៗ ដូចដែលបានកំណត់ក្នុង **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤** របស់រាជរដ្ឋាភិបាលកម្ពុជា ។

**យុទ្ធសាស្ត្រគៀរគរចំណូល ២០១៩-២០២៣** មាន **ចក្ខុវិស័យ** ប្រែក្លាយប្រព័ន្ធចំណូលរដ្ឋឱ្យមានលក្ខណៈទំនើបដែលអាចឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍ និងការវិវត្ត នៃរចនាសម្ព័ន្ធសង្គម-សេដ្ឋកិច្ចជាតិ, និងមាន **គោលបំណង** ធ្វើទំនើបភាវូបនីយកម្មរដ្ឋបាល និងគោលនយោបាយចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ ដើម្បីធានាការប្រមូលចំណូលប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពខ្ពស់, រួមចំណែក កែលម្អបរិយាកាសវិនិយោគ,តម្រង់ទិសការវិនិយោគ របស់វិស័យឯកជន , ពង្រឹងភាពប្រកួតប្រជែងនិងជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ចជាតិ។ ទន្ទឹមនេះ យុទ្ធសាស្ត្រនេះកំណត់ **គោលដៅ**÷(១)ប្រមូលចំណូលចរន្តសរុប ឱ្យកើនបានយ៉ាងតិច ០,៣ពិន្ទុភាគរយ នៃ ផ.ស.ស ជាមធ្យមក្នុងមួយឆ្នាំ និង(២)បង្កើនគុណភាពសេវា និងផលិតភាពក្នុងការផ្តល់សេវាគ្រប់ប្រភេទនៃរដ្ឋបាលប្រមូលចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ ដោយប្រកាន់ខ្ជាប់នូវអភិក្រមចំនួនបួនគឺ÷ (១) ធានាចីរភាពកំណើនសេដ្ឋកិច្ច, (២)រក្សាបាននូវចីរភាពចំណូល ដែលឈានទៅដល់កម្រិត ឧត្តមានុពល (Optimal Level), (៣)ធានានូវយុត្តិធម៌ក្នុងការអនុវត្តគោលនយោបាយសារពើពន្ធ និងមិនមែនសារពើពន្ធព្រមទាំងការប្រមូលចំណូល និង(៤)ធានានូវសមធម៌សង្គម ដើម្បីចូលរួមចំណែកបន្ធូរបន្ថយបន្ទុកពន្ធដល់ប្រជាជនមានចំណូលទាប, បង្កើនសុខុមាលភាពប្រជាពលរដ្ឋ និងរក្សាការពារបរិស្ថាន។

ជាក់ស្តែង ការធ្វើទំនើបភាវូបនីយកម្មប្រព័ន្ធចំណូលសារពើពន្ធនឹងផ្តោតលើ÷(១)ការធ្វើវិចារណកម្មគោលនយោបាយដោយឈរលើគោលការណ៍សាមញ្ញភាព, តម្លាភាព, ភាពប្រាកដប្រជា, សមធម៌, យុត្តិធម៌ និងប្រសិទ្ធភាពលើប្រភេទពន្ធដូចជា អាករពិសេស,ពន្ធលើអចលនទ្រព្យ, អាករលើតម្លៃបន្ថែម, អាករសម្រាប់បំភ្លឺសាធារណៈ, ពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គល,ពន្ធលើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងវិធានការគោលនយោបាយសារពើពន្ធផ្សេងៗ និង (២) ទំនើបភាវូបនីយកម្មរដ្ឋបាលសារពើពន្ធ សំដៅកសាងនិងពង្រឹងសមត្ថភាពរដ្ឋបាលសារពើពន្ធក្នុងការឆ្លើយតបឱ្យទាន់ពេលវេលាទៅនឹងការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ច, បច្ចេកវិទ្យា, បរិយាកាសធុរកិច្ច និងឥរិយាបថអ្នក

ជាប់ពន្ធខណៈធានាសម្រេចឱ្យបានគោល-ដៅគោលនយោបាយរបស់រាជរដ្ឋាភិបាលប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពខ្ពស់។

អគ្គនាយកដ្ឋានពន្ធដារ÷ ការធ្វើទំនើបភាវូបនីយកម្មរដ្ឋបាលសារពើពន្ធផ្តោតការពង្រឹងក្របខ័ណ្ឌស្ថាប័ន និងអភិបាលកិច្ច, មុខងារប្រតិបត្តិការស្នូល និងមុខងារគាំទ្រដែលក្នុងនោះ÷

- ការធ្វើទំនើបភាវូបនីយកម្មក្របខ័ណ្ឌស្ថាប័ន និងអភិបាលកិច្ចផ្តោតជាសំខាន់លើការគ្រប់គ្រងលក្ខណៈយុទ្ធសាស្ត្រ និងយន្តការប្រតិតុល្យការ (check and balance) ដោយធានាឯករាជ្យភាពនៃសវនកម្មផ្ទៃក្នុងដើម្បីធានាសុចរិតភាព, វិជ្ជាជីវៈ និងទំនុកចិត្តនៃរដ្ឋបាលសារពើពន្ធ។
- ការធ្វើទំនើបភាវូបនីយកម្មមុខងារប្រតិបត្តិការស្នូល ធ្វើឡើងតាមរយៈការរៀបឡើងវិញនូវដំណើរការការងារ និងធ្វើសមាហរណកម្មរដ្ឋបាលសារពើពន្ធដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលមានលក្ខណៈស្វ័យប្រវត្តិកម្មពេញលេញ និងប្រទាក់ក្រឡាលើគ្រប់មុខងារប្រតិបត្តិការស្នូល (ការចុះបញ្ជី, ការដាក់លិខិតប្រកាស, ការបង់ប្រាក់ពន្ធ, សេវាអ្នក-

*យុទ្ធសាស្ត្រកៀរគរចំណូល ២០១០-២០២៣ មាន **ចក្ខុវិស័យ** ប្រែក្លាយប្រព័ន្ធចំណូលរដ្ឋឱ្យមានលក្ខណៈទំនើបដែលអាចឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍ និងការវិវត្តនៃរចនាសម្ព័ន្ធសង្គម-សេដ្ឋកិច្ចជាតិ និងមាន **គោលដៅ** ធ្វើទំនើបភាវូបនីយកម្មរដ្ឋបាល និងគោលនយោបាយចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ*

ជាប់ពន្ធ, សវនកម្ម, បណ្តឹងតវ៉ានិងបំណុល ) ព្រមទាំងផ្តោតជាចម្បងលើការពង្រឹងគុណភាពសេវាអ្នកជាប់ពន្ធ និងបញ្ញាសវនកម្មត្រួតគ្នា។

- ការធ្វើទំនើបភាវូបនីយកម្មមុខងារគាំទ្រផ្តោតលើការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរដ្ឋបាលសារពើពន្ធ ដែលមានលក្ខណៈស្វ័យប្រវត្តិកម្មពេញលេញ និងប្រទាក់ក្រឡា, យុទ្ធសាស្ត្រអភិវឌ្ឍន៍ធនធានមនុស្សនិងប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃសមិទ្ធកម្មការងារ។

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា÷ ការធ្វើទំនើបភាវូបនីយកម្មរដ្ឋបាលសារពើពន្ធផ្តោតលើ កិច្ចសម្រួលពាណិជ្ជកម្ម, ការកែលម្អ និងពង្រឹងអភិបាលកិច្ច និងការគ្រប់គ្រងបែបយុទ្ធសាស្ត្រដែលក្នុងនោះ÷

- កិច្ចសម្រួលពាណិជ្ជកម្មសំដៅជួយកាត់បន្ថយចំណាយ និងពេលវេលារបស់ធុរជនក្នុងការបំពេញកាតព្វកិច្ច គយសម្រាប់ការធ្វើពាណិជ្ជកម្មអន្តរជាតិ។
- ការកែលម្អ និងពង្រឹងអភិបាលកិច្ច មានគោលបំណងលើកកម្ពស់អនុលោមភាព និងធានាបាននូវចីរភាពចំណូលតាមរយៈការពង្រឹងការងារ សវនកម្មក្រោយបញ្ចេញទំនិញ និងពង្រឹងការងារបង្ការ និងបង្ក្រាបបទល្មើសគយ។
- ការគ្រប់គ្រងបែបយុទ្ធសាស្ត្រ មានគោលបំណងបន្តពង្រឹងការគ្រប់គ្រងជាយុទ្ធសាស្ត្រនៃប្រភពចំណូលគយ និងអភិវឌ្ឍធនធានមនុស្សទាំងបរិមាណ និងគុណភាព ដើម្បីឆ្លើយតបទៅនឹងតម្រូវការ នៃរចនាសម្ព័ន្ធថ្មី និងចូលរួមធានាចីរភាពចំណូល។

ជារួមឯកសារយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ ផ្តោតសំខាន់លើការកំណត់វិធានការដែលមានចរិតជាយុទ្ធសាស្ត្រ និងកែទម្រង់ និងកំណត់សូចនាករសមិទ្ធកម្មគន្លឹះសំខាន់ៗដើម្បីងាយស្រួលក្នុងការតាមដាន និងវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តវិធានការទាំងនោះ៕■

*រៀបចំដោយ÷ ក្រុមការងារកែទម្រង់នៃអគ្គនាយកដ្ឋានគោលនយោបាយ*



# វិសាលភាពស្ថាប័ននៃប្រព័ន្ធស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល
## (Institutional Coverage of Government Finance Statistics)

*ដើម្បីអនុញ្ញាតឱ្យការរៀបចំស្ថិតិ និងការប្រើប្រាស់ស្ថិតិ មានលក្ខណៈជាប្រព័ន្ធប្រកបដោយសង្គតិភាព ដែលអាចប្រៀបធៀបបានជាសកល ប្រព័ន្ធស្ថិតិម៉ាក្រូសេដ្ឋកិច្ច បានកំណត់វិសាលភាពសកម្មភាព ឬព្រឹត្តិការណ៍សេដ្ឋកិច្ច ជាពីរផ្នែកសំខាន់ៗគឺ សេដ្ឋកិច្ចក្នុងស្រុក និងសេដ្ឋកិច្ចក្រៅស្រុក (Rest of the world) ដោយឈរលើមូលដ្ឋានវិធីសាស្ត្រស្ថិតិ។*

រចនាសម្ព័ន្ធនៃវិសាលភាពស្ថាប័ននៃប្រព័ន្ធស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាលមានដូចខាងក្រោម




ដើម្បីគាំទ្រនិងលើកកម្ពស់ប្រសិទ្ធភាពការវិភាគ និងការសម្រេចចិត្តគោលនយោបាយ ការរៀបចំស្ថិតិសេដ្ឋកិច្ចក្នុងស្រុកត្រូវបានបែងចែកជាវិស័យ និងអនុវិស័យសំខាន់ៗដោយផ្អែកលើទិដ្ឋភាពវិស័យសាធារណៈ និងវិស័យឯកជនដូចមានក្នុងរចនាសម្ព័ន្ធខាងលើ។ ប្រព័ន្ធស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល(GFS) ជាប្រព័ន្ធមួយដែលអាចផ្តល់នូវព័ត៌មានលម្អិតសំខាន់ៗនៃវិស័យសាធារណៈដែលគាំទ្រដល់ប្រសិទ្ធភាពនៃដំណើរការវិភាគសារពើពន្ធ (Fiscal Analysis) ក្នុងវិស័យរដ្ឋាភិបាល ឬវិស័យសាធារណៈ ឬឥទ្ធិពលនៃវិស័យសាធារណៈចំពោះការអភិវឌ្ឍសេដ្ឋកិច្ច។ ប្រព័ន្ធស្ថិតិនេះ មានវិសាលភាពគ្របដណ្តប់វិស័យរដ្ឋាភិបាលនិងវិស័យសាជីវកម្មសាធារណៈ។

### ១.វិស័យរដ្ឋាភិបាលទូទៅ

វិស័យរដ្ឋាភិបាលទូទៅសំដៅទៅលើគ្រប់អង្គភាព ឬស្ថាប័នសាធារណៈដែលបង្កើតឡើងដោយដំណើរការនយោបាយ (Political Process) បំពេញសកម្មភាពស្នូលរបស់ខ្លួនក្នុងការផ្តល់សេវាសាធារណៈដោយមិនផ្អែកលើគោលការណ៍ ឬតម្លៃទីផ្សារ (Non-Market Producer) និងគ្រប់គ្រងដោយរដ្ឋាភិបាល។ អង្គភាពឬស្ថាប័នទាំងនោះរួមមាន ស្ថាប័នអង្គនីតិបញ្ញត្តិស្ថាប័នអង្គនីតិប្រតិបត្តិ និងស្ថាប័នតុលាការ ឬស្ថាប័នដែលបំពេញមុខងារពិសេសណាមួយក្នុងវិស័យ ឬផ្នែកណាមួយជាក់លាក់នៃរដ្ឋាភិបាលកម្រិតថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ ( ឬថ្នាក់តំបន់)។ វិស័យរដ្ឋាភិបាលមានវិសាលភាពគ្របដណ្តប់លើក្រសួង ស្ថាប័ន

ថ្នាក់ជាតិ, គ្រឹះស្ថានសាធារណៈរដ្ឋបាល, បេឡាជាតិរបបសន្តិសុខសង្គម, និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំង ៣កម្រិត (រដ្ឋបាលរាជធានី ខេត្ត, រដ្ឋបាលក្រុង ស្រុក ខណ្ឌ, និងរដ្ឋបាលឃុំ សង្កាត់)។

## ១.១. រដ្ឋបាលថ្នាក់ជាតិ

យោងទៅតាមព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៨ ស្តីពី "ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ" រដ្ឋបាលថ្នាក់ជាតិសំដៅដល់ក្រសួង ស្ថាប័នអង្គភាពសាធារណៈប្រហាក់ប្រហែលនិងមន្ទីរជំនាញក្រោមឱវាទ។ រដ្ឋបាលថ្នាក់ជាតិ ផ្តល់សេវាសាធារណៈដោយមិនផ្អែកលើតម្លៃទីផ្សារ គ្រប់គ្រងផ្ទាល់ដោយរដ្ឋាភិបាល។ ការចងក្រងស្ថិតិសម្រាប់រដ្ឋបាលថ្នាក់ជាតិជួយគាំទ្រ និងបង្កើនប្រសិទ្ធភាពវិភាគតាក់តែងគោលនយោបាយ និងឥទ្ធិពលនៃការអនុវត្តគោលនយោបាយ។ ក្នុងប្រព័ន្ធស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល បានបែងចែករដ្ឋបាលថ្នាក់ជាតិបានបែងចែកជាពីរប្រភេទគឺ រដ្ឋបាលថ្នាក់ជាតិមិនរួមបញ្ចូលគ្រឹះស្ថានសាធារណៈរដ្ឋបាល និងគ្រឹះស្ថានសាធារណៈរដ្ឋបាល។

**ក.រដ្ឋបាលថ្នាក់ជាតិមិនរួមបញ្ចូលគ្រឹះស្ថានសាធារណៈរដ្ឋបាល** (Budgetary Central Government)៖

ស្ថាប័ន អង្គភាពដែលស្ថិតនៅក្នុងរដ្ឋបាលនេះ មិនមានសិទ្ធិទទួលបានការកាន់កាប់ទៅលើទ្រព្យសកម្ម, ទទួលទ្រព្យអកម្ម (ខ្ចីបំណុល) និងធ្វើប្រតិបត្តិការផ្ទេរក្នុងរបស់ខ្លួននោះទេ។ ក្នុងន័យនេះរាល់ប្រតិបត្តិការចំណូល និងចំណាយរបស់ស្ថាប័នទាំងនេះត្រូវស្ថិតនៅក្រោមការធ្វើនិយ័តកម្មរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បំពេញមុខងារជាសេនាធិការរបស់រាជរដ្ឋាភិបាល។ ស្ថាប័នឬអង្គភាពទាំងនេះបំពេញមុខងារក្នុងអំណាចទាំង៣ (អំណាចនីតិបញ្ញត្តិ នីតិប្រតិបត្តិ និងអំណាចតុលាការ)។ ក្រសួង ឬស្ថាប័នទាំងនោះរួមមាន ព្រះបរមរាជវាំង, រដ្ឋសភា, ព្រឹទ្ធសភា, ក្រុមប្រឹក្សាធម្មនុញ្ញ, ទីស្តីការគណៈរដ្ឋមន្ត្រី, រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល, ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, ក្រសួងការពារជាតិ, ក្រសួងមហាផ្ទៃ, ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច, ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងព័ត៌មាន, ក្រសួងសុខាភិបាល, ក្រសួងរ៉ែ និងថាមពល, ក្រសួងផែនការ, ក្រសួងពាណិជ្ជកម្ម, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, ក្រសួងបរិស្ថាន, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, ក្រសួងធម្មការ និងសាសនា, ក្រសួងកិច្ចការនារី, ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងយុត្តិធម៌, តុលាការកំពូល, សាលាឧទ្ធរណ៍, ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម, ក្រសួងទេសចរណ៍, ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ក្រសួងធនធានទឹក និងឧតុនិយម, គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត, អាជ្ញាធរសវនកម្មជាតិ, ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ, អង្គភាពប្រឆាំងអំពើពុករលួយ, ក្រសួងមុខងារសាធារណៈ, ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងមន្ទីរក្រោមឱវាទ។

**ខ.គ្រឹះស្ថានសាធារណៈរដ្ឋបាល** (Extra Budgetary Central Government) ៖

គ្រឹះស្ថានសាធារណៈរដ្ឋបាលបង្កើតឡើងដោយរដ្ឋាភិបាលទទួលបន្ទុកផ្តល់សេវាផ្នែកសាធារណៈមានលក្ខណៈរដ្ឋបាល និងមានថវិកាស្វយ័ត។ យោងទៅតាមព្រះរាជក្រឹត្យលេខ នស/រកត/០៨០១៥/៨៧២ ស្តីពី "លក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល" គ្រឹះស្ថានសាធារណៈរដ្ឋបាល គឺជានីតិបុគ្គលនៃនីតិសាធារណៈដែលទទួលបន្ទុកចម្បងនូវបេសកកម្មផ្នែកសេវាកម្មសាធារណៈ ជាអាទិ៍ សេវាមានលក្ខណៈរដ្ឋបាល សង្គមកិច្ច សុខាភិបាល វប្បធម៌ អប់រំ វិទ្យាសាស្ត្រ និងបច្ចេកទេស។ បេសកកម្មនេះ ត្រូវស្របតាមគោលនយោបាយ និងយុទ្ធសាស្ត្រដែលកំណត់ដោយក្រសួងស្ថាប័នអាណាព្យាបាលបច្ចេកទេស។ គិតត្រឹមចុងឆ្នាំ២០១៨នេះ គ្រឹះស្ថានសាធារណៈរដ្ឋបាលមានដូចតទៅ៖ អាជ្ញា-

| វិស័យរដ្ឋាភិបាលទូទៅ | វិស័យសាជីវកម្មមិនមែនហិរញ្ញវត្ថុ | វិស័យសាជីវកម្មហិរញ្ញវត្ថុ | វិស័យគ្រួសារ | ស្ថាប័នមិនរកប្រាក់ចំណេញដែលបម្រើដល់វិស័យគ្រួសារ |
|---|---|---|---|---|
| រដ្ឋបាលថ្នាក់ជាតិ | សាជីវកម្មសាធារណៈ | សាជីវកម្មសាធារណៈ | ឯកជន | ឯកជន |
| រដ្ឋបាលថ្នាក់ក្រោមជាតិ | សាជីវកម្មឯកជន | សាជីវកម្មឯកជន | | |

វិស័យសាធារណៈ

*វិសាលភាពនៃសិទ្ធិអំណាចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាទូទៅមានកម្រិតទាបជាងរដ្ឋបាលថ្នាក់ជាតិ ក្នុងន័យនេះពួកគេអាច ឬមិនអាចមានសិទ្ធិប្រមូលពន្ធលើអង្គភាព ស្ថាប័ននៅក្នុងតំបន់នោះឡើយ ។*

ធរអប្សរា, មន្ទីរពេទ្យកាល់ម៉ែត, វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា, វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា, វិទ្យាស្ថានសុខាភិបាលកងយោធពលខេមរភូមិន្ទ, សាលាជាតិកសិកម្មកំពង់ចាម, មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត, អាជ្ញាធរជាតិដើម្បីការពារនិងអភិវឌ្ឍរមណីយដ្ឋាន នៃប្រាសាទព្រះវិហារ, បេឡាជាតិអតីតយុទ្ធជន ,មជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល, សាកលវិទ្យាល័យជាតិគ្រប់គ្រង, មន្ទីរពេទ្យកុមារជាតិ, វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា, បេឡាជាតិរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល, មន្ទីរពេទ្យព្រះអង្គឌួង, វិទ្យាស្ថានជាតិសុខភាពសាធារណៈ ,មន្ទីរពេទ្យព្រះកុសុមៈ, សាលាជាតិកសិកម្មព្រែកលៀប, មូលនិធិជនពិការ, រាជបណ្ឌិត្យសភាកម្ពុជា, សាកលវិទ្យាល័យភូមិន្ទកសិកម្ម ,សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល, និយ័តករទូរគមនាគមន៍កម្ពុជា, គ្រឹះស្ថានអង្គរ, វិទ្យាស្ថានប្រែសណីយ៍ និងទូរគមនាគមន៍, គ្រឹះស្ថានសំបូរព្រៃគុក, ទីភ្នាក់ងារបញ្ជាក់ចំណាយសេវាសុខាភិបាល។ គ្រឹះស្ថានទាំងអស់នេះត្រូវបានបង្កើតដោយអនុក្រឹត្យ តាមសំណើរួមរបស់ក្រសួង-ស្ថាប័ន អាណាព្យាបាលបច្ចេកទេស និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជាក្រសួងអាណាព្យាបាលហិរញ្ញវត្ថុ។ ទន្ទឹមនេះ គ្រឹះស្ថានមួយចំនួនត្រូវពិនិត្យ និងរៀបចំព្រះរាជក្រឹត្យ ឬអនុក្រឹត្យស្តីពីការបង្កើតគ្រឹះស្ថាន ឱ្យមានសង្គតិភាពជាមួយខ្លឹមសារ នៃព្រះរាជក្រឹត្យលេខ សន/រកត/០៥១៨/៥៩០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨។ ក្នុងមាត្រាទី៤៩ថ្មី នៃព្រះរាជក្រឹត្យនេះ បានចែងថា “គ្រឹះស្ថាន ឬអង្គភាពរដ្ឋទាំងឡាយណាដែលអនុវត្តគោលនយោបាយរបស់អាណាព្យាបាលបច្ចេកទេស និងទទួលបានចំណូលពីការផ្តល់សេវាសាធារណៈជាប្រចាំ ត្រូវប្រែក្លាយខ្លួនជាគ្រឹះស្ថានសាធារណៈរដ្ឋបាលជាចាំបាច់”។ បេឡាជាតិរបបសន្តិសុខសង្គម (NSSF) ដែលមានភារៈកិច្ចក្នុងការធានានូវសុខុមាលភាព និងការការពារអាយុជីវិតរបស់បុគ្គលិកកម្ពុជា ខណៈពេលដែលមានការផ្តោតទៅលើការផ្តល់នូវសេវាធានារ៉ាប់រងការងារដល់កម្មករ។ ក្នុងប្រព័ន្ធស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល (GFS) បេឡាជាតិរបបសន្តិសុខសង្គមអាចទទួលស្គាល់ជាវិស័យមួយដាច់ដោយឡែកពីរដ្ឋបាលថ្នាក់ជាតិ ដែលស្ថិតក្នុងវិស័យរដ្ឋាភិបាលទូទៅ។

### ១.២. រដ្ឋបាលថ្នាក់ក្រោមជាតិ

យោងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០០៨ មាត្រា៤ បានចែងថា “រដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅដល់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ដែលស្ថិតិក្រោមដែលសមត្ថកិច្ចរបស់ក្រុមប្រឹក្សានីមួយៗ។ រដ្ឋបាលថ្នាក់ក្រោមជាតិ ជាស្ថាប័ន ឬអង្គភាពដែលមានសិទ្ធិអំណាចធ្វើវិមជ្ឈការ និងវិសហមជ្ឈការទៅលើអំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ ដែលមានវិសាលភាពគ្របដណ្តប់ទៅលើតំបន់ភូមិសាស្ត្រ



នីមួយៗសម្រាប់គោលបំណងរដ្ឋបាល និងនយោបាយ។ វិសាលភាពនៃសិទ្ធិអំណាចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិជាទូទៅមានកម្រិតទាបជាងរដ្ឋបាលថ្នាក់ជាតិ។ រដ្ឋបាលថ្នាក់ក្រោមជាតិ ជាធម្មតាពឹងផ្អែកខ្លាំងលើការឧបត្ថម្ភអំណោយ (ផ្ទេរ) ពីរដ្ឋបាលថ្នាក់ជាតិ ដើម្បីអនុវត្តមុខងារជាភ្នាក់ងាររបស់រដ្ឋាភិបាល និងក្រសួង ស្ថាប័នថ្នាក់ជាតិ ដែលមានរចនាសម្ព័ន្ធដូចខាងក្រោម៖




## ២. វិស័យសាជីវកម្មសាធារណៈ

វិស័យសាជីវកម្មសាធារណៈ សំដៅដល់អង្គភាព ស្ថាប័នសាធារណៈ ដែលគ្រប់គ្រងដោយវិស័យរដ្ឋាភិបាលផ្តល់(ផ្គត់ផ្គង់)ទំនិញ និងសេវាកម្មផ្អែកលើថ្លៃទីផ្សារ (Market Producer)។ វិស័យសាជីវកម្មសាធារណៈ ត្រូវបានបែងចែកជាពីរផ្នែកគឺ៖ ស្ថាប័នសាធារណៈមានលក្ខណៈហិរញ្ញវត្ថុ និងស្ថាប័នសាធារណៈមានលក្ខណៈមិនមែនហិរញ្ញវត្ថុ។ យោងទៅតាមព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ស្តីពី ច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ បានចែងថា “សហគ្រាសសាធារណៈគឺជាសហគ្រាសដែលមានដើមទុនទាំងអស់ ឬភាគច្រើនជារបស់រដ្ឋ(រដ្ឋកាន់កាប់ដោយប្រយោលលើសពី៥១ភាគរយនៃដើមទុនក្រុមហ៊ុន ឬសិទ្ធិបោះឆ្នោត) ដែលមានបេសកកម្មបង្ករលក្ខណៈដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច ជាអាទិ៍ ក្នុងការបង្កើនតម្លៃធនធានធម្មជាតិ និងការបង្កើតអាជីព។

### ២.១. វិស័យសាជីវកម្មសាធារណៈមានលក្ខណៈហិរញ្ញវត្ថុ

វិស័យសាជីវកម្មសាធារណៈមានលក្ខណៈហិរញ្ញវត្ថុ (Financial Corporation) បានចូលរួមចំណែកយ៉ាងសកម្មក្នុងការបម្រើសេវាកម្មហិរញ្ញវត្ថុក្នុងវិស័យសាធារណៈ ដែលក្នុងនោះមាន សេវាធនាគារ, សេវាធានារ៉ាប់រង, សេវាមូលនិធិសោធន, និងសេវាប្រាក់បញ្ញើផ្សេងៗ។ ធនាគារជាតិនៃកម្ពុជា, ធនាគារអភិវឌ្ឍន៍ជនបទ, ក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា, កាមិនគូ និងស្ថាប័នប្រហាក់ប្រហែលមួយចំនួនទៀត
ត្រូវបាន
ទទួលស្គាល់ជាសមាសធាតុនៃវិស័យសាជីវកម្មសាធារណៈមានលក្ខណៈហិរញ្ញវត្ថុក្នុងប្រព័ន្ធស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល។

### ២.២. វិស័យសាជីវកម្មសាធារណៈមានលក្ខណៈមិនមែនហិរញ្ញវត្ថុ

វិស័យសាជីវកម្មសាធារណៈមានលក្ខណៈមិនមែនហិរញ្ញវត្ថុ (Nonfinancial Corporation) មានតួនាទីចម្បងក្នុងការផ្គត់ផ្គង់ទំនិញ និងសេវា មិនមែនហិរញ្ញវត្ថុនៅក្នុងទីផ្សារ។ ស្ថាប័នមួយចំនួននៃវិស័យនេះទទួលបានថវិកាឧបត្ថម្ភចំណូល (អំណោយ) ពីរដ្ឋាភិបាល។ ស្ថាប័នសាធារណៈដែលស្ថិតក្នុងវិស័យសាជីវកម្មសាធារណៈមានលក្ខណៈមិនមែនហិរញ្ញវត្ថុមានដូចជា៖ អគ្គិសនីកម្ពុជា, រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ, រដ្ឋាករទឹកស្វយ័តខេត្តសៀមរាប, ទូរគមនាគមន៍កម្ពុជា, កំពង់ផែស្វយ័តក្រុងភ្នំពេញ, កំពង់ផែស្វយ័តក្រុងព្រះសីហនុ និងអង្គភាពប្រហាក់ប្រហែលមួយចំនួនទៀតដែលកំណត់ដោយច្បាប់។ ៕■

*រៀបចំដោយ៖ ក្រុមការងារកែទម្រង់នៃអគ្គនាយកដ្ឋានគោលនយោបាយ*

# ការត្រួតពិនិត្យ ការរៀបចំ និងការកំណត់សូចនាករសមិទ្ធកម្មគន្លឹះ ផែនការសកម្មភាពដំណាក់កាលទី៣ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

*អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) ដែលជាស្ថាប័នគន្លឹះក្នុងការសម្របសម្រួលការរៀបចំ និងអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានសម្របសម្រួលជាមួយអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍ ដើម្បីបន្តរៀបចំផែនការសកម្មភាព ដំណាក់កាលទី៣ ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២០ ដែលមានគោលដៅសម្រេចឱ្យបាន "**ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**" ។*

មូលដ្ឋានសម្រាប់រៀបចំផែនការសកម្មភាពឆ្នាំ ២០១៩-២០២០ រួមមាន÷ (១)ផែនការសកម្មភាពរួម ដំណាក់កាលទី៣ ឆ្នាំ ២០១៨-២០២០ដែលមានស្រាប់, (២) យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា ឆ្នាំ២០១៨-២០២៥, (៣) ឯកសារស្រាវជ្រាវស្ដីពីកត្តាកំណត់ជោគជ័យ ក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, (៤) របាយការណ៍នៃក្រុមការងារវាយតម្លៃឯករាជ្យ (EAP), (៥) របាយការណ៍វាយតម្លៃអំពីក្របខ័ណ្ឌចំណាយសាធារណៈ និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា ឆ្នាំ២០១៥ (PEFA) (៦) របាយការណ៍ស្ដីពីការត្រួតពិនិត្យការអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(FMIS)របស់មូលនិធិរូបិយវត្ថុអន្តរជាតិ, (៧) ក្របខ័ណ្ឌលទ្ធផល ដែលមាននៅក្នុងកិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណងរវាងរាជរដ្ឋាភិបាល និងសហភាពអ៊ឺរ៉ុប (EU) និង(៨) កិច្ចព្រមព្រៀងហិរញ្ញប្បទានរវាងរាជរដ្ឋាភិបាល និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។

ក្នុងទិសដៅធានាដល់ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការអនុវត្តផែនការសកម្មភាពខាងលើ **អ.គ.ហ.** ក៏បានសម្របសម្រួលជាមួយអគ្គនាយកដ្ឋាននិងអង្គភាពនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងជាមួយក្រសួង-ស្ថាប័ននានា ដើម្បីរៀបចំជាសូចនាករសមិទ្ធកម្មគន្លឹះដូចខាងក្រោមៈ




១. សូចនាករសមិទ្ធកម្មគន្លឹះ សម្រាប់អគ្គនាយកដ្ឋាន និងអង្គភាពនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# សូចនាករសមិទ្ធកម្មគន្លឹះ នៃ
# ផែនការសកម្មភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ២០១៩-២០២០

| សូចនាករសមិទ្ធកម្មគន្លឹះ(KPI) | បន្ទាត់គោលឆ្នាំ២០១៧-២០១៨ | គោលដៅ ២០១៩ | គោលដៅ ២០២០ |
|---|---|---|---|
| ១.១. ចំណូលក្នុងស្រុករក្សាបានក្នុងរង្វង់ +/-៥% ធៀបនឹងគោលដៅដែលបានអនុម័តក្នុងច្បាប់ហិរញ្ញវត្ថុ | +/-៥% ធៀបនឹងគោលដៅដែលបានអនុម័តក្នុងច្បាប់ហិរញ្ញវត្ថុ (ចំណូល ធៀបនឹងគោលដៅសម្រេចបាន ១០៦,០៩%តួលេខឆ្នាំ២០១៧) | +/-៥% ធៀបនឹងគោលដៅដែលបានអនុម័តក្នុងច្បាប់ហិរញ្ញវត្ថុ | +/-៥% ធៀបនឹងគោលដៅដែលបានអនុម័តក្នុងច្បាប់ហិរញ្ញវត្ថុ |
| ១.២. ចំណូលចរន្តធៀបនឹង ផ.ស.ស មានកំណើនប្រមាណ ០,៣ ពិន្ទុភាគរយនៃ ផ.ស.ស ក្នុងមួយឆ្នាំ | ចំណូលចរន្តសម្រេចបាន ១៧,៥០% នៃ ផ.ស.ស ឆ្នាំ២០១៨ | ចំណូលចរន្តធៀបនឹង ផ.ស.ស មានកំណើនប្រមាណ ០,៣ ពិន្ទុភាគរយនៃ ផ.ស.ស ក្នុងមួយឆ្នាំ | ចំណូលចរន្តធៀបនឹង ផ.ស.ស មានកំណើនប្រមាណ០,៣ពិន្ទុភាគរយនៃផ.ស.ស ក្នុងមួយឆ្នាំ |
| ១.៣. បំណុលកកស្ទះ (រយៈពេល ៦០ ថ្ងៃ) ត្រូវកម្រិតមិនឱ្យលើសពី ២% នៃ ចំណាយសរុប | បំណុលកកស្ទះទាបជាង២%នៃចំណាយ សរុប (គិតចាប់ តាំងពីអាណត្តិចូលរតនាគាជាតិក្នុងរយៈពេល៦០ថ្ងៃ និងមិនរួមបញ្ចូលទាំងបំណុលមរតក) | បំណុលកកស្ទះត្រូវកម្រិតមិនឱ្យលើសពី ២%នៃ ចំណាយសរុប | បំណុលកកស្ទះត្រូវកម្រិតមិនឱ្យលើសពី ២%នៃ ចំណាយសរុប |
| ១.៤. ស្ថានភាពចំណាយមិនត្រូវតិចជាងៈ ត្រីមាសទី ១: ១៥%, ត្រីមាសទី ២:៤៥%, ត្រីមាសទី ៣:៦៧% និង ត្រីមាសទី ៤:៩៦% | ត្រីមាសទី១: ១៥%<br>ត្រីមាសទី២: ៤៥%<br>ត្រីមាសទី៣: ៦៧%<br>ត្រីមាសទី៤: ៩៦% | ត្រីមាសទី១: ១៥%<br>ត្រីមាសទី២: ៤៥%<br>ត្រីមាសទី៣: ៦៧%<br>ត្រីមាសទី៤: ៩៦% | ត្រីមាសទី១: ១៥%<br>ត្រីមាសទី២: ៤៥%<br>ត្រីមាសទី៣: ៦៧%<br>ត្រីមាសទី៤: ៩៦% |
| ១.៥.រាល់ផ្នែកសំខាន់ៗ នៃ ចំណូល និងចំណាយសាធារណៈ ត្រូវបានដាក់បញ្ចូលក្នុងគណនីរដ្ឋ ថវិកាជាតិ | -លទ្ធផលចំណាយធៀបនឹងថវិកាអនុម័តមិនត្រូវតិចជាង÷<br>➢ បៀវត្ស: ៩៨%<br>➢ ទំនិញ/សេវា:៩៥%<br>➢ មូលធនៈ ៨៥% | -លទ្ធផលចំណាយធៀបនឹងថវិកាអនុម័តមិនត្រូវតិចជាង÷<br>➢ បៀវត្ស: ៩៨%<br>➢ ទំនិញ/សេវា:៩៥%<br>➢ មូលធនៈ ៨៥% | -លទ្ធផលចំណាយធៀបនឹងថវិកាអនុម័តមិនត្រូវតិចជាង÷<br>➢ បៀវត្ស: ៩៨%<br>➢ ទំនិញ/សេវា:៩៥%<br>➢ មូលធនៈ ៨៥% |

| សូចនាករសមិទ្ធកម្មគន្លឹះ(KPI) | បន្ទាត់គោលឆ្នាំ ២០១៧-២០១៨ | គោលដៅ ២០១៩ | គោលដៅ ២០២០ |
|---|---|---|---|
| **១.៦. បំណុលសារពើពន្ធ ត្រូវទារសរុប ត្រូវបានកាត់បន្ថយ** | -៩០% នៃចំណូលពន្ធ, ស្តង់ដារអន្តរជាតិ ៣០% | -រៀបចំចំណាត់ថ្នាក់នៃបំណុល<br>-កំណត់បំណុលដែលអាចប្រមូលបាន និងមិនអាចប្រមូលបាន<br>-ដាក់បញ្ចូលក្នុងប្រព័ន្ធគ្រប់គ្រងនិងប្រមូលបំណុលពន្ធដារថ្មី | យ៉ាងហោច ១៥% នៃបំណុលថ្មីដែលកើតឡើងក្នុងឆ្នាំចរន្ត ត្រូវបានបន្ថយ |
| **១.៧. បំណុលមិនមែនសារពើពន្ធត្រូវទារសរុប ត្រូវបានកាត់បន្ថយ** | ពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងបំណុលមិនមែនសារពើពន្ធ | -សេចក្តីព្រាងប្រកាសស្តីពីវិធាន និងនីតិវិធីនៃការតាមដាន ការតឹងទារនិងការជម្រះ បញ្ជីនៃបំណុលមិនមែនសារពើពន្ធត្រូវបានរៀបចំ | -ប្រកាសស្តីពីវិធាន និងនីតិវិធីនៃការតាមដាន ការតឹងទារ និងការជម្រះបញ្ជីនៃបំណុលមិនមែនសារពើពន្ធ ត្រូវបានដាក់ឱ្យអនុវត្ត<br>-បំណុលរ៉ាំរ៉ៃ និងមិនរ៉ាំរ៉ៃ ត្រូវបានកំណត់ |
| **១.៨. ក្របខ័ណ្ឌសម្រាប់ការគ្រប់ គ្រងគម្រោងវិនិយោគសាធារណៈ (ទស្សនាទាន និងអនុក្រឹត្យ) ត្រូវបានរៀបចំ និង ដាក់ឱ្យអនុវត្ត** | --- | ១.ក្របខ័ណ្ឌទស្សនាទានពីការគ្រប់-គ្រងការវិនិយោគសាធារណៈឆ្នាំ ២០១៩-២០២៥<br>២.អនុក្រឹត្យគោលស្តីពីការគ្រប់គ្រងគម្រោង វិនិយោគសាធារណៈ (ថវិកាជាតិ ថវិកាដៃគូនិង យន្តការ PPP) | ១.អនុក្រឹត្យស្តីពីការដាក់ឱ្យប្រើប្រាស់នីតិវិធីអនុវត្តស្តង់ដារសម្រាប់ការគ្រប់គ្រងការវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស<br>២.អនុក្រឹត្យស្តីពីការដាក់ឱ្យប្រើប្រាស់នីតិវិធីអនុវត្តស្តង់ដារសម្រាប់ការគ្រប់គ្រងការវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូ រវាងរដ្ឋ និងឯកជន |
| **<u>២.១.</u> ចំណាត់ថ្នាក់មុខងារ និងចំណាត់ភូមិសាស្ត្រត្រូវបានកែលម្អ និងអនុត្ត** | --- | ប្រកាសកែសម្រួល ចំណាត់ថ្នាក់ទាំង ៧ ត្រូវបានរៀបចំ | ចំណាត់ថវិកាទាំង៧ ត្រូវបានដាក់ឱ្យអនុវត្ត |
| **២.២. -ស្តង់ដាគណនេយ្យសាធារណៈកម្ពុជាមូលដ្ឋានសាច់ប្រាក់ត្រូវបានកំណត់<br>- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍គណនេយ្យសាធារណៈកម្ពុជាត្រូវបានរៀបចំ** | --- | -សេចក្តីព្រាងនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍គណ នេយ្យសាធារណៈកម្ពុជា ត្រូវបានរៀបចំរួចរាល់សម្រាប់ប្រឹក្សាពិគ្រោះយោបល់<br>-សេចក្តីព្រាងក្របខ័ណ្ឌរាយការណ៍ហិរញ្ញវត្ថុសាធារណៈកម្ពុជា ត្រូវបានរៀបចំ | -ស្តង់ដាគណនេយ្យសាធារណៈកម្ពុជាមូលដ្ឋានសាច់ប្រាក់ត្រូវបានធ្វើការបណ្តុះបណ្តាល<br>-ផែនការយុទ្ធសាស្ត្រអភិវឌ្ឍគណនេយ្យសាធារណៈកម្ពុជាត្រូវបានធ្វើការផ្សព្វផ្សាយ<br>-ក្របខណ្ឌរាយការណ៍ហិរញ្ញវត្ថុ |

| សូចនាករសមិទ្ធកម្មគន្លឹះ(KPI) | បន្ទាត់គោលឆ្នាំ ២០១៧-២០១៨ | គោលដៅ ២០១៩ | គោលដៅ ២០២០ |
|---|---|---|---|
| - ក្របខណ្ឌរាយការណ៍ហិរញ្ញវត្ថុសាធារណៈកម្ពុជាត្រូវបានកំណត់ | | -ស្តង់ដាគណនេយ្យសាធារណៈកម្ពុជាមូលដ្ឋានសាច់ប្រាក់ត្រូវបានធ្វើការបណ្តុះបណ្តាល | សាធារណៈកម្ពុជាត្រូវបានដាក់ពិគ្រោះយោបល់ និងអនុម័ត |
| ២.៣.តារាងឧបសម្ព័ន្ធចំណូល ចំណាយសម្រាប់រៀបចំច្បាប់ទូទាត់ប្រចាំឆ្នាំ ២០១៨ អាចផលិតសាកល្បងចេញពីប្រព័ន្ធ FMIS | តារាងឧបសម្ព័ន្ធចំណូលចំណាយ សម្រាប់រៀបចំច្បាប់ទូទាត់ប្រចាំឆ្នាំ ២០១៧ រៀបចំតាម Excel ដោយផ្អែកលើទិន្នន័យប្រព័ន្ធ FMIS | របាយការណ៍អនុវត្តចំណូល ថវិកា (តារាង ក) និងរបាយការណ៍អនុវត្តចំណាយ(តារាងខ,គ) នៅក្នុងប្រព័ន្ធ FMIS សម្រាប់ច្បាប់ទូទាត់ ត្រូវបានរៀបចំ និង ដាក់ឱ្យអនុវត្ត | របាយការណ៍អនុវត្តចំណូលថវិកានៅក្នុងប្រព័ន្ធ FMIS សម្រាប់ច្បាប់ទូទាត់ត្រូវបានដាក់ឱ្យអនុវត្តពេញលេញ |
| ២.៤. ក្រសួង-ស្ថាប័នចំនួន ២ ត្រូវបានធ្វើ Business Process Streamline សម្រាប់ការអនុវត្តប្រព័ន្ធស្វ័យប្រវត្តិកម្មសាកល្បងនៃការអនុវត្តថវិកាលើការទូទាត់ត្រង់ | --- | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានធ្វើ Business Process Streamline សម្រាប់ការអនុវត្តប្រព័ន្ធស្វ័យ ប្រវត្តិកម្មសាកល្បងនៃការអនុវត្តថវិកាលើការទូទាត់ត្រង់ | ក្រសួងថ្មីចំនួនមួយបន្ថែមទៀតត្រូវបានធ្វើ Business Process Streamline សម្រាប់ការអនុវត្តប្រព័ន្ធស្វ័យ ប្រវត្តិកម្មសាកល្បងនៃការអនុវត្តថវិកាលើការទូទាត់ត្រង់ |
| ២.៥.- IPSAS Cash Basis Report ត្រូវរៀបចំលើមូលដ្ឋានប្រព័ន្ធ FMIS<br>-សមាសធាតុ (Item) នៅក្នុងរបាយការណ៍ IPSAS Cash Basis ត្រូវបានកែលម្អដើម្បីឱ្យអនុលោមភាព (Compliance) តាមស្តង់ដារ IPSAS Cash Basis | -របាយការណ៍ IPSAS Cash Basis ឆ្នាំ២០១៦ ត្រូវបានសាកល្បងរៀបចំ<br>-សមាសធាតុចំនួន ៩ នៅក្នុង របាយការណ៍ IPSAS Cash Basis ត្រូវបានវាយតម្លៃថា Non compliance ហើយដែលត្រូវ កែលម្អឱ្យស្របតាមស្តង់ដារ IPSAS Cash Basis | -របាយការណ៍ IPSAS Cash Basis ឆ្នាំ២០១៧ ត្រូវបាន រៀបចំលើមូលដ្ឋានប្រព័ន្ធ FMIS<br>-សមាសធាតុចំនួនបី នៅក្នុង របាយការណ៍ IPSAS Cash Basis ត្រូវបានកែលម្អដើម្បីឱ្យ compliance តាមស្តង់ដារ IPSAS Cash Basis | -របាយការណ៍ IPSAS Cash Basis ឆ្នាំ២០១៨ ត្រូវបាន រៀបចំលើមូលដ្ឋានប្រព័ន្ធ FMIS<br>-សមាសធាតុចំនួនបីបន្ថែមទៀតនៅក្នុងរបាយការណ៍ IPSAS Cash Basis ត្រូវបានកែលម្អដើម្បីឱ្យ compliance តាមស្តង់ដារ IPSAS Cash Basis |

| សូចនាករសមិទ្ធកម្មគន្លឹះ(KPI) | បន្ទាត់គោលឆ្នាំ ២០១៧-២០១៨ | គោលដៅ ២០១៩ | គោលដៅ ២០២០ |
|---|---|---|---|
| ២.៦. ដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងយន្តការតាមដានវាយតម្លៃ | បន្តកែសម្រួលប្រព័ន្ធគ្រប់គ្រងទិន្នន័យបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ | ប្រព័ន្ធគ្រប់គ្រងទិន្នន័យបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រូវបានដាក់ឱ្យអនុវត្តនៅក្រសួងចំនួន១០ | -ប្រព័ន្ធគ្រប់គ្រងទិន្នន័យបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រូវបានដាក់ឱ្យអនុវត្តដាក់នៅគ្រប់ក្រសួង និងរាជធានី-ខេត្ត<br>-របាយការណ៍ត្រួតពិនិត្យតាមដានលើប្រសិទ្ធភាពនៃការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួងស្ថាប័ន ត្រូវបានរៀបចំ |
| ៣.១. សេចក្តីព្រាងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម (MTFF) ត្រូវបានរៀបចំ និងពិភាក្សាក្នុងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ដោយរួមបញ្ចូលទាំងការវិភាគហានិភ័យហិរញ្ញវត្ថុ) | --- | -ឯកសារក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០១៩ តាមទម្រង់ដូចបានរៀបចំកន្លងមក និងជំនួសដោយឯកសារ MTFF ២០២១-២០២៣ | - MTFF រយៈពេលមធ្យម ត្រូវបានពន្យារមួយឆ្នាំទៀតគឺឆ្នាំ ២០២០ និង ត្រូវបន្តកែលម្អបន្ថែមទៀត ។<br>- MTFF អនុវត្តជាផ្លូវការឆ្នាំ ២០២១ (តាមការណែនាំរបស់ឯកឧត្តមរដ្ឋលេខាធិការប្រចាំការ) |
| ៣.២. សេចក្តីព្រាងក្របខ័ណ្ឌថវិការយៈពេលមធ្យម(MTBF) ត្រូវបានរៀបចំ និងពិភាក្សាក្នុងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | --- | -ទស្សនទានក្របខ័ណ្ឌថវិការយៈពេលមធ្យម (MTBF) ត្រូវបានរៀបចំ និងត្រូវបានធ្វើសុពលភាព (Q2) | -ក្របខ័ណ្ឌថវិការយៈពេលមធ្យម (MTBF) ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តសាកល្បង |
| ៣.៣. ការពង្រីកការអនុវត្តថវិកាកម្មវិធីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | រដ្ឋបាលខេត្តចំនួន ១២ ត្រូវបានដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញ | -រដ្ឋបាលខេត្តចំនួន ១៨ ត្រូវបានដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញ | -រដ្ឋបាលខេត្តចំនួន ២៤ ត្រូវបានដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញ |
| ៣.៤. របាយការណ៍អនុវត្តថវិកាកម្មវិធីប្រចាំឆមាស និងប្រចាំឆ្នាំត្រូវបានរៀបចំ | --- | -របាយការណ៍ស្តីពីការពិនិត្យឡើងវិញ និងការកែលម្អ ត្រូវបានរៀបចំ ដោយរំលេច ឱ្យឃើញពីរបកគំហើញ និងអនុសាសន៍នានានិងដាក់ឱ្យអនុវត្ត | របាយការណ៍ស្តីពីការពិនិត្យឡើងវិញ និងការកែលម្អ ត្រូវបានរៀបចំ ដោយរំលេចឱ្យឃើញពី របកគំហើយ និងអនុសាសន៍នានានិងដាក់ឱ្យអនុវត្ត |

| សូចនាករសមិទ្ធកម្មគន្លឹះ(KPI) | បន្ទាត់គោលឆ្នាំ ២០១៧-២០១៨ | គោលដៅ ២០១៩ | គោលដៅ ២០២០ |
|---|---|---|---|
| | | -តាមដានការអនុវត្តថវិកាកម្មវិធីដោយកំណត់នូវបញ្ហាប្រឈមឱ្យបានច្បាស់លាស់ និងរៀបចំយន្តការដោះស្រាយ | |
| ៣.៥. អនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាថ្នាក់ក្រោមជាតិ ២០១៩-២០២៥ | --- | ផែនការសកម្មភាពលម្អិតសម្រាប់អនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត (Q4) | គោលការណ៍ណែនាំស្តីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត |
| ៤.១. ក្របខ័ណ្ឌគណនេយ្យភាព នៃថវិកាសមិទ្ធកម្មត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | មានយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា ២០១៨-២០២៥ | ១.ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈត្រូវបានពិនិត្យ<br>២.អនុក្រឹត្យលេខ ៨១ និង ៨២ ត្រូវបានសិក្សា<br>៣.គោលការណ៍ណែនាំស្តីពីរៀបចំថវិកាសមិទ្ធកម្មត្រូវបានរៀបចំ និងអនុម័ត<br>៤.គោលការណ៍ណែនាំស្តីពីការអនុវត្តថវិកាសមិទ្ធកម្មត្រូវបានសិក្សា | ១.សេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈត្រូវបានធ្វើវិសោធនកម្ម និងបញ្ជូនទៅគណៈរដ្ឋមន្ត្រី<br>២.អនុក្រឹត្យលេខ ៨១ និងលេខ ៨២ ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត<br>៣.គោលការណ៍ណែនាំស្តីពីការអនុវត្តថវិកាសមិទ្ធកម្មត្រូវបានអនុវត្ត |
| ៤.២. ទម្រង់កិច្ចព្រមព្រៀងព័ត៌មានសមិទ្ធកម្មបឋម | --- | ទម្រង់កិច្ចព្រមព្រៀងព័ត៌មានសមិទ្ធកម្មបឋមត្រូវបានសិក្សា និងរៀបចំ | ទម្រង់កិច្ចព្រមព្រៀងព័ត៌មានសមិទ្ធកម្មត្រូវដាក់ឱ្យអនុវត្តសាកល្បង |
| ៤.៣. ទម្រង់ព័ត៌មានសមិទ្ធកម្មប្រចាំឆ្នាំត្រូវបានរៀបចំសម្រាប់ភ្ជាប់ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ | --- | ទម្រង់ព័ត៌មានសមិទ្ធកម្មប្រចាំឆ្នាំសម្រាប់ត្រៀមភ្ជាប់ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំត្រូវបានរៀបចំ | --- |
| ៤.៤. ទម្រង់បឋមចំណាត់ថ្នាក់សេដ្ឋកិច្ចបំព្រួញ សម្រាប់ត្រៀមភ្ជាប់ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ | --- | ទម្រង់បឋមចំណាត់ថ្នាក់សេដ្ឋកិច្ចបំព្រួញត្រូវបានសិក្សា និងរៀបចំ សម្រាប់ត្រៀមភ្ជាប់ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ | ចំណាត់ថ្នាក់សេដ្ឋកិច្ចបំព្រួញត្រូវបានរៀបចំ សម្រាប់ភ្ជាប់ច្បាប់ថវិកា |
| ៤.៥. ក្របខ័ណ្ឌទស្សនាទាននៃការតាមដាន និងត្រួតពិនិត្យព័ត៌មានសមិទ្ធកម្ម (Monitor and Review) | --- | ក្របខណ្ឌទស្សនាទាននៃការតាមដាន និងត្រួតពិនិត្យព័ត៌មានសមិទ្ធកម្ម ត្រូវបានសិក្សា | ក្របខណ្ឌទស្សនាទាននៃការតាមដាន និងត្រួតពិនិត្យព័ត៌មានសមិទ្ធកម្ម ត្រូវបានរៀបចំ |

| សូចនាករសមិទ្ធកម្មគន្លឹះ | បន្ទាត់គោលឆ្នាំ ២០១៨ | គោលដៅ ២០១៩ | គោលដៅ ២០២០ |
|---|---|---|---|
| ៤.៦. ទម្រង់របាយការណ៍ព័ត៌មានសមិទ្ធកម្មនៃការអនុវត្តថវិកាប្រចាំឆ្នាំ | --- | ក្របខ័ណ្ឌនៃរបាយការណ៍សមិទ្ធកម្មនៃការអនុវត្តថវិកាប្រចាំឆ្នាំត្រូវបានសិក្សា | ទម្រង់របាយការណ៍ព័ត៌មានសមិទ្ធកម្មនៃការអនុវត្តថវិកាប្រចាំឆ្នាំត្រូវបានរៀបចំ |
| ៤.៧. ក្របខ័ណ្ឌសវនកម្មពេញលេញ (សមិទ្ធកម្ម, ព័ត៌មានវិទ្យា, អនុលោមភាព និងហិរញ្ញវត្ថុ) ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | មានគោលការណ៍ណែនាំសវនកម្មស្តីពីអនុលោមភាព និងហិរញ្ញវត្ថុ | ១. គោលការណែនាំស្តីពីការធ្វើសវនកម្មលើបច្ចេកវិទ្យាព័ត៌មានត្រូវបានរៀបចំ និងដាក់អនុវត្ត<br>២. គោលការណែនាំស្តីពីការធ្វើសវនកម្មលើសមិទ្ធកម្ម ត្រូវបានរៀបចំ និងដាក់អនុវត្ត | ១. អង្គភាពសវនកម្មផ្ទៃក្នុងនៃក្រសួងស្ថាប័ន ត្រូវបានផ្តល់ការណែនាំស្តីពីស្តីពីសវនកម្មលើបច្ចេកវិទ្យាព័ត៌មាន និងអនុវត្តសាកល្បង ៥ គោលដៅ<br>២. អង្គភាពសវនកម្មផ្ទៃក្នុងនៃក្រសួងស្ថាប័ន ត្រូវបានផ្តល់ការណែនាំស្តីពីសវនកម្មលើសមិទ្ធកម្ម និងអនុវត្តសាកល្បង ៥ គោលដៅ |
| ៤.៨. ក្របខ័ណ្ឌអធិការកិច្ចហិរញ្ញវត្ថុត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្ត | --- | ១. អនុក្រឹត្យស្តីពីវិធាននិងនីតិវិធីអធិការកិច្ចហិរញ្ញវត្ថុ<br>២. សៀវភៅគោលស្តីពីអធិការកិច្ចហិរញ្ញវត្ថុ<br>៣. ស្តង់ដារអធិការកិច្ចហិរញ្ញវត្ថុ | ១. ស្តង់ដារអធិការកិច្ចហិរញ្ញវត្ថុត្រូវបានរៀបចំ, អនុម័ត និងដាក់ឱ្យអនុវត្ត<br>២. ប្រព័ន្ធការងារអធិការកិច្ចហិរញ្ញវត្ថុតាមបច្ចេកវិទ្យាព័ត៌មាន ត្រូវបានរៀបចំ អនុម័ត និងដាក់ឱ្យអនុវត្ត |
| ៤.៩. របាយការណ៍សវនកម្មសមិទ្ធ កម្មរបស់អាជ្ញាធរសវនកម្មជាតិចំនួន៤ ត្រូវបានដាក់ជូនរដ្ឋសភា | របាយការណ៍សវនកម្មសមិទ្ធកម្មចំនួន ៣ ឆ្នាំ) (២០១៨ | របាយការណ៍សវនកម្មសមិទ្ធកម្មចំនួន ៤ ត្រូវបានដាក់ជូនរដ្ឋសភា | របាយការណ៍សវនកម្មសមិទ្ធកម្មចំនួន ៥ ត្រូវបានដាក់ជូនរដ្ឋសភា |
| ៤.១០. ផែនការយុទ្ធសាស្រ្តកសាងនិងអភិវឌ្ឍសមត្ថភាពក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៤ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | ផែនការយុទ្ធសាស្រ្តកសាងនិងអភិវឌ្ឍសមត្ថភាពក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៣ | មានសេចក្តីព្រាងផែនការយុទ្ធសាស្រ្តកសាងនិងអភិវឌ្ឍសមត្ថភាពក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី ៤ | សេចក្តីព្រាងឯកសារស្តីពីការបច្ចុប្បន្នកម្មផែនការយុទ្ធសាស្រ្តស្តីពីការកសាងនិងអភិវឌ្ឍ សមត្ថភាព ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៤ (២០២១-២០២៥) ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត |

| សូចនាករសមិទ្ធកម្មគន្លឹះ(KPI) | បន្ទាត់គោលឆ្នាំ ២០១៧-២០១៨ | គោលដៅ ២០១៩ | គោលដៅ ២០២០ |
|---|---|---|---|
| **៥.១. យន្តការ នីតិវិធី នៃការអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមក្រសួង ស្ថាប័ន ត្រូវបានអនុវត្ត** | យន្តការនីតិវិធី នៃការអនុវត្តការងារកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមក្រសួង-ស្ថាប័ន ត្រូវបានអនុវត្ត | យន្តការ នីតិវិធី នៃការអនុវត្តការងារកែទម្រង់ការគ្រប់ គ្រងហិរញ្ញវត្ថុសាធារណៈ តាមក្រសួងស្ថាប័នត្រូវបាន អនុវត្ត | យន្តការ នីតិវិធី នៃការអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមក្រសួង ស្ថាប័ន ត្រូវបានអនុវត្ត |
| **៥.២. ផែនការសកម្មភាពក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រកសាងសមត្ថភាពក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានអនុវត្ត** | -មន្ត្រីចំនួន៩៥០គ្រប់ក្រសួង- ស្ថាប័នត្រូវបានបណ្តុះបណ្តាល | -យ៉ាងតិច៨០%នៃផែនការសកម្មភាពដែលបានដាក់ចេញសម្រេចបាន<br>-មន្ត្រីចំនួន១០៤៥គ្រប់ក្រសួង- ស្ថាប័នត្រូវបានបណ្តុះបណ្តាល | -យ៉ាងតិច៩០នៃផែនការសកម្មភាព% ដែលបានដាក់ចេញសម្រេចបាន<br>-មន្ត្រីចំនួន១១៤៩គ្រប់ក្រសួង- ស្ថាប័នត្រូវបានបណ្តុះបណ្តាល<br>-សិក្ខាសាលាវគ្គបណ្តុះបណ្តាល ត្រូវបានរៀបចំស្របតាមចក្ខុវិស័យការងារកែទម្រង់PFM និងយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកានិងតម្រូវការផ្ទាល់របស់មន្ត្រីរាជការគ្រប់ គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួងស្ថាប័ន |



## សូចនាករសមិទ្ធកម្មគន្លឹះសម្រាប់ក្រសួង-ស្ថាប័ន នៃផែនការសកម្មភាពរួមដំណាក់កាលទីបី ឆ្នាំ២០១៩-២០២០

| លទ្ធផលក្នុងឆ្នាំ | សូចនាករសមិទ្ធកម្មគន្លឹះក្នុងឆ្នាំ |
|---|---|
| ១. ពង្រឹងប្រសិទ្ធភាពការគ្រប់គ្រង ចំណូល ចំណាយ | ១. ចំណូលមិនមែនសារពើពន្ធ កើនឡើង ....%<br>២. ផែនការចំណូលប្រចាំត្រីមាស និងប្រចាំឆ្នាំធៀបនឹងការអនុវត្តជាក់ស្តែងក្នុងរង្វង់ +/-៥%<br>៣. កម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសត្រូវបានរៀបចំនិងអនុវត្តប្រកបដោយសុក្រឹត្យភាព និងមានរបាយការណ៍ស្តីពីការអនុវត្តចំណាយ (កម្រិតលម្អៀង +/-៥%) |
| ២. ពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ | ១. ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួង ស្ថាប័នត្រូវបានអនុវត្តតាមប្រព័ន្ធគ្រប់គ្រងទិន្នន័យបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ នៃកសហវ<br>២. បញ្ចប់ការចុះបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ និងធ្វើបច្ចុប្បន្នភាពជាប្រចាំ |
| ៣. ពង្រឹង និងពង្រីកការអនុវត្តប្រព័ន្ធ FMIS | ១. រៀបចំបរិបទនៃប្រតិបត្តិការ (ការធានាចំណាយ, ការទូទាត់ចំណាយ ការកត់ត្រាចំណូល និងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ) តាមក្រសួង-ស្ថាប័នស្របតាមប្រព័ន្ធ FMIS<br>២. កសាងសមត្ថភាពគ្រប់គ្រងគម្រោង FMIS តាមគ្រប់ក្រសួង-ស្ថាប័ន |
| ៤.ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តថវិកាកម្មវិធី | ១. របាយការណ៍វាយតម្លៃការអនុវត្តថវិកាកម្មវិធីប្រចាំឆមាស និងប្រចាំឆ្នាំ ត្រូវបានរៀបចំនិងផ្ញើជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>២. ត្រួតពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តថវិកាកម្មវិធីដោយរំលេចឱ្យឃើញពីរបកគំហើញ និងអនុសាសន៍នានា និងកែលម្អ<br>៣. គម្លាតនៃផែនការយុទ្ធសាស្ត្រថវិកា ៣ឆ្នាំរំកិល និងផែនការថវិកាប្រចាំឆ្នាំដែលអនុម័តត្រូវបានកាត់បន្ថយ |
| ៥.ពង្រឹងការរៀបចំ និងការអនុវត្តកម្មវិធីសវនកម្ម អធិការកិច្ចប្រចាំឆ្នាំ/ (ប្រព័ន្ធត្រួតពិនិត្យ) | ១. រៀបចំ និងកែលម្អផែនការយុទ្ធសាស្ត្រសវនកម្ម ,ផែនការសវនកម្ម/អធិការកិច្ចប្រចាំឆ្នាំរបស់ក្រសួងស្ថាប័ន<br>២. យ៉ាងតិច ៦០% នៃផែនការសវនកម្ម និង ៩០% នៃផែនការអធិការកិច្ចប្រចាំឆ្នាំរបស់ក្រសួង-ស្ថាប័នត្រូវបានអនុវត្ត<br>៣. ក្រសួង-ស្ថាប័ន/អង្គភាព ឆ្លើយតប និងកែលម្អតាមវិធានការដែលបានលើកឡើងដោយអគ្គាធិការដ្ឋាន និងសវនកម្មផ្ទៃក្នុងយ៉ាងតិច ៥០% |

ដោយផ្អែកលើផែនការសកម្មភាពឆ្នាំ២០១៩-២០២០ និងសូចនាករសមិទ្ធកម្មគន្លឹះ ខាងលើ អគ្គនាយកដ្ឋាន និងអង្គភាពនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នទាំងអស់ ត្រូវរៀបចំផែនការសកម្មភាពលម្អិតសម្រាប់ អនុវត្តប្រចាំឆ្នាំនីមួយៗ (សម្រាប់ឆ្នាំ២០១៩ និង ឆ្នាំ២០២០)៕■ *រៀបចំដោយ៖ អ.គ.ហ.*

# យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥

*សេចក្តីព្រាងឯកសារយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥ ត្រូវបានរៀបចំឡើងឱ្យមានសង្គតិភាពជាមួយឯកសារយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា ឆ្នាំ២០១៨-២០២៥ ដែលត្រូវបានគណៈរដ្ឋមន្ត្រីអនុម័តដាក់ឱ្យប្រើប្រាស់ជាផ្លូវការកាលពីថ្ងៃទី ១២ ខែមករា ឆ្នាំ២០១៨។*

សេចក្តីព្រាងឯកសារយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥ ត្រូវបានរៀបចំឡើងដោយផ្អែកលើមូលដ្ឋានមួយចំនួនរួមមាន៖

១) ក្របខ័ណ្ឌវាយតម្លៃចំណាយសាធារណៈ និងគណនេយ្យហិរញ្ញវត្ថុ (Public Expenditure and Financial Accounability - PEFA) ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

២) ការវាយតម្លៃហានិភ័យអភិបាលកិច្ច និងផែនការគ្រប់គ្រង (Country Governance Risk Assessment and Management Plan) របស់ធនាគារអភិវឌ្ឍន៍អាស៊ី

៣) ការវិភាគចំណុចខ្លាំង ចំណុចខ្សោយ កាលានុវត្តភាព និងការគំរាមកំហែង (SWOT Analysis)

៤) បទពិសោធន៍ នៃការអនុវត្តកិច្ចលទ្ធកម្មសាធារណៈកន្លងមករបស់ប្រទេសកម្ពុជា និងការដកស្រង់បទពិសោធន៍ នៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈពីប្រទេសមួយចំនួនជាពិសេសប្រទេសហ្វីលីពីន និងប្រទេសបារាំង។

តាមការចង្អុលបង្ហាញនៅក្នុងឯកសារយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា ឆ្នាំ២០១៨-២០២៥ ទិសដៅសំខាន់ៗនៃការរៀបចំឯកសារយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥ នេះគឺ៖ (១). ពង្រឹងយន្តការគណនេយ្យភាព តាមរយៈក្របខ័ណ្ឌនិយ័តកម្ម ដោយបែងចែកមុខងារឱ្យដាច់ពីគ្នារវាងនិយ័តករនិងប្រតិបត្តិករ ដែលក្នុងនោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានតួនាទីជានិយ័តករ រីឯស្ថាប័ន ដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ត្រូវទទួលខុសត្រូវ និងមានគណនេយ្យភាពចំពោះកិច្ចលទ្ធកម្ម (២). ធ្វើវិមជ្ឈការលទ្ធកម្មដោយ ប្រតិភូកម្មសិទ្ធិអំណាចនិងការទទួលខុសត្រូវជាបណ្តើរៗជូនស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ សំដៅដល់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌរហូតដល់ពេញលេញនៅឆ្នាំ២០២៥ នៅពេលមានក្របខ័ណ្ឌគណនេយ្យភាពច្បាស់លាស់ (៣). បន្តពង្រឹងយន្តការដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្មឱ្យមានឯករាជ្យភាពដោយបង្កើតឱ្យមានរបបរបបដាក់ទោសទណ្ឌ (៤). ធ្វើសុខដុមនីយកម្មវិធាន បទប្បញ្ញត្តិ និងនីតិវិធីនៃលទ្ធកម្មសាធារណៈ ដោយរៀបចំចងក្រងប្រមូលផ្តុំនូវលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និង (៥). គម្រោងផែនការលទ្ធកម្មនឹងត្រូវភ្ជាប់មកជាមួយសំណើគម្រោងថវិកាប្រចាំឆ្នាំ ហើយការពិនិត្យ និងសម្រេចនឹងធ្វើឡើងនៅក្នុងក្របខ័ណ្ឌ នៃការចរចាថវិកាកម្រិតថ្នាក់ដឹកនាំក្រសួងស្ថាប័ន សម្រាប់ជាមូលដ្ឋានផ្តល់ការឯកភាពជាផ្លូវការ ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។



គោលបំណងនៃឯកសារយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥ គឺដើម្បីធ្វើឱ្យប្រព័ន្ធលទ្ធកម្មសាធារណៈនៅកម្ពុជាក្លាយជា “**ប្រព័ន្ធ**

**មួយដែលកាន់តែជឿទុកចិត្ត ប្រសិទ្ធភាព ការប្រកួតប្រជែង និងការសន្សំសំចៃ ព្រមទាំងស្របតាមឧត្តមានុវត្តន៍អន្តរជាតិ**”។

ដើម្បីសម្រេចនូវគោលបំណងនេះ គឺត្រូវកំណត់វិសាលភាពនិងសមាធាតុគន្លឹះៗដែលពាក់ព័ន្ធនឹងកិច្ចលទ្ធកម្មសាធារណៈ និងធ្វើអាទិភាពនីយកម្មលើសមាសធាតុគន្លឹះៗទាំងនេះ ព្រមទាំងដាក់ចេញនូវសកម្មភាពកែទម្រង់ជាក់លាក់តាមអភិក្រមជាជំហ៊ានៗ និងជាដំណាក់កាលៗ ចាប់ពីឆ្នាំ២០១៩ រហូតដល់ឆ្នាំ២០២៥ ។

សមាសធាតុគន្លឹះៗដែលពាក់ព័ន្ធនឹងកិច្ចលទ្ធកម្មរួមមាន÷

**(១). ការរៀបចំនិងការអនុម័តផែនការលទ្ធកម្ម :** ស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់នៅរដ្ឋបាលថ្នាក់ជាតិត្រូវភ្ជាប់គម្រោងផែនការលទ្ធកម្មប្រចាំឆ្នាំមកជាមួយនឹងសំណើគម្រោងថវិកាប្រចាំឆ្នាំ ហើយការពិនិត្យសម្រេចលើគម្រោងផែនការលទ្ធកម្មប្រចាំឆ្នាំនឹងត្រូវធ្វើឡើងនៅក្នុងក្របខ័ណ្ឌនៃការចរចាថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង-ស្ថាប័នដែលនឹងត្រូវចាប់អនុវត្តពីឆ្នាំ២០១៩នេះតទៅ។ ចំពោះការពិនិត្យ និងអនុម័តផែនការលទ្ធកម្មប្រចាំឆ្នាំវិញត្រូវធ្វើឡើង ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើកលែងតែផែនការលទ្ធកម្មប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ នឹងត្រូវពិនិត្យនិង អនុម័តដោយមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត ។ ចាប់ពីឆ្នាំ២០២៣ តទៅ ផែនការលទ្ធកម្មប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី-ខេត្ត ក្រុង ស្រុក ខណ្ឌ និងមន្ទីជំនាញរាជធានី-ខេត្ត នឹងត្រូវពិនិត្យនិងអនុម័ត ដោយមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត។

**(២). ការអនុវត្តកិច្ចលទ្ធកម្ម :** គោលបំណងសម្រាប់ឆ្នាំ២០២៥ គឺធ្វើវិមជ្ឈការលទ្ធកម្មដោយប្រតិភូកម្មសិទ្ធិអំណាច និងការទទួលខុសត្រូវជាបណ្តើរៗ ជូនស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់រហូតដល់ពេញលេញនៅឆ្នាំ២០២៥ នៅពេលមានក្របខ័ណ្ឌគណនេយ្យភាពច្បាស់លាស់លើកលែងតែមុខសញ្ញាលទ្ធកម្មមួយចំនួនដែលមានទំហំធំមានចរិតជាយុទ្ធសាស្ត្រ មានលក្ខណៈបច្ចេកទេសដោយឡែកសម្រាប់ការគ្រប់គ្រង និង/ ឬមានវេទយិតភាពខ្ពស់ដែលចាំបាច់ត្រូវតែជាកម្មវត្ថុនៃការស្នើសុំការឯកភាពជាមុនពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ នៅពេលនោះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងដើរតួនាទីជានិយ័តករ និងសវនកម្មកិច្ចលទ្ធកម្ម ចំណែកឯក្រសួងស្ថាប័នត្រូវទទួលខុសត្រូវ និងមានគណនេយ្យភាពចំពោះកិច្ចលទ្ធកម្ម។ ស្របតាមទិសដៅនេះ នឹងមានបង្កើតមុខងារលទ្ធកម្ម ក្នុងក្របខ័ណ្ឌអភិបាលថវិកា ដាក់នៅអមក្រសួង ស្ថាប័នជាបណ្តើរៗ។ **(៣). ការត្រួតពិនិត្យនិងការវាយតម្លៃលើការអនុវត្តកិច្ចលទ្ធកម្ម :** គោលបំណងសម្រាប់ឆ្នាំ២០២៥ គឺត្រូវកែលម្អលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការធ្វើសវនកម្ម និងពង្រីកវិសាលភាពនៃការធ្វើសវនកម្មលើកិច្ចលទ្ធកម្មដែលប្រើប្រាស់ថវិកាហិរញ្ញប្បទានដោយ ដៃគូអភិវឌ្ឍន៍ និងកិច្ចលទ្ធកម្មដែលប្រើប្រាស់ថវិការដ្ឋ។ **(៤). ការពង្រឹងឯករាជ្យភាពនៃយន្តការដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្មនិងបង្កើតឱ្យមានរបបដាក់ទោសទណ្ឌ :** គោលបំណងសម្រាប់ឆ្នាំ២០២៥ គឺបន្តពង្រឹងការអនុវត្តលិខិតបទដ្ឋានសម្រាប់ដោះស្រាយបណ្តឹងតវ៉ាបច្ចុប្បន្ន និងកែលម្អក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដោយបង្កើតឱ្យមានរបបដាក់ទោសទណ្ឌ។ **(៥). ហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់ :** ដើម្បីឈានទៅសម្រេច



បានតាមសមាធាតុទាំង៤នេះ គឺចាំបាច់ត្រូវធ្វើការកែទម្រង់លើសមាសធាតុទ្រទ្រង់មួយចំនួនរួមមាន÷ ការកែលម្អក្របខ័ណ្ឌគតិយុត្តនៃលទ្ធកម្មសាធារណៈតាមរយៈការធ្វើវិសោធនកម្មច្បាប់ស្តីពីលទ្ធកម្មសាធារណៈ និងការកែលម្អលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា ការធ្វើសុខដុមនីយកម្មនូវគោលការណ៍ វិធាន និងនីតិវិធីលទ្ធកម្ម ដោយរៀបចំចងក្រងជាសៀវភៅណែនាំស្តីពីលទ្ធកម្មសាធារណៈ (Public Procurement



Manual) ការរៀបចំនិងប្រើប្រាស់លទ្ធកម្មរដ្ឋាភិបាលតាមប្រព័ន្ធអេឡិចត្រូនិច (e-GP) និងការបន្តកសាងសមត្ថភាពភាគីពាក់ព័ន្ធ។ **(៦). ការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ : គឺផ្តោតតែទៅលើសមាសធាតុសំខាន់ៗចំនួន៣ ដែលពាក់ព័ន្ធនឹងការរៀបចំ និងការអនុម័តផែនការលទ្ធកម្ម ការអនុវត្តកិច្ចលទ្ធកម្ម និងប្រព័ន្ធរបាយការណ៍អនុវត្តកិច្ចលទ្ធកម្ម។ និងការអនុម័តផែនការលទ្ធកម្មប្រចាំឆ្នាំ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ** លើកលែងតែរដ្ឋបាលឃុំ សង្កាត់ដែលត្រូវអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តដោយឡែក និងត្រូវធ្វើឡើងដោយមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្តចាប់ពីឆ្នាំ២០២៣ តទៅ។ ដោយឡែក ចំពោះប្រព័ន្ធរបាយការណ៍អនុវត្តកិច្ចលទ្ធកម្មវិញគឺត្រូវមានការកែលម្អលើទម្រង់របាយការណ៍ និងរបបរាយការណ៍ដោយរៀបចំបង្កើតតាមស្តង់ដាររបាយការណ៍ថ្មី។

ជាមួយគ្នានេះ ក្នុងឯកសារយុទ្ធសាស្ត្រ ក៏បានគូសរំលេចអំពីផែនទីចង្អុលផ្លូវក្នុងក្របខ័ណ្ឌនៃការកែទម្រង់ ប្រព័ន្ធលទ្ធកម្មសាធារណៈកម្ពុជាចាប់ពីឆ្នាំ២០១៩ រហូតដល់ឆ្នាំ២០២៥ ការវិភាគ និងការគ្រប់គ្រងហានិភ័យ ដែលអាចកើតមានឡើងក្នុងការអនុវត្តយុទ្ធសាស្ត្រ នៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈនេះផងដែរ។ទន្ទឹមនេះ ភាពជោគជ័យ នៃការអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈនេះ គឺអាស្រ័យលើលទ្ធផល នៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈការកែទម្រង់ប្រព័ន្ធថវិកា និងការកែទម្រង់សំខាន់ៗផ្សេងទៀតរបស់រាជរដ្ឋាភិបាល។ ឯកសារយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ ឆ្នាំ២០១៩-២០២៥ ត្រូវបានចាត់ទុកជាឯកសាររស់ដែលជាកម្មវត្ថុនៃការកែប្រែបានតាមការចាំបាច់៕■

*ការអនុវត្តកិច្ចលទ្ធកម្មមានគោលបំណងសម្រាប់ឆ្នាំ២០២៥ គឺធ្វើវិមជ្ឈការលទ្ធកម្មដោយប្រតិភូកម្មសិទ្ធអំណាច និងការទទួលខុសត្រូវជាបណ្តើរៗ ជូនស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់រហូតដល់ពេញលេញនៅឆ្នាំ២០២៥ នៅពេលមានក្របខ័ណ្ឌគណនេយ្យភាពច្បាស់លាស់ លើកលេងតែមុខសញ្ញាលទ្ធកម្មមួយចំនួនដែលមានទំហំធំមានចរិតជាយុទ្ធសាស្ត្រ មានលក្ខណៈបច្ចេកទេសដោយឡែកសម្រាប់ការគ្រប់គ្រងនិង/ឬមានវេទយិតភាពខ្ពស់ដែលចាំបាច់ត្រូវតែជាកម្មវត្ថុនៃការស្នើសុំការឯកភាពជាមុនពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។*

*រៀបចំដោយ÷ ក្រុមការងារកែទម្រង់នៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ*

# មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ ចូលរួមចំណែកពង្រឹងសមត្ថភាពស្ថាប័នរដ្ឋបាលស្រុក

*រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានបង្កើត និងដាក់ឲ្យដំណើការយន្តការមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈអនុក្រឹត្យលេខ ៣២ អនក្រ.បក ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ ក្នុងគោលបំណងលើកកម្ពស់ការអភិវឌ្ឍសង្គមសេដ្ឋកិច្ច នៅថ្នាក់ក្រោមជាតិ ដោយផ្តល់ហិរញ្ញប្បទានទៅដល់គម្រោងវិនិយោគសាធារណៈ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានលក្ខណៈជាយុទ្ធសាស្ត្រ និងផ្តល់ការលើកទឹកចិត្តដល់រដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីលើកកម្ពស់ការបំពេញភារកិច្ច និងការគ្រប់គ្រងការវិនិយោគសាធារណៈឲ្យកាន់តែប្រសើរ។*

មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានទីតាំងស្ថិតនៅក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានគ្រប់គ្រងដោយក្រុមប្រឹក្សាភិបាល ដែលមានសមាសភាពមកពីតំណាងក្រសួង-ស្ថាប័នចំនួន ១៩ និងមានរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាប្រធានក្រុមប្រឹក្សាភិបាល ព្រមទាំងមានលេខាធិការដ្ឋាន ក្រុមប្រឹក្សាភិបាលគ្រប់គ្រងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ ជាសេនាធិការក្នុងការបំពេញការងារប្រតិបត្តិការប្រចាំថ្ងៃ។

ជាការពិតណាស់ យន្តការមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាយន្តការទទួលបានហិរញ្ញប្បទាន មានភ្ជាប់លក្ខខណ្ឌ និងប្រកួតប្រជែង,រដ្ឋបាលស្រុកដែលជាប់ការវាយតម្លៃសមិទ្ធកម្ម និងមានពិន្ទុខ្ពស់ជាងគេត្រូវបានទទួលធនធានបន្ថែមដើម្បីអនុវត្តគម្រោងវិនិយោគនៅមូលដ្ឋានរបស់ខ្លួន។ ដូច្នេះដើម្បីទទួលបានជោគជ័យ រដ្ឋបាលស្រុកនីមួយៗ ត្រូវយកចិត្តទុកដាក់បំពេញគ្រប់លក្ខខណ្ឌដែលបានកំណត់នៅក្នុងគោលការណ៍ណែនាំស្តីពីការវាយតម្លៃសមិទ្ធកម្មប្រចាំឆ្នាំសម្រាប់រដ្ឋបាលស្រុក។ រៀងរាល់ឆ្នាំ បុគ្គលិកនៃលេខាធិការដ្ឋានក្រុមប្រឹក្សាភិបាល គ្រប់គ្រងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ នឹងចុះធ្វើការវាយតម្លៃសមិទ្ធកម្មរបស់រដ្ឋបាលស្រុក ដើម្បីជ្រើសរើសរដ្ឋបាលស្រុកដែលមានពិន្ទុខ្ពស់ជាងគេតាមលំដាប់ ដាក់ជូនក្រុមប្រឹក្សាភិបាលគ្រប់គ្រងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិពិនិត្យ និងអនុម័ត។

*យន្តការមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាយន្តការទទួលបានហិរញ្ញប្បទាន មានភ្ជាប់លក្ខខណ្ឌ និងប្រកួតប្រជែង, រដ្ឋបាលស្រុកដែលជាប់ការវាយតម្លៃសមិទ្ធកម្ម និងមានពន្ទុខ្ពស់ជាងគេត្រូវបានទទួលធនធានបន្ថែមដើម្បីអនុវត្តគម្រោងវិនិយោគនៅមូលដ្ឋានរបស់ខ្លួន។*



គោលការណ៍ណែនាំស្តីពីការវាយតម្លៃសមិទ្ធកម្មប្រចាំឆ្នាំ សម្រាប់រដ្ឋបាលស្រុក ត្រូវបានរៀបចំឡើងផ្អែកលើ ការអនុវត្តគោលការណ៍ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងការបំពេញភារកិច្ចរបស់រដ្ឋបាលស្រុកប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ដែលមានចែងនៅក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ។ មូលដ្ឋានសម្រាប់វាយតម្លៃសមិទ្ធកម្មចែកចេញជា ៥ លក្ខខណ្ឌធំៗ គឺ៖

**១). តម្លាភាព និងការផ្សព្វផ្សាយ៖** រដ្ឋបាលស្រុកបានផ្សព្វផ្សាយព័ត៌មានអំពីកិច្ចប្រជុំក្រុមប្រឹក្សាអំពីគម្រោងថវិកាប្រចាំឆ្នាំ ការគ្រប់គ្រងហិរញ្ញវត្ថុ ការអនុវត្តថវិកា និងការងារផ្សេងៗដែលកំណត់ដោយច្បាប់ ឬលិខិតបទដ្ឋានជាធរមាន ។





**២). ការចូលរួម÷** រដ្ឋបាលស្រុកបានរៀបចំឱ្យមានយន្តការពិគ្រោះយោបល់ និងស្នើឱ្យមានការចូលរួម ពីប្រជាពលរដ្ឋនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាអំពីការកសាងផែនការ និងការរៀបចំគម្រោងថវិកា ដូចមានចែងក្នុងច្បាប់ ឬលិខិតបទដ្ឋានជាធរមាន។

**៣). ការបំពេញភារកិច្ចរបស់ក្រុមប្រឹក្សា÷** ក្រុមប្រឹក្សាស្រុកបានរៀបចំកិច្ចប្រជុំដោយមានការកត់ត្រាកំណត់ហេតុកិច្ចប្រជុំបានត្រឹមត្រូវ រៀបចំបង្កើតគណៈកម្មាធិការ និងធានាឱ្យបានថាប្រជាពលរដ្ឋមានឱកាសចូលរួមក្នុងអភិបាលកិច្ច និងឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

**៤). ការបំពេញភារកិច្ចរបស់គណៈអភិបាល÷** គណៈអភិបាលស្រុកបានរៀបចំ និងដាក់ជូនក្រុមប្រឹក្សានូវផែនការអភិវឌ្ឍរយៈពេល ០៥ឆ្នាំកម្មវិធីវិនិយោគ០៣ឆ្នាំរំកិលគម្រោងថវិកាប្រចាំឆ្នាំ និងរបាយការណ៍នានាបានទាន់ពេលវេលាដោយផ្អែកតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។

**៥). ការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ÷** រដ្ឋបាលស្រុកបានរៀបចំ គម្រោងថវិកាប្រចាំឆ្នាំ ការអនុវត្តថវិកា ការអនុវត្តកិច្ចលទ្ធកម្ម ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ (ការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ) ការគ្រប់គ្រងថវិកា និងគណនេយ្យដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដែលមានជាធរមាន។

ក្នុងដំណើការអនុវត្តសាកល្បងនូវយន្តការថ្មីនេះ រដ្ឋបាលស្រុកត្រូវបានជ្រើសរើសជារដ្ឋបាលគោលដៅក្នុងការប្រកួតប្រជែងសម្រាប់អនុវត្តយន្តការមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិនេះ ។ រដ្ឋបាលស្រុកត្រូវបានទទួលការវាយតម្លៃសមិទ្ធកម្មប្រចាំឆ្នាំ ដើម្បីទទួលបានធនធានបន្ថែមពីមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិលើកញ្ចប់ថវិការដ្ឋប្រចាំឆ្នាំ ។ ចាប់ពីឆ្នាំ ២០១៧ ដល់ឆ្នាំ២០១៨, ថវិការដ្ឋចំនួនប្រមាណ ១០ ០០០ លានរៀល ឬសមមូលនឹង ២.៥ លានដុល្លារអាមេរិក ត្រូវបានផ្តល់ជូនរដ្ឋបាលស្រុកចំនួន ៣៤ ដែលបានជាប់ចំណាត់ថ្នាក់ល្អជាងគេ ក្នុងការវាយតម្លៃសមិទ្ធកម្មប្រចាំឆ្នាំ ។ ផ្អែកលើបទពិសោធន៍ដែលទទួលបានពីការអនុវត្តសាកល្បងនេះ, លេខាធិការដ្ឋានក្រុមប្រឹក្សាភិបាលគ្រប់គ្រងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ ពិនិត្យឃើញថារដ្ឋបាលស្រុកជាច្រើនបានបង្កើនការយកចិត្តទុកដាក់ក្នុងការគ្រប់គ្រងនិងថែរក្សាឯកសារ, បង្កលក្ខណៈងាយស្រួលនៅពេលមានការធ្វើអធិការកិច្ចនិងសវនកម្ម, ទំនាក់ទំនងរវាងប្រជាពលរដ្ឋនៅមូលដ្ឋាននិង រដ្ឋបាលស្រុកមានភាពប្រសើរឡើង, ប្រជាពលរដ្ឋបានយល់ពីកិច្ចដំណើរការ ការងាររបស់រដ្ឋបាលស្រុក និងសមត្ថភាពមន្ត្រីរបស់រដ្ឋបាលស្រុក ជាពិសេសពាក់ព័ន្ធទៅនឹងការងារថវិកាមានការកែលម្អ ។ សម្រាប់ឆ្នាំ២០១៩, ធនធានអនុវត្តយន្តការមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានបង្កើន ក្នុងនោះ រាជរដ្ឋាភិបាលបានផ្តល់ថវិកាចំនួន ១.៥ លានដុល្លារអាមេរិក និងធនាគារអភិវឌ្ឍន៍អាស៊ី បានផ្តល់ហិរញ្ញប្បទានថវិកា ចំនួន ៧.៥ លានដុល្លារអាមេរិក សម្រាប់ពង្រីកវិសាលភាពមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ ទៅដល់រដ្ឋបាលក្រុង និងខណ្ឌព្រមទាំងឯកសារគាំទ្រការអនុវត្តសំខាន់ចំនួនពីរ គឺគោលការណ៍ណែនាំស្តីពីការវាយតម្លៃសមិទ្ធកម្មសម្រាប់រដ្ឋបាលក្រុង និងគោលការណ៍ណែនាំស្តីពីការវាយតម្លៃសមិទ្ធកម្មសម្រាប់រដ្ឋបាលខណ្ឌត្រូវបានក្រុមប្រឹក្សា អនុម័ត និងដាក់ឱ្យអនុវត្តនាពេលថ្មីៗ កន្លងមកនេះ ៕■

*រៀបចំដោយ÷ ក្រុមការងារកែទម្រង់នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ*

# បទពិសោធក្នុងការកែទម្រង់របស់ប្រទេសហ្វីលីពីន

*រដ្ឋាភិបាលហ្វីលីពីនបានចាប់ផ្តើមអនុវត្តនូវសូចនាករនៃការអភិវឌ្ឍសង្គម (Indicators of Social development) តាំងពីដើមទសវត្សរ៍ឆ្នាំ៧០s មកម្លេះ ។ រហូតដល់ចុងទសវត្សរ៍ឆ្នាំ៩០s, រដ្ឋាភិបាលបានផ្តោតលើការគ្រប់គ្រងចំណាយសាធារណៈ (Public Expenditure Management-PEM) ក្នុងគោលដៅពង្រឹងវិន័យថវិកា, ពង្រឹងប្រសិទ្ធភាពនៃការវិភាជ, និងពង្រឹងប្រសិទ្ធភាពនៃប្រតិបត្តិការ។*




សមាសភាគនៃការគ្រប់គ្រងចំណាយសាធារណៈរួមមាន ក្របខណ្ឌសូចនាករសមិទ្ធកម្មអង្គភាព (Organizational Performance Idicator Framework-OPIF) និងក្របខណ្ឌចំណាយរយៈពេលមធ្យម (Medium-Term Expenditure Framework-MTEF)។ OPIF ត្រូវបានដាក់ឱ្យអនុវត្តសាកល្បងនៅ ស្ថាប័នចំនួន ២០ នៅឆ្នាំ២០០៧ និងអនុវត្តគ្រប់ស្ថាប័ននៅឆ្នាំ២០០៨ ។

ក្នុងការអនុវត្តនេះ, រដ្ឋាភិបាលបានរៀបចំ និងផ្សព្វផ្សាយសៀវភៅលទ្ធផលក្នុងឆ្នាំ (Book of Outputs) ដែលប្រមូលផ្តុំដោយលទ្ធផលក្នុងឆ្នាំសំខាន់ៗ (Major Final Outputs-MFOs) និងសូចនាករសមិទ្ធកម្ម (Performance Indicators) នៃស្ថាប័ននីមួយៗ។ រដ្ឋាភិបាលបានអនុវត្តនូវប្រព័ន្ធលើកទឹកចិត្តផ្អែកលើសមិទ្ធកម្ម(Performance-Based Incentive System) នៅឆ្នាំ២០១២ និងរៀបចំឱ្យមានកិច្ចព្រមព្រៀងសមិទ្ធកម្មនៅឆ្នាំ២០១៣។ នៅឆ្នាំ២០១៥ រដ្ឋាភិបាលបានប្តូរពីការអនុវត្តថវិកាផ្អែកលើលទ្ធផលក្នុងឆ្នាំ (Outputs) ទៅថវិកាផ្អែកលើលទ្ធផលចុងក្រោយ (outcomes)។

## តើអ្វីជាថវិកាព័ត៌មានសមិទ្ធកម្ម (Performance-Informed Budgeting-PIB)?

ថវិកាព័ត៌មានសមិទ្ធកម្ម គឺជាអភិក្រមថវិកា ដែលប្រើប្រាស់ព័ត៌មានសមិទ្ធកម្ម (រំលេចអំពីគោលបំណង, លទ្ធផលក្នុងឆ្នាំ, លទ្ធផលចុងក្រោយ, និងការចំណាយ) ជាជំនួយដល់ការសម្រេចចិត្តក្នុងការវិភាជថវិកា ។ ព័ត៌មានហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ នឹងត្រូវបង្ហាញក្នុងច្បាប់ថវិកា (General Appropriation Act-GAA)។ ភាពខុសគ្នារវាងថវិកាផ្អែកលើធាតុចូល (Input-Based Budgeting-IBB) និងថវិកាព័ត៌មានសមិទ្ធកម្ម (Performance-Informed Budgeting-PIB) រួមមាន÷ ការផ្លាស់ប្តូរពីការផ្តល់ធនធានផ្តោតលើចំណាយឆ្នាំចាស់ ទៅជាការផ្តល់ធនធានផ្តោតលើគោលបំណង និងចំណាយតាមកម្មវិធី។ ផ្លាស់ប្តូរពីការលម្អិតលើធាតុថវិកា (Budget Element/Line Item) ទៅជាការបង្ហាញព័ត៌មានសមិទ្ធកម្មតម្រឹមជាមួយធនធានដែលបានគ្រោងទុក, ផ្លាស់ប្តូរពីការគ្មានមូលហេតុសមស្របក្នុងការចំណាយ ទៅជាមានគោលបំណង ឬគោលដៅច្បាស់លាស់

និងផ្លាស់ប្តូរពីចំណោទដែលថាតើស្ថាប័នអាចចំណាយកៀកនឹងផែនការដែលឬទេ? ទៅជាការសង្កត់ធ្ងន់ទៅលើសមិទ្ធកម្មតាមលទ្ធផលក្នុងឆ្នាំ និងលទ្ធផលចុងក្រោយ។

## ទស្សនវិស័យរយៈពេលវែង (Long-Term Vision)

ហ្វីលីពីនបានរៀបចំនូវទស្សនវិស័យប្រកបដោយមហិច្ឆិតាមួយសម្រាប់ជាតិរហូតដល់ឆ្នាំ ២០៤០ “AMBISYON NATIN 2040”។ ក្នុងទស្សនវិស័យនេះ,រដ្ឋាភិបាលហ្វីលីពីនចាំបាច់ត្រូវផ្តោតលើការរក្សានូវកំណើនសេដ្ឋកិច្ច ការវិនិយោគលើធនធានមនុស្ស និងការការពារប្រឆាំងនឹងអស្ថិរភាព។ តាមទស្សនវិស័យខាងលើ ប្រជាជននឹងពេញចិត្តនូវជីវិតប្រកបដោយផាសុកភាពមានចំណេះដឹងគ្រប់គ្រាន់ និងអាចរៀបចំផែនការសម្រាប់អនាគតក្មេងជំនាន់ក្រោយ។ គ្រួសាររស់នៅទីកន្លែងដែលខ្លួនជាម្ចាស់កម្មសិទ្ធ និងមានសេរីភាពក្នុងការធ្វើដំណើរទៅគ្រប់ទីកន្លែងតាមបំណងប្រាថ្នា,ព្រមទាំងទទួលបានការគាំពារ និងការគាំទ្រ តាមរយៈរដ្ឋាភិបាល ដែលមានភាពយុត្តិធម៌ ប្រសិទ្ធភាព និងស្អាតស្អំ ។

នៅឆ្នាំ២០៤០ តាមការគ្រោងទុក ហ្វីលីពីននឹងក្លាយជាប្រទេស ដែលមានវិបុលភាព, ជាសង្គមថ្នាក់កណ្តាល (Middle Class) ដែលគ្មានទុរគតជន, ជាសង្គមដែលរឹងមាំ, ជាសង្គមដែលឆ្លាតវៃ(Smart City) និងពេញទៅដោយនវានុវត្តន៍ និងជាសង្គមដែលផ្តល់ទំនុកចិត្តខ្ពស់ដល់ប្រជាពលរដ្ឋ ។ ដើម្បីសម្រេចបាននូវទស្សនវិស័យឆ្នាំ ២០៤០ រដ្ឋាភិបាលបានរៀបចំ និងអនុវត្តនូវផែនការអភិវឌ្ឍន៍ហ្វីលីពីនរយៈពេលមធ្យម (Medium-Term Philippine Development Plan) ឬហៅកាត់ថាផែនការអភិវឌ្ឍន៍ហ្វីលីពីន (Philippine Development Plan-PDP) ដែលមានរយៈពេល ៦ឆ្នាំ និងត្រូវអនុវត្តចំនួន៤ ផែនការរួមមាន÷ PDP 2017-2022, PDP 2023-2028, PDP 2029-2034, PDP 2035-2040។

## ផែនការអភិវឌ្ឍន៍ហ្វីលីពីន (Philippine Development Plan-PDP)

ក្នុងការអនុវត្តផែនការអភិវឌ្ឍន៍ហ្វីលីពីនឆ្នាំ២០១៧-២០២២ ដែលបានអនុម័តកាលពីដើមឆ្នាំ២០១៧,ហ្វីលីពីនត្រូវកសាងមូលដ្ឋានគ្រឹះដ៏រឹងមាំ សម្រាប់កំណើនប្រកបដោយបរិយាប័ន្ន, កសាងសង្គមមួយដែលរឹងមាំ និងផ្តល់នូវទំនុកចិត្តខ្ពស់ដល់ប្រជាជន ព្រមទាំងជាប្រទេសមានចំណេះដឹង ផ្អែកសេដ្ឋកិច្ចក្នុងការប្រកួតប្រជែងកម្រិតពិភពលោក។ បច្ច័យនេះ នឹងនាំឱ្យហ្វីលីពីនសម្រេចបាននូវឋានៈជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០២២, ភាពក្រីក្រនឹងថយចុះពី ៣០% នៅឆ្នាំ២០១៥ ដល់ ២០% នៅឆ្នាំ២០២២,អត្រានិកម្មភាពនឹងធ្លាក់ចុះពី ៥.៥% ទៅចន្លោះ ៣-៥ % នៅឆ្នាំ២០២២ ។

*ក្រៅពីការតាមដាន និងវាយតម្លៃទៅលើសមិទ្ធកម្មតាមរយៈទិន្នន័យជារបាយការណ៍ ហ្វីលីពីនបានផ្តួចផ្តើមនូវគម្រោងឌីជីថល (Digital Imaging for Monitoring and Evaluation-DIME) ដែលជាការចាំបាច់សម្រាប់ប្រមូលព័ត៌មានសមិទ្ធកម្មផ្អែកលើភស្តុតាង*

PDP គាំទ្រដោយសសរស្តម្ភចំនួន ៣ រួមមាន÷

**១)ការលើកកម្ពស់របៀបរៀបរយសង្គម (Enhancing the Social Fabric) :** លើកកម្ពស់ទំនុកចិត្តកាន់តែខ្លាំងលើស្ថាប័នសាធារណៈ និងសង្គម, ពង្រឹងប្រសិទ្ធភាព យុត្តិធម៌ និងភាពស្អាតស្អំក្នុងវិស័យសាធារណៈ, លើកកម្ពស់ការយល់ដឹង និងការគោរពចំពោះវប្បធម៌ចម្រុះ។

**(២) កាត់បន្ថយវិសមភាព (Inequality educing transformation):** ពង្រីកឱកាសសេដ្ឋកិច្ចតាមរយៈទីផ្សារក្នុងស្រុក និងពិភពលោក, ផ្តល់ភាពងាយស្រួលក្នុងការចាប់យកឱកាសទាំងនោះ និងការយកចិត្តទុកដាក់ជាពិសេសលើក្រុមប្រជាជនដែលរស់នៅក្នុងជីវភាពលំបាក ។

**(៣) បង្កើនសក្តានុពលកំណើន (Increasing Growth Potential) :** រដ្ឋាភិបាលនឹងផ្តោតលើបច្ចេកវិទ្យាទំនើប និងលើកទឹកចិត្តចំពោះនវានុវត្តន៍ ជាពិសេសលើការស្រាវជ្រាវ និងអភិវឌ្ឍន៍។ ទន្ទឹមនេះ ដើម្បីពន្លឿនកំណើនសេដ្ឋកិច្ច, រដ្ឋាភិបាលត្រូវគ្រប់គ្រងកំណើនប្រជាជន និងបង្កើនការវិនិយោគលើការអភិវឌ្ឍធនធានមនុស្ស ។ ការធានាបាននូវមូលដ្ឋានម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយជាយុទ្ធសាស្ត្រ, និងការកសាងគោលការណ៍ចម្បងសម្រាប់សន្តិសុខ, សន្តិភាព និងសុវត្ថិភាព, ហេដ្ឋារចនាសម្ព័ន្ធ, និងបរិស្ថាន គឺជាកត្តាដ៏សំខាន់ក្នុងការគាំទ្រដល់ការអនុវត្ត PDP។

## ក្របខណ្ឌអាទិភាពថវិកា (Budget Priorities Framework-BPF)÷

ក្របខណ្ឌអាទិភាពថវិកាដំបូងគេត្រូវបានបោះផ្សាយសម្រាប់ថវិកាជាតិឆ្នាំសារពើពន្ធ២០១៥ (FY 2015 National Budget)។ សម្រាប់ឆ្នាំសារពើពន្ធ២០១៩ ឆ្លុះបញ្ចាំងលើ ៣ ទិដ្ឋភាព រួមមាន÷ ១)បរិការណ៍ម៉ាក្រូសេដ្ឋកិច្ចសម្រាប់ថវិកាឆ្នាំ២០១៩, ២)កម្មវិធីហិរញ្ញវត្ថុ (Fiscal Program), ៣)អាទិភាពថវិកា (budget Priorities)។ ថវិកាឆ្នាំ២០១៩ ផ្តោតសំខាន់លើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ក្រោម

កម្មវិធី Build Build Build និងសេវាសង្គម ដែលផ្តោតលើ, ការធានានូវនិរន្តរភាពហិរញ្ញវត្ថុសម្រាប់កម្មវិធីអប់រំ, គាំទ្រដល់ជនជាតិដើមភាគតិច និងជនពិការ, បង្កើនអាហារូបត្ថម្ភប្រកបដោយគុណភាព និងពិពិធកម្មគម្រោងផ្ទេរសាច់ប្រាក់ និងកំណែទម្រង់ពន្ធដារ (Tax Reform Cash Transfer Project )

### 2-Tier Budgeting Approach - 2TBA

គោលបំណងនៃការគ្រោង និងការរៀបចំថវិកាអនុលោមតាម 2TBA គឺដើម្បីធានាថាសំណើថវិកាថ្មី និងថវិកាកំពុងអនុវត្តមានសង្គតិភាព ទៅនឹងអាទិភាពគោលនយោបាយ និងថវិកាប្រចាំឆ្នាំ ព្រមទាំងត្រូវតម្រឹមជាមួយធនធាននិងគោលដៅគោលនយោបាយរបស់រដ្ឋាភិបាល។ លក្ខណៈពិសេសនៃ 2TBA គឺសំណើថវិកាសរុបត្រូវប្ញូកបញ្ចូលគ្នារវាង TIER1 ( គោលនយោបាយឬគម្រោងដែលកំពុងអនុវត្ត) និង TIER2 ( សំណើថវិកាថ្មី)។

### បញ្ហាប្រឈម និងការអនុវត្តថវិកាពាក់ព័ន្ធនឹងកិច្ចលទ្ធកម្ម

#### បញ្ហាប្រឈម

ការទម្លាក់ថវិកាទាបជាងការគ្រោងទុក (Low Disbursement) គឺជាបញ្ហាប្រឈមដែលនឹងមានបច្ច័យដល់កំណើនផលិតផលក្នុងស្រុកសរុប (GDP Growth) និងការបម្រើសាវាសាធារណៈ ជូនប្រជាពលរដ្ឋ ។ ការចំណាយទាបជាងផែនការនៅតែបន្តចោទជាបញ្ហាប្រឈមនៅហ្វីលីពីន។

#### ការអនុវត្តកិច្ចលទ្ធកម្មមុន (Early Procurement)

ដើម្បីដោះស្រាយនូវបញ្ហា នៃការអនុវត្តកិច្ចលទ្ធកម្ម ហ្វីលីពីនបានអនុវត្តនីតិវិធីកិច្ចលទ្ធកម្មមុន មានន័យថាការអនុវត្តការដេញថ្លៃក្នុងអំឡុង ខែតុលា ដល់ខែធ្នូនៃឆ្នាំសារពើពន្ធ មុនកម្មវិធីចំណាយជាតិ ឬច្បាប់ឥណទានទូទៅ (NEP/GAA) ត្រូវបានដាក់ឆ្លងសភាអនុម័តក្នុងអំឡុង ខែធ្នូនៃឆ្នាំសារពើពន្ធ។ រីឯការប្រគល់កិច្ចសន្យាគឺត្រូវផ្តល់ជូន ស្របពេលនឹងការអនុម័តច្បាប់ឥណទានទូទៅ។ បន្ទាប់ពីច្បាប់ឥណទានទូទៅត្រូវផ្សព្វផ្សាយក្នុងខែមករានៃឆ្នាំបន្ទាប់, រដ្ឋាភិបាល នឹងរៀបចំបញ្ជីវិភាជលម្អិតតាមស្ថាប័ន (Special Allotment Release Order-SARO) ដូចនេះ ការអនុវត្តថវិកាតាមកិច្ចលទ្ធកម្មនឹងអាចចាប់ផ្តើមក្នុងខែមករា តែម្តង។

#### ការតាមដាន និងវាយតម្លៃសមិទ្ធកម្ម

ក្រៅពីការតាមដាន និងវាយតម្លៃទៅលើសមិទ្ធកម្មតាមរយៈទិន្នន័យជារបាយការណ៍ ហ្វីលីពីនបានផ្តួចផ្តើមនូវគម្រោងឌីជីថល




(Digital Imaging for Monitoring and Evaluation-DIME) ដែលជាការចាំបាច់សម្រាប់ប្រមូលព័ត៌មានសមិទ្ធកម្មផ្អែកលើភស្តុតាង។ការផ្តួចផ្តើមនូវ DIME នេះគឺក្នុងគោលបំណងតាមដាន នូវគម្រោងរដ្ឋាភិបាលដែលមានការចំណាយខ្ពស់ ដោយធ្វើការប្រៀបធៀប រវាងការប្រើប្រាស់ថវិកា និងលទ្ធផលជាក់ស្តែង សំដៅដល់សមិទ្ធផលរូបវន្ត។ ក្នុងការអនុវត្តនេះ ហ្វីលីពីនបានប្រើប្រាស់នូវបច្ចេកវិទ្យារូបភាព និងទិន្នន័យឌីជីថល (Digital Data and Imaging Technologies-DDIT) និងបច្ចេកវិទ្យាញ្ញាញពីចម្ងាយ (Remote Sensing Technologies) ដែលរួមមានឧបករណ៍ដូចជា÷ Light Detection and Ranging (LiDAR) មានសមត្ថភាពអាចឆ្លុះមើលទិន្នន័យនៅក្នុងព្រៃក្រាស់ ដោយចាប់យកចំនួនជាក់លាក់ក្នុងទំហំដី១ម៉ែត្រការ៉េ ( ឧ. ការពិនិត្យមើលចំនួនដើមឈើ), Satellites អាចពិនិត្យមើលភាពប្រែប្រួលនៃទំហំដី ឬទំហំព្រៃ, Open Roads platform/Geo-store អាចតាមដាន និងពិនិត្យមើលពីចម្ងាយលើ ស្ថានភាពផ្លូវជាក់ស្តែង ឬក្នុងរួមទាំងផ្លូវដែលសាងសង់រួច និងកំពុងសាងសង់។ Geo-tagging តម្រូវឱ្យមន្ត្រីត្រូវផ្ចិតយករូបភាព និងវីដេអូ ភ្ជាប់ជាមួយទីតាំងនៃគម្រោង រួចបង្ហោះចូលទៅក្នុងប្រព័ន្ធផ្សព្វផ្សាយ ដូចជា Facebook ឬ Google ជាដើម ក្នុងគោលបំណងធានាតម្លាភាពក្នុងការអនុវត្តគម្រោងរបស់រដ្ឋាភិបាល ។■ *រៀបចំដោយ÷ អ.គ.ហ.*

គន្ធនិទ្ទេស÷

*១. ទស្សនវិស័យឆ្នាំ២០៤០ របស់រដ្ឋាភិបាលហ្វីលីពីន (Ambisyon Natin 2040)*
*២. ផែនការអភិវឌ្ឍន៍ហ្វីលីពីន ឆ្នាំ២០១៧ - ២០២២*
*៣. ក្របខណ្ឌអាទិភាពថវិកា ឆ្នាំ២០១៩ របស់រដ្ឋាភិបាលហ្វីលីពីន*
*៤. បទបង្ហាញស្តីពីថវិកាព័ត៌មានសមិទ្ធកម្មរបស់នាយកដ្ឋានគ្រប់គ្រងនិងថវិកា (DBM) នៃរដ្ឋាភិបាលហ្វីលីពីន*




# ក្របខ័ណ្ឌលទ្ធផលរវាងរាជរដ្ឋាភិបាលកម្ពុជា និងសហភាពអ៊ឺរ៉ុបឆ្នាំ២០១៩-២០២០

*កិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណងរវាងរាជរដ្ឋាភិបាលកម្ពុជា និងសហភាពអ៊ឺរ៉ុប ២០១៩-២០២០ លើកទី២ គាំទ្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ ក្នុងគោលបំណងដើម្បីកែលម្អការផ្តល់សេវាធារណៈ និងជំរុញកំណើនសេដ្ឋកិច្ច។*

អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ **(អ.គ.ហ.)** ជាសេនាធិការ នៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សហការជាមួយអង្គភាពពាក់ព័ន្ធ និងប្រតិភូសហភាពអ៊ឺរ៉ុបប្រចាំព្រះរាជាណាចក្រកម្ពុជា បានរៀបចំកិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណង ឆ្នាំ២០១៩-២០២០ ដែលសហភាពអ៊ឺរ៉ុបនឹងបន្តផ្តល់ហិរញ្ញប្បទានឥតសំណងបន្ថែមប្រមាណ ២២លានអឺរ៉ូ ក្នុងនោះរាជរដ្ឋាភិបាលកម្ពុជាទទួលបាន ១៤ លានអឺរ៉ូដោយទទួលការឯកភាពនៅថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០១៩។ កិច្ចព្រមព្រៀងលើកទី ២ ផ្តោតលើលទ្ធផលចុងក្រោយចំនួន៨ រួមមាន (១) ការកសាងសមត្ថភាពត្រូវបានពង្រឹង ÷ ចំនួនមន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលបច្ចេកទេស, (២) ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានកែលម្អ, (៣) សុក្រឹតភាពនិងតម្លាភាពថវិកានៃការផ្ទេរថវិកាទៅថ្នាក់ក្រោមជាតិ ត្រូវបានពង្រឹង, (៤) សមត្ថភាព និងតម្លាភាពនៃអាជ្ញាធរសវនកម្មជាតិ, (៥) ការអនុវត្តថវិកាឆ្ពោះទៅសមិទ្ធកម្មត្រូវបានបង្កើន, (៦) ការគ្រប់គ្រងវិនិយោគសាធារណៈត្រូវបានកែលម្អ, (៧) ការកៀរគរចំណូលក្នុងស្រុកត្រូវបានពង្រឹង និង (៨) តម្លាភាពនិងប្រសិទ្ធភាព នៃលទ្ធកម្មសាធារណៈ ត្រូវបានបង្កើន។

ដើម្បីឱ្យការអនុវត្តសម្រេចបានតាមគោលដៅឆ្នាំ២០១៩ និង២០២០ អ.គ.ហ. បានតាមដានត្រួតពិនិត្យវឌ្ឍនភាពប្រចាំត្រីមាស និងសហការជាមួយគ្រប់ស្ថាប័នពាក់ព័ន្ធ ធ្វើការវាយតម្លៃប្រចាំឆ្នាំលើលទ្ធផលសម្រេចបាន៕

**តារាងក្របខ័ណ្ឌលទ្ធផលឆ្នាំ២០១៩-២០២០**

| លទ្ធផលចុងក្រោយ | គោលដៅសូចនាករឆ្នាំ ២០១៩ | គោលដៅសូចនាករឆ្នាំ ២០២០ |
| --- | --- | --- |
| ១.ការកសាងសមត្ថភាពត្រូវបានពង្រឹង÷ ចំនួនមន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលបច្ចេកទេស | មន្ត្រីរាជការចំនួន ១០៤៥ នាក់ត្រូវបានប៉ាន់ស្មានចូលរួមវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសពាក់ព័ន្ធសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | មន្ត្រីរាជការចំនួន ១១៥០ នាក់ ត្រូវបានប៉ាន់ស្មានចូលរួមវគ្គបណ្តុះបណ្តាលបច្ចេកទេស ពាក់ព័ន្ធសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ២. ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានកែលម្អ | ១). FMIS ត្រូវដំឡើងដល់ក្រសួង-ស្ថាប័នចំនួន ២០ និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រាជធានី-ខេត្តទាំង ២៥។ ២). ម៉ូឌុល FMIS ថ្មី រួមមានការរៀបចំថវិកានិង ការគ្រប់គ្រងលទ្ធកម្មនិងកិច្ចសន្យា ត្រូវដាក់ឱ្យដេញថ្លៃ | i). FMIS ត្រូវបានដំឡើង និងដាក់ឱ្យដំណើរការគ្រប់ក្រសួង-ស្ថាប័ន និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>ii). ម៉ូឌុល FMIS ថ្មី ត្រូវបានដាក់ឱ្យអនុវត្តសាកល្បងក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ៣. សុក្រឹតភាព និងតម្លាភាពថវិកានៃការផ្ទេរថវិកាទៅថ្នាក់ក្រោមជាតិត្រូវបានពង្រឹង÷ ការអនុវត្តថវិកាកម្មវិធីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | គោលការណ៍ណែនាំស្តីពីការវាយតម្លៃសមិទ្ធកម្មប្រចាំឆ្នាំសម្រាប់ក្រុង ខណ្ឌ តាមរយៈយន្តការ SNIF ត្រូវបានរៀបចំ និងអនុម័ត | រដ្ឋបាលខេត្តចំនួន ២៤ ត្រូវបានដាក់ឱ្យអនុវត្តថវិកាកម្មវិធី |
| ៤.សមត្ថភាព និងតម្លាភាពនៃអាជ្ញាធរសវនកម្មជាតិ÷សវនកម្មលើកិច្ចប្រតិបត្តិការ/ សមិទ្ធកម្ម | គោលការណ៍ណែនាំស្តីពីសវនកម្មកិច្ចប្រតិបត្តិការ/ សមិទ្ធកម្មត្រូវបានបញ្ចប់ | កម្មវិធីនិងឯកសារបណ្តុះបណ្តាលស្តីពីសវនកម្មកិច្ចប្រតិបត្តិការ/ សមិទ្ធកម្មត្រូវបានរៀបចំ |
| ៥.ការអនុវត្តថវិកាឆ្ពោះទៅសមិទ្ធកម្មត្រូវបានបង្កើន | ក្របខ័ណ្ឌថវិការយៈពេលមធ្យម ២០២០-២០២២ ត្រូវបានអនុម័តដោយរាជរដ្ឋាភិបាល | សេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ត្រូវបាន បញ្ជូនទៅគណៈរដ្ឋមន្ត្រី |
| ៦.ការគ្រប់គ្រងវិនិយោគសាធារណៈ ត្រូវបានកែលម្អ | អនុក្រឹត្យស្តីពីគោលការណ៍ណែនាំរួមនៃការគ្រប់គ្រងវិនិយោគសាធារណៈ ត្រូវបានអនុម័ត | ១)អនុក្រឹត្យស្តីពីការដាក់ឱ្យប្រើប្រាស់នីតិវិធីអនុវត្តស្តង់ដារសម្រាប់ការគ្រប់គ្រងការវិនិយោគសាធារណៈ ដោយហិរញ្ញប្បទានបរទេស ត្រូវបានអនុម័ត។ ២)អនុក្រឹត្យស្តីពីការដាក់ឱ្យប្រើប្រាស់នីតិវិធីអនុវត្តស្តង់ដារសម្រាប់ការគ្រប់គ្រងការវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន។ ៣)សេចក្តីព្រាងចុងក្រោយអនុក្រឹត្យស្តីពីការដាក់ឱ្យប្រើប្រាស់នីតិវិធីអនុវត្តស្តង់ដារសម្រាប់ការគ្រប់គ្រងការវិនិយោគសាធារណៈដោយថវិកាថ្នាក់ជាតិត្រូវបានដាក់ឱ្យប្រជុំពិភាក្សាអន្តរក្រសួង។ ៤)សេចក្តីព្រាងចុងក្រោយអនុក្រឹត្យស្តីពីការដាក់ឱ្យប្រើប្រាស់នីតិវិធីអនុវត្តស្តង់ដារសម្រាប់ការគ្រប់គ្រងការវិនិយោគសាធារណៈដោយថវិកាថ្នាក់ក្រោមជាតិ ត្រូវបានដាក់ប្រជុំពិភាក្សាជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ។ |
| ៧.ការកៀរគរចំណូលក្នុងស្រុកត្រូវបានពង្រឹង | កំណើនចំណូលចរន្តជាពិន្ទុភាគរយ ធៀបនឹង ផ.ស.ស. | កំណើនចំណូលចរន្តជាពិន្ទុភាគរយធៀបនឹង ផ.ស.ស. |
| ៨.តម្លាភាព និងប្រសិទ្ធភាពនៃលទ្ធកម្មសាធារណៈត្រូវបានបង្កើន | គោលការណ៍ណែនាំស្តីពីផែនការលទ្ធកម្មភ្ជាប់ជាមួយសំណើថវិកាត្រូវបានអនុម័ត | ស្ថិតិលទ្ធកម្មសាធារណៈសម្រាប់គម្រោងថវិកាជាតិ ត្រូវបានរៀបចំ និងផ្សព្វផ្សាយលើគេហទំព័ររបស់អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ |

*រៀបចំដោយ÷ អ.គ.ហ.*

# ភាពជាដៃគូថ្មីក្នុងការគាំទ្រកំណើនសេដ្ឋកិច្ចនៅកម្ពុជា

*ប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើនកំពុងតែជួបប្រទះនឹងការលំបាកក្នុងការសម្រេចបាននូវតម្រូវការមូលធនសម្រាប់ការអភិវឌ្ឍសង្គម និងហេដ្ឋារចនាសម្ព័ន្ធ នៅខណៈពេលដែលថវិកាជាតិ និងហិរញ្ញប្បទាន អភិវឌ្ឍន៍ផ្លូវការ (ODA)[១] សម្រាប់រដ្ឋាភិបាលនៅមានកម្រិត ។ ហេតុនេះហើយ, វិស័យឯកជនបាននិងកំពុងដើរតួនាទីយ៉ាងសំខាន់ ដែលជាផ្នែកមួយនៃលំហូរហិរញ្ញវត្ថុដ៏ធំសម្រាប់បណ្ដាប្រទេសកំពុងអភិវឌ្ឍន៍។*

គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs)[២] ក៏បានគូសបញ្ជាក់ឆ្លុះបញ្ចាំងពីសារៈសំខាន់ចំពោះភាពជាដៃគូរវាងរដ្ឋ និងវិស័យឯកជនក្នុងការចូលរួមដោះស្រាយនូវរាល់ការប្រឈមនានា នៃការអភិវឌ្ឍរបស់រដ្ឋាភិបាលផងដែរ ។

កំណើន នៃផសស ក្នុងរង្វង់៧%[៣] ចាប់ពីឆ្នាំ២០១១ រហូតមក។ របាយការណ៍នេះនឹងធ្វើឱ្យដៃគូអភិវឌ្ឍន៍ខ្លះពិចារណាបន្ថយ ឬកែប្រែលក្ខខ័ណ្ឌផ្សេងនៃហិរញ្ញប្បទានរបស់ខ្លួន ខណៈសម្ពាធពីការប្រកួតប្រជែងក្នុងសមាហរណកម្មសេដ្ឋកិច្ច តំបន់ និងសកលោក ដែលអាចនាំទៅដល់ការកាត់ដែលកម្ពុជានឹងត្រូវការចំណាយកាន់តែច្រើនឡើងៗលើការកសាងហេដ្ឋារចនាសម្ព័ន្ធ និងការពង្រឹងការផ្តល់សេវាសាធារណៈ ក្នុងការធានាសម្រេចគោលដៅអភិវឌ្ឍន៍យូរអង្វែងរបស់ខ្លួន។ ក្នុងន័យនេះ កម្ពុជាចាំបាច់ត្រូវពង្រឹងប្រភពធនធានហិរញ្ញវត្ថុក្នុងស្រុកសម្រាប់ប្រតិបត្តិការ



ក្នុងបរិការណ៍កម្ពុជា, ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់ផ្សេងៗ, កម្ពុជាទទួលបានឋានៈជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាបក្នុងឆ្នាំ២០១៥ ជាមួយនឹងអត្រា

បន្ថយ ឬ ការបាត់បង់ទាំងស្រុងនូវការអនុគ្រោះផ្នែកពាណិជ្ជកម្មពីដៃគូអភិវឌ្ឍន៍នានា។ ហេតុនេះ, កម្ពុជាត្រូវត្រៀមខ្លួនក្នុងការគ្រប់គ្រងប្រភពហិរញ្ញវត្ថុ ដើម្បីអភិវឌ្ឍប្រកបដោយចីរភាព នៅខណៈពេល

រដ្ឋបាល និងការអភិវឌ្ឍ ជាពិសេសការពឹងផ្អែកលើមូលដ្ឋានហិរញ្ញវត្ថុផ្ទាល់ខ្លួន ឬក្នុងស្រុក ដោយចៀសវាងការពឹងផ្អែកទាំងស្រុង ឬភាគច្រើនលើមូលនិធិពីម្ចាស់ជំនួយ ឬ ប្រទេសជាមិត្ត។ ដើម្បីសម្រេចបាន

[១] Official Development Assistance

[២] Sustainable Development Goals (SDGs) 2015

[៣] គេហទំព័រក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ៖ http://www.mef.gov.kh

នូវគោលដៅអភិវឌ្ឍន៍ជាតិប្រកបដោយកំណើន និងចីរភាព។ កម្ពុជាត្រូវបន្តខិតខំចំរាញ់យកសក្តានុពលនៃកាលានុវត្តភាពដែលមានស្រាប់ និងពង្រឹងអំណោយផលនិងឱកាសពីទីផ្សារថ្មីៗបន្ថែមទៀត ដើម្បីជំរុញការវិនិយោគទាំងក្នុង និងក្រៅប្រទេស ជាពិសេស សក្តានុពលនៃវិស័យហិរញ្ញវត្ថុដែលមានស្រាប់ដូចជាធនាគារ ធានារ៉ាប់រង និងទីផ្សារមូលបត្រ ដែលដើរតួនាទីសំខាន់ក្នុងការកៀរគរប្រភពធនធានក្នុងប្រទេស។ ក្រៅពីនេះ, មូលបត្ររដ្ឋក៏នឹងត្រូវដើរតួនាទីសំខាន់ក្នុងការកៀរគរប្រភពទុនសម្រាប់រដ្ឋាភិបាលផងដែរ។

*កម្ពុជាចាំបាច់ត្រូវពង្រឹងប្រភពធនធានហិរញ្ញវត្ថុក្នុងស្រុកសម្រាប់ប្រតិបត្តការរដ្ឋបាល និងការអភិវឌ្ឍ ជាពិសេសការពឹងផ្អែកលើមូលដ្ឋានហិរញ្ញវត្ថុផ្ទាល់ខ្លួន ឬក្នុងស្រុក ដោយជៀសវាងការពឹងផ្អែកទាំងស្រុង ឬភាគច្រើនលើមូលនិធិពីម្ចាស់ជំនួយ ឬប្រទេសជាមិត្ត ។*

កិច្ចប្រឹងប្រែងក្នុងការជំរុញភាពជាដៃគូរវាងរដ្ឋនិងឯកជន បាននិងកំពុងផ្តល់វិភាគទានជាច្រើន ក្នុងការបង្កើតឱកាសការងារ ការអភិវឌ្ឍធនធានមនុស្ស ការពង្រឹងបច្ចេកវិទ្យាឈានមុខ និងគំនិតធុរកិច្ចជាច្រើន សម្រាប់បរិការណ៍សកលភាវូបនីយកម្ម និងបដិវត្តឧស្សាហកម្មទី៤ ។ នៅខណៈពេលដែលថវិកាជាតិនៅមានកម្រិត ភាពជាដៃគូរវាងរដ្ឋ និងឯកជន គឺជាដំណោះស្រាយមួយដែលធានាចីរភាពកំណើន។ ដើម្បីឆ្លើយតបទៅនឹងការវិវឌ្ឍតឈប់ឈរ ជាពិសេសការថយចុះនៃជំនួយក្រៅប្រទេស កម្ពុជាបានរៀបចំឯកសារគោលនយោបាយ ស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់គ្រប់គ្រងគម្រោង វិនិយោគសាធាណៈ ២០១៦-២០២០។ ជាមួយគ្នានេះ ដើម្បីប្រែក្លាយកម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ២០៣០ និងជាប្រទេសចំណូលខ្ពស់ត្រឹមឆ្នាំ២០៥០, ការកសាងការវិនិយោគហេដ្ឋារចនាសម្ព័ន្ធប្រកបដោយគុណភាព គឺជាកត្តាគន្លឹះដែលធ្វើឱ្យកម្ពុជាមានឧត្តមភាពប្រកួតប្រជែងនៅក្នុងតំបន់ និងឆ្ពោះទៅរកកំណើនសេដ្ឋកិច្ចស្របទៅតាមចក្ខុវិស័យ ដូចបានកំណត់របស់រាជរដ្ឋាភិបាល។ ទន្ទឹមនេះ ឯកសារគោលនយោបាយខាងលើ, ផែនទីបង្ហាញផ្លូវសម្រាប់អនុវត្តគោលនយោបាយយុទ្ធសាស្រ្តចតុកោណ ដំណាក់កាលទី៤ ត្រូវបានបង្ហាញនៅក្នុង ផែនការអភិវឌ្ឍន៍យុទ្ធសាស្រ្តជាតិ ២០១៤-២០១៨ និងផែនការអភិវឌ្ឍន៍យុទ្ធសាស្រ្តជាតិឆ្នាំ ២០១៩ - ២០២៣។ លើសពីនេះ, យើងមានគោលនយោបាយ អភិវឌ្ឍន៍វិស័យឧស្សាហកម្ម ២០១៥-២០២៥, កម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល និងគោលនយោបាយតាមវិស័យ។ ដើម្បីឱ្យការងារវិនិយោគសាធារណៈនេះមានក្របខ័ណ្ឌច្បាស់លាស់, ការធ្វើទំនើបកម្មក្របខ័ណ្ឌ ការគ្រប់គ្រងការវិនិយោគសាធារណៈនឹងត្រូវដាក់ចេញនូវបទប្បញ្ញត្តិ ដើម្បីធ្វើការ គ្រប់គ្រងកំណត់អត្តសញ្ញាណ, ការជ្រើសរើស, ការរៀបចំ, ការអនុម័ត, ការអនុវត្ត, ការត្រួតពិនិត្យ, ការគ្រប់គ្រងទ្រព្យ និងការវាយតម្លៃគម្រោងវិនិយោគសាធារណៈ។ ក្របខ័ណ្ឌវិនិយោគសាធារណៈនេះនឹងត្រូវអនុវត្តរាល់ការវិនិយោគសាធារណៈតាមរយៈអនុក្រឹត្យស្តីពីការគ្រប់គ្រងការវិនិយោគសាធារណៈ ដែលនឹងត្រូវអនុវត្តរាល់គម្រោងសាធារណៈទាំងឡាយ ជាពិសេសធានាបាននូវការគ្រប់គ្រងការវិនិយោគសាធារណៈដ៏រឹងមាំ និងគួរទុកចិត្តបាន។ ហេតុនេះ, ភាពជាដៃគូរវាងរដ្ឋនិងឯកជន នឹងដើរតួនាទីកាន់តែសំខាន់ និងជាយន្តការគន្លឹះ សម្រាប់ពង្រឹងគុណភាពនៃហេដ្ឋារចនាសម្ព័ន្ធ និងសេវាជាមួយនឹងវិស័យឯកជន។ តាមរយៈយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជននេះ, គម្រោងវិនិយោគហេដ្ឋារចនាសម្ព័ន្ធនានានឹងត្រូវបានពង្រីក ។ ការវិនិយោគហេដ្ឋារចនាសម្ព័ន្ធនឹងជួយពន្លឿនកំណើនប្រកបដោយបរិយាប័ន្ន ជាពិសេសនឹងជួយលើកកម្ពស់ចំណូលនៅតំបន់ជនបទក្រីក្រតាមរយៈការពង្រឹងចលភាពទីផ្សារ ។

ក្រោមការដឹកនាំមុខដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានបង្កើតអង្គភាពភាពជាដៃគូរវាងរដ្ឋ និងឯកជនថ្នាក់កណ្តាល[4] ដែលមានតួនាទីសំខាន់ក្នុងការសម្របសម្រួល និងគ្រប់គ្រងប្រតិបត្តិការនៃគម្រោងវិនិយោគតាមរយៈយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន និងពិនិត្យ និងតាមដានគម្រោងវិនិយោគនៅតាមដំណាក់កាលនីមួយៗជាដើម។ ជាមួយនឹងការកែទម្រង់រចនាសម្ព័ន្ធដែលកំពុងបន្តក្នុងនោះរួមមានការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនឹងជំរុញការប្រកួតប្រជែងខាងក្រៅរបស់កម្ពុជា និងជួយពន្លឿនសន្ទុះកំណើន រយៈពេលវែង និងការរក្សាបាននូវចីរភាព។

ភាពជាដៃគូរវាងរដ្ឋនិងឯកជន ត្រូវបានគេឃើញថា ជាប្រភេទកិច្ចសន្យាពិសេសពាក់ព័ន្ធនឹងកិច្ចសន្យាហេដ្ឋារចនាសម្ព័ន្ធនានាដូចជាការសាងសង់ និងការបំពាក់ឧបករណ៍សាលារៀន, មន្ទីរពេទ្យ, ប្រព័ន្ធដឹកជញ្ជូន, ប្រព័ន្ធទឹកជាដើម។ ជាករណីសិក្សាជាក់ស្តែង, នៅខែមិថុនា ឆ្នាំ២០១៥[5], ទីភ្នាក់ងារ JICA ជប៉ុន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងកម្ចី សម្រាប់គម្រោងអភិវឌ្ឍន៍មជ្ឈមណ្ឌលសង្គ្រោះជីវិតបន្ទាន់នៅកម្ពុជា ជាមួយនឹងមន្ទីរពេទ្យ Sunrise Healthcare Service Co.,Ltd (SHS) ដែលគម្រោងមន្ទីរពេទ្យសាន់រ៉ាយ ជប៉ុននេះ ត្រូវបានចងសម្ព័ន្ធរវាងក្រុមហ៊ុន GJC Corporation, ក្រុមហ៊ុន INCJ, និងក្រុម

*[4] ប្រកាសស្តីពីការបង្កើតអង្គភាពភាពជាដៃគូរវាងរដ្ឋនិងឯកជនថ្នាក់កណ្តាល ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៧។ [5] របាយការណ៍ប្រចាំឆ្នាំរបស់ទីភ្នាក់ងារ JICA, ២០១៦*

ហ៊ុន Kitahara Medical Strategies International។ នេះជាហិរញ្ញប្បទានគម្រោងលើកដំបូងនៅក្រោមគម្រោងហិរញ្ញប្បទានវិនិយោគវិស័យឯកជន។ តាមរយៈការបង្កើតគម្រោង និងប្រតិបត្តិការ, មន្ទីរពេទ្យសាន់រ៉ាយជប៉ុន ផ្តល់នូវសេវាថែទាំសុខភាពប្រកបដោយគុណភាពនៅកម្ពុជា ព្រមទាំង ការប្រើប្រាស់បច្ចេកវិទ្យាថែទាំសុខភាព ដែលមានលក្ខណៈជាអន្តរជាតិ។ គម្រោងនេះបានបុកគ្រឹះនៅក្នុងឆ្នាំ២០១៥ និងមានដើមទុនវិនិយោគ៣៥ លានដុល្លារ រួមបញ្ចូលទាំងប្រាក់កម្ចីពីទីភ្នាក់ងារអភិវឌ្ឍន៍របស់ជប៉ុន (JICA) ផងដែរ។ មន្ទីរពេទ្យនេះចូលរួម ជាផ្នែកមួយ នៃហេដ្ឋារចនាសម្ព័ន្ធ ផ្នែកវេជ្ជសាស្ត្ររបស់ប្រទេសកម្ពុជា។ ក្រៅពីគម្រោងខាងលើ, គម្រោងផ្លូវល្បឿនលឿនភ្នំពេញ និងខេត្តព្រះសីហនុ ដែលបានបើកការដ្ឋាននៅថ្ងៃទី២២ ខែមីនា

*កិច្ចប្រឹងប្រែងក្នុងការជំរុញភាពជាដៃគូរវាងរដ្ឋនិងឯកជន បាននិងកំពុងផ្តល់វិភាគទានជាច្រើន ក្នុងការបង្កើតឱកាសការងារ ការអភិវឌ្ឍធនធានមនុស្ស ការពង្រឹងបច្ចេកវិទ្យាឈានមុខ និងគំនិតធុរកិច្ចជាច្រើន សម្រាប់បរិការណ៍សកលភាវូបនីយកម្ម និងបដិវត្តឧស្សាហកម្មទី ៤ ។*

ឆ្នាំ២០១៩[៦] ក្នុងការសាងសង់ផ្លូវដឹកជញ្ជូនថ្មីប្រវែងជាង១៩០[៧] គីឡូម៉ែត គឺជាគម្រោងហេដ្ឋារចនាសម្ព័ន្ធដ៏ធំមួយអនុវត្តក្រោមរូបភាព ភាពជាដៃគូរវាងរដ្ឋនិងឯកជន នេះផងដែរ ក្រោមការវិនិយោគដោយក្រុមហ៊ុន Cambodian PPSHV Expressway Co.,Ltd ក្នុងទឹកប្រាក់ ១,៩ ពាន់លានដុល្លារអាមេរិច ។ ការវិនិយោគលើគម្រោងផ្លូវល្បឿនលឿននេះ ត្រូវអនុវត្តតាមទម្រង់សាងសង់ប្រតិបត្តិផ្ទេរ (BOT)។

ជាការសន្និដ្ឋាន, ក្រោមលិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយពាក់ព័ន្ធសំខាន់ៗដែលមានរួមជាមួយនឹងការកសាងស្ថាប័នគាំទ្រការអភិវឌ្ឍភាពជាដៃគូថ្មីក្នុងការគាំទ្រកំណើនសេដ្ឋកិច្ចនៅកម្ពុជា បាននិងកំពុងធ្វើឱ្យកម្ពុជាបោះជំហានទៅមុខមិនរាថយ ដើម្បីកៀរគរប្រភពធនធានក្នុងស្រុកដែលមានសក្តានុពល យកមកប៉ះប៉ូវលើការខាតបង់នានាក្រោមការកាត់បន្ថយហិរញ្ញប្បទានអភិវឌ្ឍន៍ផ្លូវការ ឬ ការពឹងផ្អែកទាំងស្រុង ឬ មួយភាគធំទៅលើប្រទេសផ្តល់ជំនួយ។ ការពង្រឹងភាពជាដៃគូថ្មីនេះនឹងធ្វើឱ្យកម្ពុជាអាចទ្រទ្រង់ និងពង្រឹងការកសាងហេដ្ឋារចនាសម្ព័ន្ធនានាបាន ដើម្បីជាប្រយោជន៍ និងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋកម្ពុជា៕■

*រៀបចំដោយ÷ អ.គ.ហ.*




[៦] សារព័ត៌មាន The Phnom Penh Post, ចុះផ្សាយថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៩ ។ [៧] គេហទំព័រក្រសួងសាធារណការ និងដឹកជញ្ជូន÷ http://www.mpwt.gov.kh/kh/home

# សញ្ញាណទូទៅ នៃ "វិសហមជ្ឈការ" នៅកម្ពុជា

*នៅប្រទេសកម្ពុជា, "**វិសហមជ្ឈការ**" ត្រូវបានគេឮ និងចាប់ផ្តើមប្រើប្រាស់ទន្ទឹមគ្នានឹងពាក្យ "**វិមជ្ឈការ**" ដែរ ក្នុងអំឡុងឆ្នាំ២០០០ ពេលដែលរាជរដ្ឋាភិបាលកម្ពុជា កំពុងរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ ដែលក្រោយមកទៀត ត្រូវបានអនុម័ត និងប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលត្រូវបានអនុម័តនិងប្រកាស ដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅក្នុងកាលបរិច្ឆេទដូចគ្នា។*

ច្បាប់ទាំង២នេះ ជាមូលដ្ឋានគ្រឹះនៃប្រព័ន្ធរដ្ឋបាលវិមជ្ឈការ និងវិសហមជ្ឈការនៅប្រទេសកម្ពុជា ដែលជាច្បាប់បើកផ្លូវឈាន ទៅដល់ការបោះឆ្នោតជាសកលជ្រើសតាំងក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី១ និងជាលើកទី១ ក្នុងប្រវត្តិសាស្ត្រកម្ពុជា នៅក្នុងឆ្នាំ២០០២។

ផ្អែកលើការអនុវត្ត វិសហមជ្ឈការមានវត្តមានក្នុងប្រព័ន្ធរដ្ឋបាលសាធារណៈខ្មែរជាយូរយារណាស់មកហើយ គ្រាន់តែវាបានផ្លាស់ប្តូរមុខមាត់ជាច្រើនដងច្រើនសារតាមរយៈវិសោធនកម្មបន្តបន្ទាប់នៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តហើយត្រូវបានពង្រឹង និងធ្វើទំនើបកម្មឱ្យមានសង្គតិភាពនិងស៊ីចង្វាក់គ្នា ដើម្បីគាំទ្រនិងត្រួតពិនិត្យ ការអនុវត្តអំណាច នៅក្នុងប្រព័ន្ធថ្មីមួយទៀត គឺប្រព័ន្ធវិមជ្ឈការ ដែលជាប្រព័ន្ធថ្មីថ្មោង។ ការកែទម្រង់នេះ បានកាត់បន្ថយសមត្ថកិច្ចមួយចំនួនធំនៃអាជ្ញាធរវិសហមជ្ឈការ ដោយសមត្ថកិច្ចទាំងនោះត្រូវបានផ្ទេរទៅអោយអាជ្ញាធរនៃរដ្ឋបាលវិមជ្ឈការដែលតំណាងដោយក្រុមប្រឹក្សាវិញដែលកើតចេញពីការបោះឆ្នោត។ ទន្ទឹមនឹងការបាត់បង់សមត្ថកិច្ចនេះ រដ្ឋបាលវិសហមជ្ឈការក៏ទទួលបាននូវមុខងារ ភារកិច្ចថ្មីៗដែរ ជាពិសេសមុខងារក្នុងទំនាក់ទំនងជាមួយនឹងក្រុមប្រឹក្សា ដែលមុខងារនោះគឺជា ***មុខងារ*** ***ត្រួតពិនិត្យទៅលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា។***




### ក.និយមន័យ

ដូចគ្នានឹងវិមជ្ឈការដែរ, "**វិសហមជ្ឈការ**" មិនមានពន្យល់នៅក្នុងវចនានុក្រមខ្មែរនោះទេ ព្រោះជាពាក្យថ្មីដែលត្រូវបានបង្កើតនៅក្នុងអំឡុងឆ្នាំ២០០០ ដោយឥស្សរជនខ្មែរមួយរូប នៃរាជរដ្ឋាភិបាលកម្ពុជា ដូចធ្លាប់បានរៀបរាប់នៅក្នុងអត្ថបទស្តីពីវិមជ្ឈការ។ ទោះយ៉ាងណា យើងអាចយល់បានអំពីអត្ថន័យទូទៅ នៃពាក្យនេះ បានតាមរយៈវិធីសាស្ត្របំបែកពាក្យ។ វិមជ្ឈការ បានមកពី "**វិ-**" + "**មជ្ឈការ**"។ "**វិ-**" សំដៅដល់អ្វីដែលមិនមែនជា ឬដែលផ្ទុយពី។ "**សហ-**" មានន័យថា ជាមួយនឹង

ឬ រួមជាមួយ រីឯ “**មជ្ឈការ**” បានន័យថា ការធ្វើឱ្យទៅជាកណ្តាល។ដូចនេះ “**វិសហមជ្ឈការ**” បានសេចក្តីថា ការធ្វើមិនឱ្យទៅជាកណ្តាល ឬ អាចនិយាយបានថាការកាត់បន្ថយ ឬការបញ្ឈប់ឱ្យទៅជាថ្នាក់កណ្តាល ដោយសហការគ្នាទៅវិញទៅមក។

ក្នុងប្រព័ន្ធរដ្ឋបាលសាធារណៈ នៃរដ្ឋទោល (unitary state), វិសហមជ្ឈការ គឺជាកិច្ចដំណើរការបង្កើត នៅក្នុងមណ្ឌលរដ្ឋបាលមូលដ្ឋាន នូវអាជ្ញាធររដ្ឋបាលដែលតំណាងឱ្យរដ្ឋ (រដ្ឋបាលកណ្តាល)។ ផ្ទុយ



ពីអាជ្ញាធរវិមជ្ឈការ, អាជ្ញាធរវិសហមជ្ឈការទាំងនេះ មិនមានស្វ័យភាពណាមួយ ឬ មានបុគ្គលភាពគតិយុត្តឡើយ ហើយត្រូវគោរពនូវបទបញ្ជានៃអាជ្ញាធរថ្នាក់លើដោយគោរពទៅតាមគោលការណ៍ឋានានុក្រមនៃអំណាច។ ហេតុនេះហើយ ទើបច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី-ខេត្ត ក្រុង ស្រុក-ខណ្ឌ ឃុំ-សង្កាត់ បានកំណត់ថាតាមរយៈវិសហមជ្ឈការ, **រាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ន ធ្វើប្រតិភូកម្មមុខងារ សិទ្ធិអំណាច និងធនធានទៅអង្គភាពក្រោមបង្គាប់ ឬទៅក្រុមប្រឹក្សាប្រភេទណាមួយ ដើម្បីអនុវត្ត ក្នុងនាមរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ន។ អង្គភាព ឬ ក្រុមប្រឹក្សានោះ ត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ឬ ក្រសួង ស្ថាប័ន ស្របទៅតាមតម្រូវការនៃការធ្វើប្រតិភូកម្មនោះ។**

## ២.រចនាសម្ព័ន្ធរដ្ឋបាលវិសហមជ្ឈការ

មាត្រា១៣៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ បញ្ញត្តិថា ត្រូវរៀបចំឱ្យមានគណៈអភិបាលសម្រាប់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ក្រៅពីគណៈអភិបាល យើងសង្កេតឃើញមាន មន្ទីរក្រសួងនានារបស់រាជរដ្ឋាភិបាលតាំងទីនៅតាមខេត្តនីមួយៗ។ ដូចនេះ វិសហមជ្ឈការ មាន ២ ប្រភេទធំៗ គឺ ÷ **វិសហមជ្ឈការដែនដី និង វិសហមជ្ឈការតាមខ្សែបណ្តោយជំនាញ។**

### ២.១.វិសហមជ្ឈការដែនដី

វិសហមជ្ឈការដែនដី គឺជាកិច្ចដំណើរការក្នុងការរៀបចំរដ្ឋបាលសាធារណៈដោយបង្កើតឱ្យមាននូវ អាជ្ញាធររដ្ឋបាលមានសមត្ថកិច្ចទូទៅ នៅក្នុងមណ្ឌលរដ្ឋបាលមូលដ្ឋានដែនដីកំណត់មួយ។ ក្នុងន័យនេះ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់ការបែងចែក ជា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ ទាំងនេះ គ្រប់គ្រងដោយអាជ្ញាធររដ្ឋបាលមួយរៀងៗខ្លួន។ អាជ្ញាធរវិសហមជ្ឈការដែនដីដែលគ្រប់គ្រងនៅកម្រិតរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ហៅថា **គណៈអភិបាល** ដែលដឹកនាំដោយអភិបាលមួយរូប និងមានអភិបាលរងមួយចំនួន។ នៅកម្រិតឃុំ សង្កាត់ អាជ្ញាធរវិសហមជ្ឈការដែនដី ដឹកនាំដោយមេឃុំ និងចៅសង្កាត់ផ្ទាល់តែម្តង ដែលខុសពីកម្រិតខាងលើ មេឃុំ ចៅសង្កាត់នេះ កើតចេញពីការបោះឆ្នោតដោយប្រជាពលរដ្ឋ។

អភិបាលរាជធានី-ខេត្ត ត្រូវតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើនាយករដ្ឋមន្ត្រី និងតាមសេចក្តីស្នើសុំ ពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចំណែកឯអភិបាលរងរាជធានី អភិបាលរងខេត្ត អភិបាលក្រុង អភិបាលស្រុក អភិបាលខណ្ឌត្រូវតែងតាំងដោយអនុក្រឹត្យតាមសំណើរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ដោយឡែក អភិបាលរងក្រុង អភិបាលរងស្រុក អភិបាលរងខណ្ឌ ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ អភិបាល អភិបាលរងទាំងនេះ មានអាណត្តិការងារមិនលើសពីបួនឆ្នាំ តែអាចត្រូវបានតែងតាំងជាលើកទីពីរ នៅក្នុងដែនសមត្ថកិច្ចដដែល។ ដូចនេះ អាជ្ញាធរទាំងនេះ កើតចេញពីការតែងតាំង និងត្រូវគោរពអំណាចបទបញ្ជារបស់អាជ្ញាធរដែលមានឋានានុក្រមខ្ពស់ជាង ហើយថ្នាក់លើដែលជារដ្ឋបាលកណ្តាលអាចដកហូត ព្យួរ ឬផ្លាស់ប្តូរតំណែង របស់អភិបាលខេត្ត ក្រុង ស្រុក ខណ្ឌ ពេលណាក៏បាន។

ផ្ទុយពីកម្រិតរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, នៅកម្រិតឃុំ-សង្កាត់ មិនមានគណៈអភិបាលទេ គឺគ្រប់គ្រងដោយក្រុមប្រឹក្សាដែលជាអាជ្ញាធរមូលដ្ឋាន កើតចេញពីការបោះឆ្នោតតាមបែបវិមជ្ឈការ និងដឹកនាំដោយមេឃុំ-ចៅសង្កាត់។ ក្រៅពីមុខងារជាប្រមុខដឹកនាំការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សារបស់ខ្លួន, មេឃុំ-ចៅសង្កាត់នេះឯង ដែលជាអាជ្ញាធរវិសហមជ្ឈការបំពេញមុខងារតំណាងឱ្យរដ្ឋមានគណនេយ្យភាពចំពោះរដ្ឋផងដែរ។

គណៈអភិបាល និងមេឃុំ ចៅសង្កាត់ ជាស្ថាប័នដែលចំណុះក្រសួងមហាផ្ទៃផ្ទាល់

*ផ្អែកលើការអនុវត្ត វិសហមជ្ឈការ មានវត្តមានក្នុងប្រព័ន្ធរដ្ឋបាលសាធារណៈខ្មែរជាយូរយារណាស់មកហើយ គ្រាន់តែវាបានផ្លាស់ប្ដូរមុខមាត់ជាច្រើនដងច្រើនសារ តាមរយៈវិសោធនកម្មបន្តបន្ទាប់នៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ហើយត្រូវបានពង្រឹង និងធ្វើទំនើបកម្មឱ្យមានសង្គតិភាព និងស៊ីចង្វាក់គ្នា ដើម្បីគាំទ្រ និងត្រួតពិនិត្យការអនុវត្តអំណាច នៅក្នុងប្រព័ន្ធថ្មីមួយទៀតគឺ ប្រព័ន្ធវិមជ្ឈការ ដែលជាប្រព័ន្ធថ្មីថ្មោង។*

និងជាតំណាងរាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងដែនដី មានសមត្ថកិច្ចគ្រប់គ្រងលើវិស័យរដ្ឋបាល និងនយោបាយ ដោយធ្វើសេចក្ដីសម្រេចតាមការកំណត់ក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ។ដូចនេះ អភិបាល និងមេឃុំ ចៅសង្កាត់ មានកាតព្វកិច្ចត្រូវផ្ដល់ព័ត៌មាន និងធ្វើរបាយការណ៍ជូនក្រសួងមហាផ្ទៃ អំពីសភាពការណ៍ទូទៅក្នុងដែនដីដែលខ្លួនគ្រប់គ្រង។

## ខ.២.វិសហមជ្ឈការតាមខ្សែបណ្ដោយជំនាញ

វិសហមជ្ឈការជំនាញ ឬតាមខ្សែបណ្ដោយសំដៅដល់ដំណើរការមួយ ដែលក្រសួង-ស្ថាប័ននានារបស់រាជរដ្ឋាភិបាល មានអាជ្ញាធររបស់ខ្លួននៅតាមខេត្ត ក្រុង ដែលជាធម្មតា ហៅថា មន្ទីរ។ ជាវិសហមជ្ឈការតាមខ្សែបណ្ដោយ ព្រោះមន្ទីរទាំងនោះ ស្ថិតក្រោមអំណាចឋានានុក្រមរបស់ក្រសួងដែលជាអាណាព្យាបាលរបស់ខ្លួន។ ក្នុងដំណើរការនេះ មន្ទីរក្រសួងទាំងនោះ មានអំណាចសម្រេចអ្វីមួយទៅតាមលក្ខខណ្ឌដែលបានកំណត់ដោយក្រសួងនៅឯរាជធានីភ្នំពេញ។ ក៏ប៉ុន្តែ លើសពីនេះ មន្ទីរក្រសួងទាំងនោះក៏ត្រូវស្ថិតក្រោមឋានានុក្រមរបស់អាជ្ញាធរវិសហមជ្ឈការដែលជាអភិបាលខេត្តដែរ។

ជាធម្មតាក្រសួងមួយតែងមានមន្ទីររបស់ខ្លួនមួយនៅក្នុងរាជធានី និងគ្រប់ខេត្ត ដូចជាមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, មន្ទីរអប់រំ-យុវជន និងកីឡា និងមន្ទីរសុខាភិបាល ជាដើម ហើយក្រសួងសំខាន់ៗមួយចំនួនថែមទាំងមានការិយាល័យជំនាញរបស់ខ្លួននៅតាមក្រុង-ស្រុកផងដែរ ដូចជាការិយាល័យអប់រំ យុវជន និងកីឡា ឬការិយាល័យសុខាភិបាលជាដើម។ ក្រៅពីនេះ ក៏មានក្រសួងមួយចំនួន ដែលមានអង្គភាពជារដ្ឋបាលវិសហមជ្ឈការនៅថ្នាក់មូលដ្ឋាន ក្រៅពីមន្ទីរផងដែរ ដូចជាករណីនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលក្រៅពីមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានអង្គភាពមូលដ្ឋានផ្សេងទៀតដូចជា សាខាពន្ធដារ (នៅតាមរាជធានី ខេត្ត ក្រុង ស្រុក), សាខាគយ (នៅតាមរាជធានី-ខេត្ត និងមាត់ច្រក) និងរតនាគាររាជធានី-ខេត្ត។ ទន្ទឹមនេះ មានក្រសួងស្ថាប័នមួយចំនួនទៀត មិនមានមន្ទីរតំណាងរបស់ខ្លួនឡើយ តែមានអាជ្ញាធររដ្ឋបាលផ្សេងទៅវិញ ដូចជា ករណីក្រសួងមហាផ្ទៃ គ្មានឡើយនូវមន្ទីរមហាផ្ទៃតែមាននូវស្នងការនិងអធិការដ្ឋានពន្ធនាគារខេត្ត, ចំណែកឯក្រសួងយុត្តិធម៌ តំណាងដោយមហាអយ្យការនៅអមសាលាជំនុំជំរះក្ដីនីមួយៗ។ ករណីស្ថាប័នខ្លះទៀត មិនមាននូវអាជ្ញាធរមូលដ្ឋានឡើយ។

## គ. គោលបំណង នៃវិសហមជ្ឈការ

គ្មានឡើយ មជ្ឈការដាច់ខាត ហើយក៏មិនមានវិមជ្ឈការ ឬវិសហមជ្ឈការទាំងស្រុងនោះដែរ ព្រោះលំនាំដឹកនាំទាំង៣នេះតែង



**តែត្រូវការគ្នា ដើម្បីបំពេញឱ្យគ្នា និងគាំទ្រគ្នាទៅវិញទៅមកដោយមិនអាចកាត់ផ្ដាច់ចេញពីគ្នាបានឡើយ។** ដូចដែលបានពន្យល់ខាងលើ, រដ្ឋជាអ្នកបង្កើត, តែងតាំង និងប្រគល់សមត្ថកិច្ចជូនដល់អាជ្ញាធរនៅថ្នាក់មូលដ្ឋានហៅថា “**អាជ្ញាធរវិសហមជ្ឈការ**” ដែលខ្លួនបានប្រគល់សមត្ថកិច្ចជូន ដើម្បី ***ធ្វើសកម្មភាពក្នុងនាមរដ្ឋ***។ ពួកគេមិនមែនកើតចេញពីការជ្រើសតាំងដោយប្រជាពលរដ្ឋតាមរយៈការបោះឆ្នោតនោះទេ។ ដូចនេះ ទំនាក់ទំនងរវាងរដ្ឋបាលកណ្ដាល និងរដ្ឋបាលវិសហមជ្ឈការស្ថិតក្រោមវិធាន នៃអំណាចឋានានុក្រម បានសេចក្ដីថាអាជ្ញាធរវិសហមជ្ឈការ ត្រូវគោរពបទបញ្ជារបស់ថ្នាក់លើ។

មន្ត្រីរាជការទាំងឡាយនៅថ្នាក់ក្រោមជាតិទាំងនោះ អាចត្រូវបានតំឡើងឋានន្តរស័ក្ដទៅតាមឆន្ទានុសិទ្ធិរបស់អាជ្ញាធរថ្នាក់លើ ដែលមាននាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ជាដើម។ ម្យ៉ាងទៀត រដ្ឋបាលកណ្ដាលដែលជាអាជ្ញាធរថ្នាក់លើនេះ បញ្ជា និងត្រួតពិនិត្យលើអាជ្ញាធរថ្នាក់ក្រោមជាតិចំពោះការអនុវត្តបញ្ជា។ ក្នុងការអនុវត្តអំណាចនេះ អាជ្ញាធរថ្នាក់លើ អាចនឹងកែប្រែ ឬបដិសេធនូវការសម្រេចដែលធ្វើឡើងដោយអាជ្ញាធរថ្នាក់ក្រោមរបស់ខ្លួន កាលបើយល់ឃើញថាការសំរេចនោះប្រាសចាកពីសមត្ថកិច្ច និងអំណាចដែលអាជ្ញាធរថ្នាក់លើបានធ្វើប្រតិភូកម្មអោយ។ លើសពីនេះ អាជ្ញាធរថ្នាក់លើ ក៏អាចនឹងអន្តរាគមន៍ជំនួសរដ្ឋបាលថ្នាក់ក្រោមរបស់ខ្លួន ដោយបំពេញសកម្មភាពដោយខ្លួនឯងផ្ទាល់។

អាជ្ញាធរវិសហមជ្ឈការ មានតួនាទីយ៉ាងសំខាន់ក្នុងរង្វង់ដែនដីថ្នាក់ក្រោមជាតិ។ គណៈអភិបាលមានតួនាទីជាតំណាងក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងដែនដី។ អាជ្ញាធរទាំងនេះមានកាតព្វកិច្ចក្នុងការថែរក្សាសន្តិសុខសណ្ដាប់ធ្នាប់សាធារណៈការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ។ ដើម្បីបំពេញការងារនេះអោយមានប្រសិទ្ធភាព អភិបាលខេត្តអាចបញ្ជាកងកម្លាំងនគរបាល ឬអាវុធហត្ថក្នុងការបង្ការបង្ក្រាប និងស្រាវជ្រាវបទល្មើស។ ភារកិច្ចដ៏សំខាន់មួយទៀត របស់អាជ្ញាធរវិសហមជ្ឈការគឺ ផ្សព្វផ្សាយអនុវត្តតាមដាន និងត្រួតពិនិត្យការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗដែលកំពុងនៅជាធរមាន។ ចុងក្រោយ គណៈអភិបាលមានអំណាចឋានានុក្រមលើប្រធានមន្ទីរ ក្រសួងស្ថាប័ននានា របស់រាជរដ្ឋាភិបាលផងដែរ។ គណៈអភិបាល មានភារកិច្ចណែនាំសម្របសម្រួលត្រួតពិនិត្យ តម្រង់ទិស មន្ទីរ អង្គភាព ខ្សែបណ្ដោយរបស់ក្រសួង ស្ថាប័នទាំងនោះ ដែលធ្វើសកម្មភាពក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។ ក្នុងន័យនេះ រដ្ឋបាលកណ្ដាលអាចនឹងកំណត់ការបែងចែកដោយជាក់លាក់ នូវសមត្ថកិច្ចមួយចំនួន ដែលត្រូវសម្រេចដោយអាជ្ញាធរវិសហមជ្ឈការនៅថ្នាក់មូលដ្ឋាន។ ជាក់ស្ដែង អភិបាលខេត្ត អាចសម្រេចលើកិច្ចការមួយចំនួន ដែលមិនចាំបាច់ស្នើសុំទៅរដ្ឋាភិបាលនៅឯរាជធានីភ្នំពេញ។ ចំណែកឯមន្ទីរនៃក្រសួង- ស្ថាប័ន ក៏ត្រូវបានប្រគល់នូវសិទ្ធិសម្រេចមួយចំនួនផងដែរ។ នេះគឺជាការផ្ទេរសមត្ថកិច្ចក្នុងទស្សនាទាននៃការធ្វើវិសហមជ្ឈការ ដើម្បីជំរុញប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព នៃការផ្ដល់សេវាសាធារណៈ និងការអភិវឌ្ឍនៅថ្នាក់មូលដ្ឋាន ហើយដែលការសម្រេចផ្សេងៗនៅក្នុងក្របខ័ណ្ឌនេះ គឺធ្វើឡើងក្នុងនាមរាជរដ្ឋាភិបាល នៅឯភ្នំពេញ ៕■



*រៀបចំដោយ៖ អ.ត.ហ.*


ការកៀរគរចំណូលក្នុងស្រុក និងកំណើនចំណូលចរន្ត
110.7%
113.0%
105.9%
109.3%
10,516,195
11,640,021
11,808,929
13,339,518
14,347,021
15,193,250
16,606,429
18,152,554
2015
2016
PEFA
កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០១៨
កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣
2018 Annual Review Meeting
Philippine Development Plan 2017-2022
លើកកម្ពស់របៀបរៀបរយសង្គម
បង្កើនសក្តានុពលកំណើន
សាលាឃុំ








# ផ្នែកទី៣

# សុន្ទរកថា

# សុន្ទរកថារបស់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

## *ថ្លែងក្នុងពិធីបើកកិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ ២០១៨ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៣*

*-ឯកឧត្តម, លោកជំទាវ, ថ្នាក់ដឹកនាំក្រសួង-ស្ថាប័ននៃរាជរដ្ឋាភិបាល;*

*-ឯកឧត្តម George Edgar ឯកអគ្គរដ្ឋទូត និង ប្រធានប្រតិភូសហភាព អឺរ៉ុបប្រចាំកម្ពុជា និងជាតំណាងដៃគូអភិវឌ្ឍន៍ ជាទីរាប់អាន;*

*-ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, ភ្ញៀវជាតិ និង អន្តរជាតិ, ជាទីមេត្រី !*

ថ្ងៃនេះ,ខ្ញុំមានកិត្តិយស និងសេចក្តីរីករាយជាអនេកដោយបានចូលរួមថ្លែងសុន្ទរកថាបើក «កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ ២០១៨ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៣» និង ប្រកាសដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រចំនួនបី គឺ «យុទ្ធសាស្ត្រ កៀរគរចំណូល ២០១៩-២០២៣», «យុទ្ធសាស្ត្រ នៃការកែទម្រង់ ប្រព័ន្ធលទ្ធកម្មសាធារណៈ ឆ្នាំ ២០១៩-២០២៥», និង «យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ ២០១៩-២០២៥»។

ក្នុងនាម ជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងក្នុងនាមជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ខ្ញុំសូមសម្តែងនូវការស្វាគមន៍ចំពោះវត្តមានរបស់ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, ជាថ្នាក់ដឹកនាំ និងជាមន្ត្រីរាជការនៃរាជរដ្ឋាភិបាលកម្ពុជា, ឯកអគ្គរាជទូត/ឯកអគ្គរដ្ឋទូត, តំណាងដៃគូអភិវឌ្ឍន៍, ភ្ញៀវ ជាតិ និង អន្តរជាតិទាំងអស់ ដែលបានចូលរួមក្នុងកិច្ចប្រជុំនាថ្ងៃនេះ,ដែលញ៉ាំងកម្មវិធីយើងប្រព្រឹត្តទៅប្រកបដោយបរិយាកាស អធិកអធម និងមានអត្ថន័យដ៏វិសេសវិសាល ព្រមទាំងឆ្លុះបញ្ចាំងអំពីការយកចិត្តទុកដាក់ និងការប្រមូលផ្តុំនូវកម្លាំងសរុបរបស់ជាតិ រួមជាមួយនឹង ដៃគូអភិវឌ្ឍន៍របស់កម្ពុជា ដើម្បីជំរុញការកែទម្រង់ឱ្យបន្តទៅមុខជានិច្ច ។ ខ្ញុំកត់សម្គាល់ថាកិច្ចប្រជុំថ្ងៃនេះ គឺមិនគ្រាន់តែជាការត្រួតពិនិត្យការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រចាំ ឆ្នាំ ២០១៨ ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាការវាយតម្លៃរួម លើការអនុវត្តដំណាក់កាលទី ៣ គឺ «**ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**» ដែលគ្រោងនឹងបញ្ចប់នៅឆ្នាំ ២០២០ ខាងមុខ ដើម្បីជាមូលដ្ឋានត្រៀមរៀបចំឆ្ពោះទៅ ដំណាក់កាល ទី ៤ គឺ «**គណនេយ្យភាពសមិទ្ធកម្ម**» ។ ដូច្នេះ, ខ្ញុំសូមឆ្លៀតយកឱកាសនេះ ដើម្បីគូសរំលេច និងវាយតម្លៃអំពីវឌ្ឍនភាពសំខាន់ៗមកទល់ឆ្នាំ ២០១៨ ព្រមទាំងអំពីបញ្ហាប្រឈមជារួមក្នុងការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ជាពិសេស អំពីការត្រៀមខ្លួនសម្រាប់ ដំណាក់កាលទី ៤ តទៅមុខទៀត ។

*ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ ជាទីមេត្រី!*

រហូតមកដល់ដំណាច់ឆ្នាំ ២០១៨ និងតមកដើមឆ្នាំ ២០១៩, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សម្រេចបាននូវវឌ្ឍនភាពល្អ, ទាំងក្នុងក្របខ័ណ្ឌសកម្មភាពនៃអង្គភាព ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសកម្មភាពកែទម្រង់របស់ក្រសួង/ ស្ថាប័ន។ វឌ្ឍនភាពគន្លឹះៗដែលសម្រេចបាន រួមមាន ÷

ទី១). ការអនុវត្តដោយជោគជ័យ នៃយុទ្ធសាស្ត្រកៀរគរចំណូល រយៈពេលមធ្យម ដែលធ្វើឱ្យចំណូលកើនឡើងជាលំដាប់ ក្នុងនោះចំណូលចរន្ត កើនឡើងជាមធ្យមប្រមាណ ១,៣៥ ពិន្ទុ ភាគរយនៃ ផសស ក្នុងមួយឆ្នាំចាប់តាំងពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨ ។ សមិទ្ធផលនេះ ទទួលបាននូវមូលវិចារល្អគួរជាទីមោទនៈ, ទាំងពីសំណាក់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា និង ពីសំណាក់ដៃគូអភិវឌ្ឍន៍ និង ស្ថាប័នអន្តរជាតិ ព្រមទាំងបានអនុញ្ញាត ឱ្យរាជរដ្ឋាភិបាលអាចបង្វែរថវិកាកាន់តែច្រើនទៅកាន់វិស័យអាទិភាព ក៏ដូចជាអាចបង្កើនយ៉ាងច្រើន នូវធនធានវិនិយោគសាធារណៈក្នុងស្រុក ពិសេសលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលជាប្រការជួយលើកស្ទួយមួយកម្រិត ដល់ឯករាជ្យភាពផ្នែកថវិការបស់កម្ពុជា។

ទី២). ការដាក់ឱ្យអនុវត្តជាបណ្តើរៗ នូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ដោយបានដាក់បញ្ចូលចំណាត់ថ្នាក់ថវិកា ទាំង ៧,




បង្កើតបានជាមូលដ្ឋានសម្រាប់ការកត់ត្រាគណនេយ្យគ្រប់ជ្រុងជ្រោយ និងអាចផលិតរបាយការណ៍ទាន់ពេលវេលា។ នៅពេលនេះ ,ប្រព័ន្ធ FMIS បាននិងកំពុងអភិវឌ្ឍជំហានទី ២ ដោយបានដាក់ឲ្យអនុវត្តជាផ្លូវការនៅតាមក្រសួង/ ស្ថាប័នចំនួន ២០ និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទាំង ២៥ រាជធានី-ខេត្ត, រីឯក្រសួង/ ស្ថាប័នចំនួន ១៧ ផ្សេងទៀត នឹងត្រូវប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការនៅឆ្នាំ ២០២០ ខាងមុខ ។ វឌ្ឍនភាពក្នុងការអនុវត្តបច្ចេកវិទ្យាព័ត៌មានបែបនេះ ប្រហែលជាមិនមានប្រទេសច្រើនទេ អាចសម្រេចបានជាពិសេសក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍន៍ដែល ចាប់ផ្តើមការងារនេះប្រហាក់ប្រហែលកម្ពុជា។

ទី៣). ការដាក់ឲ្យអនុវត្តថវិកាកម្មវិធីពេញលេញនៅគ្រប់ក្រសួង/ ស្ថាប័ន និង តាមបណ្តារដ្ឋបាលរាជធានី-ខេត្តមួយចំនួនស្របគ្នានឹងការបង្កើត និងដាក់ឲ្យអនុវត្តអង្គភាពថវិកា នៅគ្រប់ក្រសួង/ ស្ថាប័ន។ នៅថ្នាក់ក្រោមជាតិ,ចាប់ពីឆ្នាំ២០១៧ មក, រដ្ឋបាលខេត្តចំនួន ១៨ ត្រូវបានដាក់ឱ្យអនុវត្តសាកល្បងនូវថវិកាកម្មវិធីពេញលេញ។ សម្រាប់ឆ្នាំ ២០២០ , រដ្ឋបាលខេត្តចំនួន ៦ បន្ថែមរួមមាន÷ កំពង់ចាម, កំពង់ធំ, ព្រះវិហារ, ឧត្តរមានជ័យ, សៀមរាប និងព្រះសីហនុនឹងត្រូវបានដាក់ ឲ្យអនុវត្តថវិកាកម្មវិធីហើយ នៅឆ្នាំ ២០២១ រដ្ឋបាលរាជធានីភ្នំពេញ នឹងត្រូវបានដាក់ឲ្យអនុវត្តនូវថវិកាកម្មវិធីដូចគ្នាដែរ។ ការដាក់ឲ្យអនុវត្តថវិកាកម្មវិធីបាននាំមកនូវការកែប្រែការគ្រប់គ្រងថវិកាទាំងស្រុង, ដែលពីមុនមានលក្ខណៈមជ្ឈការនៅតាមក្រសួង/ ស្ថាប័ន, ឥឡូវនេះមានលក្ខណៈវិមជ្ឈការ ពោលគឺអ្នកអនុវត្ត



គម្រោង, កម្មវិធី និង សកម្មភាពផ្ទាល់ ឬអ្នកបច្ចេកទេសបានដឹងពីថវិការបស់ខ្លួន និង អាចធ្វើសកម្មភាពក្នុងលក្ខណៈបុរេសកម្ម។ ជាការកត់សម្គាល់ផងដែរ, ក្រសួង/ស្ថាប័នមួយចំនួន បានចាប់ផ្តើមធ្វើការកែសម្រួលរចនាសម្ព័ន្ធរបស់ខ្លួន ដើម្បីឈានឆ្ពោះទៅពង្រឹងសមិទ្ធកម្មថែមទៀត។ លើសពីនេះ, ការអនុវត្តថវិកា កម្មវិធីអនុញ្ញាតឱ្យរាជរដ្ឋាភិបាល បង្កើនប្រសិទ្ធភាពនៃការវិភាជថវិកាឱ្យបានកាន់តែប្រសើរ ដោយបែរឆ្ពោះទៅរកវិស័យអាទិភាព។

ទី៤). ការដាក់ចេញនូវក្របខ័ណ្ឌយុទ្ធសាស្ត្រច្បាស់លាស់សម្រាប់ការកែទម្រង់ ដែលក្នុងនោះមាន «យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣», «យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០១៩-២០២៥», «យុទ្ធសាស្ត្រនៃការកែទម្រង់ ប្រព័ន្ធលទ្ធកម្មសាធារណៈ ឆ្នាំ ២០១៩-២០២៥» និង «ផែនការសកម្មភាព សម្រាប់អនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥» ដែលត្រូវប្រកាសដាក់ឱ្យអនុវត្ត ក្នុងកិច្ចប្រជុំនេះ។ យុទ្ធសាស្ត្រនីមួយៗ បានកំណត់គោលបំណង និង គោលដៅច្បាស់លាស់សម្រាប់តម្រង់សកម្មភាពកែទម្រង់នៅក្នុងរយៈពេលមធ្យមខាងមុខ ដែលមានអគ្គនាយកដ្ឋានទទួលបន្ទុកជាអ្នករៀបចំផ្ទាល់ ដោយធានាបាន ភាពជាម្ចាស់ក្នុងការកែទម្រង់។

ទី៥). ការដាក់ឱ្យអនុវត្តសាកល្បងប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ, ការបង្កើនការផ្សព្វផ្សាយ ឯកសារថវិកាជាសាធារណៈ, ការពង្រឹងតួនាទីស្ថាប័នសវនកម្ម និងអធិការកិច្ច, និងការពង្រឹងសមត្ថភាពមន្ត្រីក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាប្រចាំ ។ វឌ្ឍនភាពទាំងអស់នេះបានជួយឱ្យការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កាន់តែមានប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព និងតម្លាភាព។

ទី៦). ការរៀបចំក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម និងក្របខ័ណ្ឌថវិការយៈពេលមធ្យម ទើបត្រូវបានចាប់ផ្តើមអនុវត្តសាកល្បងនៅឆ្នាំ ២០១៩ សម្រាប់ថវិកាឆ្នាំ២០២០-២០២២ ដើម្បីតម្រង់ទិសផែនការយុទ្ធសាស្ត្រថវិកាឱ្យមានគុណភាពប្រសើរឡើង។ ជាមួយ គ្នានេះ, ក្របខ័ណ្ឌនៃការគ្រប់គ្រង ការវិនិយោគសាធារណៈ ក៏កំពុងតែស្ថិតនៅក្នុងដំណាក់កាល រៀបចំនៅឡើយ។

ទី៧). ខណៈដែលការរៀបចំថវិកាត្រូវបានធ្វើឡើងតាមកម្មវិធី, ការគ្រប់គ្រងស្ថាប័នត្រូវធ្វើទំនើបកម្មថែមទៀត តាមរយៈការផ្តល់សិទ្ធិអំណាចកាន់តែច្រើនដល់អ្នកអនុវត្ត ដែលក្នុងនោះថ្នាក់ដឹកនាំ ឬគ្រប់គ្រងទទួលខុសត្រូវជាសំខាន់លើសមិទ្ធកម្ម ឬការត្រួតពិនិត្យលើលទ្ធផលនៃការអនុវត្ត, ចំណែកការទទួលខុសផ្នែកហិរញ្ញវត្ថុ ត្រូវធ្វើឡើងតាមរយៈការពង្រឹងមុខងារសវនកម្មផ្ទៃក្នុង និង អធិការកិច្ចនៃក្រសួង/ស្ថាប័ន។

ទី៨). ភាពចាំបាច់ក្នុងការ បន្តការយកចិត្តទុកដាក់លើការពង្រឹងសមត្ថភាពផ្នែកគ្រប់គ្រងហិរញ្ញវត្ថុ, ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ, ដើម្បីគាំទ្រ និង ឆ្លើយតបទៅនឹងការកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេស ឆ្ពោះទៅ «ប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម» ។






*ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ ជាទីមេត្រី!*

បញ្ហាប្រឈមទាំងនេះ ត្រូវបានដោះស្រាយមួយចំណែកធំ នៅក្នុងយុទ្ធសាស្ត្រទាំងបី ដែលនឹងត្រូវពិភាក្សា ក្នុងកម្មវិធីផ្សព្វផ្សាយដាក់ឲ្យអនុវត្តក្នុងព្រឹកនេះ ចំណែកបញ្ហាដែលនៅសេសសល់ នឹងត្រូវលើកឡើងដើម្បីបន្តស្វែងរកដំណោះស្រាយ នៅក្នុងកិច្ចប្រជុំ គណៈកម្មាធិការដឹកនាំការងារ កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ និងក្រុមការងារបច្ចេកទេស TWG នាពេលរសៀលនេះ។

ជារួម «យុទ្ធសាស្ត្រកៀរគរចំណូល ឆ្នាំ ២០១៩-២០២៣» មានគោលដៅប្រមូលចំណូលចរន្តសរុប ឱ្យកើនបានយ៉ាងតិចបំផុត ០,៣ពិន្ទុភាគរយនៃ ផសស ជាមធ្យមក្នុងមួយឆ្នាំ, ទន្ទឹមនឹងការបង្កើនគុណភាពសេវា និងផលិតភាពក្នុងការផ្តល់សេវាគ្រប់គ្រងគ្រប់ប្រភេទនៃរដ្ឋបាលប្រមូលចំណូលសារពើពន្ធ និង មិនមែនសារពើពន្ធ។ យុទ្ធសាស្ត្រពីរផ្សេងទៀតពាក់ព័ន្ធនឹងការកែទម្រង់ប្រព័ន្ធថវិកា ឆ្ពោះទៅសម្រេច **«ប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម»** នៅឆ្នាំ ២០២៥។ ក្នុងនោះ **«យុទ្ធសាស្ត្រ នៃការកែទម្រង់ថវិកាថ្នាក់ក្រោមជាតិឆ្នាំ ២០១៩-២០២៥»** ផ្តោតការយកចិត្តទុកដាក់លើការធ្វើសមាហរណកម្មផែនការនីយកម្ម និង ការតម្រឹមជាមួយ នឹងអាទិភាពតាមវិស័យនៃក្រសួង/ ស្ថាប័នថ្នាក់ជាតិ (មន្ទីរជំនាញរាជធានី-ខេត្ត) ដែលជាអភិក្រមពីលើ ចុះក្រោម និងការឆ្លុះបញ្ចាំងអាទិភាពនៅថ្នាក់មូលដ្ឋាន ដែលជាតម្រូវការ និងសំណូមពរនានាពីរដ្ឋបាលថ្នាក់ក្រុង-ស្រុក-ខណ្ឌ និង ឃុំ-សង្កាត់ ដែលជាអភិក្រមពីក្រោមទៅលើ ដោយមាន **«ផែនការយុទ្ធសាស្ត្រថវិការាជធានី-ខេត្ត»** ជាឧបករណ៍។ ចំណែក **«យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ ២០១៩-២០២៥»** ផ្តោតលើការបង្កើនសិទ្ធិសម្រេច និងការទទួលខុសត្រូវលើកិច្ចលទ្ធកម្មជាបណ្តើរៗ ជូនក្រសួង/ ស្ថាប័ន, រដ្ឋបាលថ្នាក់ជាតិ, និង អង្គភាពសាធារណៈប្រហាក់ប្រហែល រហូតដល់ឆ្នាំ ២០២៥។ យុទ្ធសាស្ត្រទាំងពីរនេះ គឺជា ការបំពេញបន្ថែមលើ «យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥» ដែលទទួលបានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម្រ័យប្រជុំពេញអង្គ ថ្ងៃទី ១២ ខែមករា ឆ្នាំ ២០១៨។

ខ្ញុំសូមគូសបញ្ជាក់ថាយុទ្ធសាស្ត្រទាំងបី ដែលនឹងដាក់ផ្សព្វផ្សាយនៅព្រឹកនេះ ត្រូវបានដាក់ឆ្លង ការពិភាក្សាជាច្រើនលើកជាមួយនឹងក្រសួង/ ស្ថាប័ន និង ភាគីពាក់ព័ន្ធ ព្រមទាំងបានដាក់ឆ្លងគណៈកម្មាធិការដឹកនាំ ការកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុព្រមទាំងទទួលបានការឯកភាពដ៏ខ្ពង់ខ្ពស់ពីសំណាក់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ ចំពោះ **«ផែនការសកម្មភាព សម្រាប់ការអនុវត្តយុទ្ធសាស្ត្រ នៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥»** ត្រូវបានអនុម័តដោយរូបខ្ញុំផ្ទាល់ ក្នុងនាមជាប្រធានគណៈកម្មាធិការដឹកនាំ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ផងដែរ។ ទោះបីជាយ៉ាងនេះក្តី, ឯកសារយុទ្ធសាស្ត្រ និងផែនការសកម្មភាពទាំងនេះ ត្រូវបានចាត់ទុកជាឯកសាររស់ ដែលនឹងត្រូវបន្តកែលម្អ ផ្អែកតាមបទពិសោធន៍ និង បរិការណ៍ថ្មីៗ នៅពេលខាងមុខថែមទៀត។ ដូចខ្ញុំបានគូសបញ្ជាក់, យើងអាចនឹងបន្តលើកយកមកពិភាក្សាគ្នានូវចំណុចជាក់ស្តែងមួយចំនួនថែមទៀត ក្នុងកិច្ចប្រជុំ នៅថ្ងៃរសៀល។

ខ្ញុំរំពឹងទុកជាមុនថា កិច្ចប្រជុំរបស់យើងនៅថ្ងៃនេះនឹងប្រព្រឹត្តទៅ ដោយមានការពិភាក្សាយ៉ាងផុសផុល និងគ្រប់ជ្រុងជ្រោយ ដើម្បីធានាថាការគិតគូររបស់យើងមានភាពត្រឹមត្រូវពេញលេញ។ នៅពេលណាដែលការគិតគូរធ្វើបានល្អ, ការដាក់ចេញយុទ្ធសាស្ត្របានច្បាស់លាស់ និងការប្រាស្រ័យទាក់ទងយល់គ្នាដោយភាតរភាព ពេលនោះទើបសកម្មភាពកែទម្រង់នឹងអាច។

ក្នុងស្មារតីនេះ, ខ្ញុំ, តាងនាមឱ្យរាជរដ្ឋាភិបាល, សូមប្រកាសដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រទាំងបី គឺ «យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣», «យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ

ឆ្នាំ ២០១៩-២០២៥», និង « យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា រដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥», និង សូមឱ្យគ្រប់អង្គភាពពាក់ព័ន្ធទាំងអស់ អនុវត្តយុទ្ធសាស្ត្រទាំងបីនេះ ប្រកបដោយឆន្ទៈ, មនសិការ, និង ការទទួលខុសត្រូវខ្ពស់។

ខ្ញុំសូម លើកទឹកចិត្តឱ្យបន្តការពិភាក្សាឯកសារយុទ្ធសាស្ត្រទាំងបី ដើម្បីឈានទៅរៀបចំផែនការសកម្មភាព សម្រាប់អនុវត្តហិរញ្ញវត្ថុសាធារណៈ រហូតសម្រេចបានលទ្ធផលល្អប្រសើរ។ បើយោងតាម ផែនការសកម្មភាពរួម ដំណាក់កាលទី៣, យើងអាចសន្និដ្ឋានបានថាយើងបានអនុវត្តសកម្មភាពកាន់តែច្រើន និង សម្រេចបានលទ្ធផលកាន់តែច្រើនឡើងៗ ពីមួយឆ្នាំទៅមួយឆ្នាំ។ សមិទ្ធផលទាំងនេះ គូសបញ្ជាក់យ៉ាងច្បាស់ពីកិច្ចខិតខំប្រឹងប្រែងរបស់យើងទាំងអស់គ្នា។ ឆ្លៀតក្នុងឱកាសនេះផងដែរ, ខ្ញុំក៏សូមមានសន្ទុះល្អទៅមុខហើយខ្ញុំរំពឹងទុកចំពោះស្មារតីសហការបែបនេះ ក្នុងដំណាក់កាលបន្តបន្ទាប់ទៀត។

ជាចុងក្រោយ, ខ្ញុំសូមជូនពរឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, តំណាងដៃគូអភិវឌ្ឍន៍, តំណាងអង្គទូត, ភ្ញៀវជាតិនិងអន្តរជាតិគ្រប់រូប, សូមបានប្រកបដោយសុខភាពល្អ និងសម្រេចបានជោគជ័យក្នុងគ្រប់កិច្ចការរបស់ខ្លួន។




ឱ្យបានគ្រប់ជ្រុងជ្រោយ, ធានាបាននូវការចូលរួមពេញលេញ, ប្រសិទ្ធភាព និង ការទទួលខុសត្រូវខ្ពស់។

មុននឹងបញ្ចប់, ខ្ញុំសូមយកឱកាសនេះវាយតម្លៃខ្ពស់ និង ផ្តល់មូលវិចារដ៏ថ្លៃថ្លាចំពោះសហការីនៃរដ្ឋាភិបាលកម្ពុជា, ក្រសួង/ស្ថាប័ន, និង អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទាំងអស់ ដែលបានខិតខំប្រឹងប្រែងអនុវត្តសកម្មភាពទាំងឡាយនៅក្រោម កម្មវិធីកែទម្រង់ការគ្រប់គ្រងថ្លែងអំណរគុណដ៏ជ្រាលជ្រៅ ដល់សហគមន៍អឺរ៉ុប, ធនាគារពិភពលោក, ធនាគារអភិវឌ្ឍន៍អាស៊ី, មូលនិធិរូបិយវត្ថុអន្តរជាតិ, អង្គការយូនីសែហ្វ, រដ្ឋាភិបាលបារាំង/AFD, រដ្ឋាភិបាលអូស្ត្រាលី, និងស្ថាប័នអន្តរជាតិផ្សេងទៀត ដែលបាន និង គ្រោងបន្តផ្តល់ជំនួយហិរញ្ញវត្ថុ និង បច្ចេកទេស សម្រាប់គាំទ្រដល់ ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៣ នេះ ឲ្យប្រព្រឹត្តទៅដោយរលូន និង

ខ្ញុំសូមប្រកាសបើក « កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ ២០១៨ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៣» ចាប់ពីពេលនេះតទៅ។

**សូមអរគុណ !**

# សុន្ទរកថាស្វាគមន៍ របស់ឯកឧត្តម រស់ សីលវ៉ា អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

*ថ្លែងនៅក្នុងកិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ ២០១៨ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ នៅថ្ងៃពុធ ១១រោច ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៩*

*- ខ្ញុំបាទសូមគោរព ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ!*

*- សូមគោរព ឯកឧត្តម, លោកជំទាវ, សមាជិក, សមាជិកា នៃរាជរដ្ឋាភិបាល!*

*- ឯកឧត្តម George Edgar ឯកអគ្គរដ្ឋទូត និងជាប្រធានប្រតិភូសហភាពអឺរ៉ុបប្រចាំកម្ពុជា និងជាតំណាងដៃគូអភិវឌ្ឍន៍ ជាទីរាប់អាន!*

*- ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី ថ្នាក់ដឹកនាំ, សហសេវិក, ភ្ញៀវជាតិ និងអន្តរជាតិ ជាទីមេត្រី!*



ជាបឋម, ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមាន ឯកឧត្តម, លោកជំទាវ ,អស់លោក, លោកស្រី, ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ ដែលបានអញ្ជើញ ចូលរួម “កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០១៨ នៃកម្មវិធីកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសា-ធារណៈ ដំណាក់កាលទី៣” ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាកម្មវិធីកែទម្រង់រយៈពេលវែង ដែលមានចក្ខុវិស័យ ប្រកបដោយមហិច្ឆតា និងប្រាកដនិយមគឺផ្លាស់ប្តូរប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជា ឆ្ពោះទៅឧត្តមានុវត្តអន្តរជាតិ ដោយបាននិងកំពុងកសាង និងពង្រឹងសមាសធាតុស្នូលទាំង៤ រួមមាន “**ការកែលម្អប្រព័ន្ធ, ក្របខ័ណ្ឌ គតិយុត្ត, យន្តការស្ថាប័ន និងធនធានមនុស្ស**”។ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺត្រូវរៀបចំឡើងតាមលំដាប់លំដោយស្រប តាមបរិបទនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា។

ក្នុងន័យនេះ, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានរៀបចំ និងប្រកាសដាក់ឱ្យអនុវត្តដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** នៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៤ ដោយប្រកាន់យកអភិក្រមជាខឿន និងអនុវត្តជាដំណាក់កាល រួមមាន ជាអាទិ៍÷

- **ដំណាក់កាលទី១** “ភាពជឿទុកចិត្ត នៃថវិកា” ពីឆ្នាំ២០០៥-២០០៨
- **ដំណាក់កាលទី២** “ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ” ពីឆ្នាំ២០០៩-២០១៥
- **ដំណាក់កាលទី៣** “ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ” ពីឆ្នាំ២០១៦-២០២០
- **ដំណាក់កាលទី៤** “គណនេយ្យភាពសមិទ្ធកម្ម” ពីឆ្នាំ២០២១-២០២៥។

រហូតមកដល់ពេលនេះ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺស្ថិតក្នុងដំណាក់កាលទី៣ “ការផ្សារភ្ជាប់ថវិកា




ទៅនឹងគោលនយោបាយ” ដោយគោលដៅអាទិភាពចំនួន ០៣ រួមមាន (១). ការពង្រឹងការគ្រប់គ្រង និងអនុវត្តផែនការប្រមូលចំណូល, (២). ការពង្រឹង និងពង្រីកការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) និង (៣). ការពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធី ព្រមទាំងផ្តល់ថវិកាគាំទ្រការអនុវត្តផែនការសកម្មភាព ដល់ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅតាមក្រសួង-ស្ថាប័ន ប្រមាណ ៣០០០០ ដុល្លារអាមេរិកក្នុងមួយឆ្នាំ ក្នុងមួយក្រសួង-ស្ថាប័ន ព្រមទាំងបានទទួលប្រាក់ឧបត្ថម្ភលើកទឹកចិត្តសមស្របតាមផែនការសកម្មភាពកែទម្រង់របស់ខ្លួន។

ការត្រួតពិនិត្យតាមដានវឌ្ឍនភាព នៃការ អនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានរៀបចំឡើងជាប្រចាំត្រីមាស និងប្រចាំឆ្នាំអនុលោមតាមសារាចរណែនាំ របស់រាជរដ្ឋាភិបាលលេខ ០៩ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១៥ ស្តីពី “វិធាននិងនីតិវិធីនៃការរៀបចំ, ការអនុវត្ត ,ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ




សាធារណៈ” ក្នុងគោលបំណង ដើម្បីធានានូវប្រសិទ្ធភាពនៃការរៀបចំ,អនុវត្តនិងត្រួតពិនិត្យតាមដាននៃអនុវត្តផែនការសកម្មភាពគាំទ្រ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ផ្អែកលើលទ្ធផល នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០១៨ ខ្ញុំសូមគោរព រាយការណ៍ជូនអង្គប្រជុំនូវរបាយការណ៍វឌ្ឍនភាពសង្ខេបដូចតទៅ÷

❖ ការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យមឆ្នាំ២០១៤-២០១៨ សម្រេចបានគោលដៅ ដែលបានដាក់ចេញ ដោយចំណូលចរន្ត មានកំណើន ០,៥ ពិន្ទុភាគ-រយ នៃ ផ.ស.ស. ដែលឆ្នាំ ២០១៨ នេះសម្រេចបាន១,៤៧ ពិន្ទុភាគរយនៃ ផ.ស.ស ជាមធ្យមពីឆ្នាំ២០១៤-២០១៨ ចំណូលចរន្តកើនឡើងប្រមាណ ១,៣៥ ពិន្ទុភាគរយនៃ ផ.ស.ស.។

❖ គម្រោង FMIS ត្រូវបានរៀបចំ និងដាក់ឱ្យ អនុវត្តជំហានទី១ នៅឆ្នាំ២០១៤ និងជំហានទី២ នៅឆ្នាំ ២០១៧។ ទន្ទឹមនេះ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានធ្វើការកែសម្រួលប្លង់គណនេយ្យថ្មី ឱ្យស្របតាមស្តង់ដារអន្តរជាតិ ព្រមទាំងបានរៀបចំ និងដាក់ឱ្យ អនុវត្តប្រកាសស្តីពី ការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់ទាំង ៧ រួមមាន (១). ចំណាត់ថ្នាក់អង្គភាពប្រតិបត្តិ និងរដ្ឋបាល, (២).ចំណាត់ថ្នាក់ភូមិសាស្ត្រ, (៣).ចំណាត់ថ្នាក់សេដ្ឋកិច្ច, (៤).ចំណាត់ថ្នាក់កម្មវិធី, (៥).ចំណាត់ថ្នាក់មុខងារ, (៦).ចំណាត់ថ្នាក់គម្រោង និង (៧). ចំណាត់ថ្នាក់មូលនិធិ ដោយក្នុងនោះចំណាត់ថ្នាក់ថវិកាចំនួន ៥ អនុវត្តបានពេញលេញ និងចំនួន ២ទៀត បាននិងកំពុងជំរុញអនុវត្ត។ បន្ថែមពីនេះ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានកំណត់ផែនការពង្រីកប្រព័ន្ធ FMIS ប្រកបដោយភាពច្បាស់លាស់សំដៅគាំទ្រ ការអនុវត្តថវិកាកម្មវិធី និងប្រព័ន្ធគណនេយ្យភាពហិរញ្ញវត្ថុនៅតាមក្រសួង-ស្ថាប័ន ដូចតទៅ÷

☑ ឆ្នាំ២០១៨÷ក្រសួង-ស្ថាប័នចំនួន ១០ ត្រូវបានដាក់ឱ្យ ប្រើប្រាស់ប្រព័ន្ធ FMIS ជាផ្លូវការ។

☑ ឆ្នាំ២០១៩÷ក្រសួង-ស្ថាប័ន ចំនួន ១០ ថ្មីបន្ថែម និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត ទាំង២៥ត្រូវដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ FMIS ជាផ្លូវការ។

☑ ឆ្នាំ២០២០÷ក្រសួង-ស្ថាប័នចំនួន ១៧ ថ្មីបន្ថែម នឹងត្រូវដាក់ឱ្យ ប្រើប្រាស់ប្រព័ន្ធ FMIS ជាផ្លូវការ។

❖ ការអនុវត្តថវិកាកម្មវិធី ត្រូវបាននិងកំពុងដាក់ឱ្យ អនុវត្តគ្រប់ក្រសួង-ស្ថាប័ន និងគ្រប់រដ្ឋបាលរាជធានី-ខេត្ត។ ជាវឌ្ឍនភាព, ចាប់ពីឆ្នាំ ២០១៥ ដល់ឆ្នាំ ២០១៨




ក្រសួង-ស្ថាប័ន ទាំង៣៩ ត្រូវបានដាក់ឱ្យអនុវត្តថវិកាកម្មវិធីសាកល្បងពេញលេញ រីឯ រដ្ឋបាលរាជធានី-ខេត្តទាំង២៥ ត្រូវបានដាក់ឱ្យអនុវត្តថវិកាកម្មវិធីសាកល្បងពេញលេញចាប់ពី ឆ្នាំ២០១៧ រហូតដល់ ឆ្នាំ ២០២១។

ជាមួយគ្នានេះ, ដើម្បីកំណត់ទិសដៅកែទម្រង់ប្រព័ន្ធថវិកា ឱ្យបានច្បាស់លាស់ និងប្រាកដនិយម, គណៈកម្មាធិការដឹកនាំការងារកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានរៀបចំយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥ ហើយត្រូវបានគណៈរដ្ឋមន្ត្រី អនុម័តនៅថ្ងៃ១២ ខែមករា ឆ្នាំ២០១៨ ដោយកំណត់ប្រព័ន្ធថវិកាកម្ពុជាជា “**ប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម ឬថវិកាសមិទ្ធកម្ម**”។

ជារួម, ផ្អែកលើលទ្ធផលសម្រេចបានប្រចាំឆ្នាំ២០១៨ យើងអាចសន្និដ្ឋានថា÷ (១). ថវិកាកាន់តែមានភាពជឿទុកចិត្ត និងបានក្លាយជាចលករ នៃកំណើនសេដ្ឋកិច្ច, (២). បុរេលក្ខណៈសំខាន់ៗត្រូវ បានកសាង និងពង្រឹងបន្ថែម ដើម្បីធានាគណនេយ្យភាពហិរញ្ញវត្ថុ, (៣). ក្របខ័ណ្ឌថវិកាកម្មវិធី ត្រូវបានរៀបចំ ពង្រឹង និងពង្រីកការអនុវត្តដែលជាឧបករណ៍សំខាន់សម្រាប់ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ របស់រាជរដ្ឋាភិបាល, (៤). សមត្ថភាពមន្ត្រី ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានពង្រឹង និង (៥). ការយល់ដឹង និងការចូលរួម អនុវត្តកម្មវិធីកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមានការកើនឡើងជាលំដាប់។

ត្បិតតែកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រេចបាននូវសមិទ្ធផលសំខាន់ៗដូចបានជម្រាបជូនរៀបរាប់ខាងលើ ក្នុងនាមជាសេនាធិការឱ្យគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងរូបខ្ញុំផ្ទាល់បានកត់សម្គាល់ឃើញថា យើងជួបប្រទះបញ្ហាប្រឈមសំខាន់ៗ រួមមាន កត្តាស្ថាប័ន (ភាពជាអ្នកដឹកនាំ, ការគ្រប់គ្រង, ឆន្ទៈ និងយន្តការសម្របសម្រួលផ្ទៃក្នុង) និង កត្តាធនធានមនុស្សនៅមានកម្រិតដែលចាំបាច់ត្រូវផ្តោតការយកចិត្តដាក់និងចូលរួមបន្ថែមពីគ្រប់តួអង្គពាក់ព័ន្ធទាំងអស់។

ជាមួយគ្នានេះ, តាមគោលដៅឆ្នាំ២០២០ កម្មវិធី កែទម្រង់ការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈ នឹងបញ្ចប់ ដំណាក់កាលទី ៣ ឈានឆ្ពោះទៅ ដំណាក់កាលទី ៤ “គណនេយ្យភាពសមិទ្ធកម្ម”, អគ្គលេខាធិការដ្ឋានគណៈកម្មាធិការ ដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានសហការ ជាមួយក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័ន បានធ្វើកែសម្រួល និងសម្រេចក្របខ័ណ្ឌផែនការសកម្មភាពរួម ដំណាក់កាលទី៣ ដើម្បីបញ្ចប់ការងារដែលសេសសល់ក្នុងឆ្នាំ២០១៩-២០២០។ ទន្ទឹមនេះ, អគ្គលេខាធិការគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈគ្រោងនឹងធ្វើ ការវាយតម្លៃចំណាយ សាធារណៈ និងគណនេយ្យភាព ហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ ឆ្នាំ២០១៩ និងវាយតម្លៃចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុថ្នាក់ជាតិឆ្នាំ២០២០ ដើម្បីប្រមូលធាតុចូលសម្រាប់ការរៀបចំក្របខ័ណ្ឌផែនការសកម្មភាពរួម ដំណាក់កាលទី៤ ឱ្យសមស្របតាម បរិបទទាំងការ អភិវឌ្ឍសង្គម-

សេដ្ឋកិច្ចកម្ពុជានិងឧត្តមានុវត្តន៍អន្តរជាតិ។

*ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!*

សម្រាប់កិច្ចដំណើរការកម្មវិធីកិច្ចប្រជុំត្រួតពិនិត្យ ប្រចាំឆ្នាំ ២០១៨ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ នាថ្ងៃនេះ គឺបែងចែកជាបីវគ្គ ដូចតទៅ÷

◈ **វគ្គទី១÷** កម្មវិធីបើក និងប្រកាសដាក់ឱ្យអនុវត្ត “យុទ្ធសាស្ត្រគៀរគរចំណូលឆ្នាំ២០១៩-២០២៣, យុទ្ធសាស្ត្រ នៃការកែទម្រង់ ប្រព័ន្ធថវិកា ថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥, យុទ្ធសាស្ត្រ នៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ ឆ្នាំ២០១៩-២០២៥ និងផែនការសកម្មភាពគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

◈ **វគ្គទី២÷**ផ្សព្វផ្សាយឯកសារយុទ្ធសាស្ត្រកែទម្រង់ និងផែនការ សកម្មភាពលម្អិតគាំទ្រយុទ្ធសាស្ត្រ នៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ ក្រោមការសម្របសម្រួល របស់ឯកឧត្តម **ខៀវ វិសុទ្ធ** រដ្ឋលេខាធិការប្រចាំការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

◈ **វគ្គទី៣÷**កិច្ចប្រជុំគណៈកម្មាធិការដឹកនាំ ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ដៃគូអភិវឌ្ឍន៍ ដែលផ្តោតលើ (ទី១).ពិភាក្សាលើរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំឆ្នាំ២០១៨ និង (ទី២).ប្រខ័ណ្ឌផែនការសកម្មភាពរួមដំណាក់កាលទី៣។

មុននឹងបញ្ចប់, តាងនាមអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងរូបខ្ញុំផ្ទាល់ សូមសម្តែងកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅជូនចំពោះ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តែងតែងផ្តល់ការគាំទ្រ និងផ្តល់អនុសាសន៍ សំដៅតម្រង់ទិសកម្មវិធីកែទម្រង់ការគ្រប់គ្រងឱ្យអនុវត្តបាន ប្រកបដោយ ជោគជ័យ និងចីរភាព។ ទន្ទឹមនេះ, ខ្ញុំសូមធ្វើការវាយតម្លៃខ្ពស់ និងកោតសរសើរចំពោះ ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួង-ស្ថាប័ន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលបានផ្តល់កិច្ចសហការចូលរួម និងខិតខំអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ទន្ទឹមនេះ, ខ្ញុំសូមអរគុណជាថ្មីម្តងទៀតចំពោះ បណ្តាដៃគូអភិវឌ្ឍន៍នានា ដែលបានប្តេជ្ញាបន្តផ្តល់ការគាំទ្រចាំបាច់ ទាំងជាហិរញ្ញប្បទាន ទាំងជា ជំនួយបច្ចេកទេស ប្រកបដោយសុឆន្ទៈនិងប្រកបដោយចីរភាពចំពោះការងារកែទម្រង់នេះ ឱ្យសម្រេចបានជោគជ័យតាមការគ្រោងទុក ក្នុងស្មារតីនៃការគោរព និងលើកតម្កើង ភាពជាម្ចាស់របស់កម្ពុជា។

ជាទីបញ្ចប់, ខ្ញុំសូមជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី ទាំងអស់ ប្រកបដោយពុទ្ធពរទាំង ៤ប្រការ គឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ!**

ដំណាក់កាលទី១
(២០០៥ - ២០០៨)
ភាពជឿទុកចិត្តនៃថវិកា

ដំណាក់កាលទី២
(២០០៩ - ២០១៥)
គណនេយ្យភាពហិរញ្ញវត្ថុ
FMI
ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ដំណាក់កាលទី៣
(២០១៦ - ២០២០)
ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ

ដំណាក់កាលទី៤
(២០២១ - ២០២៥)
គណនេយ្យភាពចំពោះសមិទ្ធកម្ម



113.0%
110.7%
105.9%
109.3%
10,516,195
11,640,021
11,808,629
13,339,518
14,347,021
15,193,250
16,606,429
18,152,554
2015
2016
PEFA
2018 Annual Review Meeting
Philippine
Development Plan
2017-2022








# ផ្នែកទី៤

# ទស្សនៈ និង មតិ



ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់
ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

*“ តាមរយៈវឌ្ឍនភាព ដែលបាន និង កំពុងលេចរូបរាងឡើងនេះ, យើងអាចវាយតម្លៃបានថា ប្រព័ន្ធថវិកាយើងកាន់តែមានភាពជឿទុកចិត្ត និងជាឧបករណ៍សំខាន់សម្រាប់ទ្រទ្រង់ និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម, មានបុរេលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីធានាគណនេយ្យភាពហិរញ្ញវត្ថុ, មានក្របខ័ណ្ឌថវិកាកម្មវិធីច្បាស់លាស់ជាឧបករណ៍សម្រាប់ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល, មានមន្ត្រីកាន់តែមានសមត្ថភាពសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, មានការយល់ដឹងកាន់តែច្រើនឡើងសម្រាប់ចូលរួមអនុវត្តកម្មវិធីកែទម្រង់ និងកំពុងកសាងមូលដ្ឋានជាបណ្តើរៗឆ្ពោះទៅកាន់គណនេយ្យភាពសមិទ្ធកម្ម ។”*

*“ ខ្ញុំចង់គូសបញ្ជាក់ថាកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈបានផ្លាស់ប្តូររបៀប នៃការរៀបចំ និងអនុវត្តថវិកាដោយបានផ្លាស់ប្តូរប្រព័ន្ធពីការផ្តោតលើធាតុចូលទៅជាការផ្តោតលើធាតុចេញ, ការពង្រឹងការផ្សារភ្ជាប់រវាងគោលនយោបាយនិងថវិកាព្រមទាំងការផ្តោតលើលទ្ធផល។ បើទោះបីជាផ្លូវនៃការកែទម្រង់នៅវែងឆ្ងាយបន្តទៀតក៏ដោយ, យុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកា ២០១៨-២០២៥និងផែនការសកម្មភាពដែលត្រូវបានប្រកាសដាក់ឱ្យដំណើរការអនុវត្តបានរួមបញ្ចូលនូវមូលដ្ឋាននៃការគ្រប់គ្រងបែបទំនើបតាមរយៈក្របខណ្ឌថវិការយៈពេលមធ្យម និងការពង្រឹងប្រព័ន្ធគណនេយ្យភាព ។”*



ឯកឧត្តម George Edgar ឯកអគ្គរដ្ឋទូត និងជាប្រធានប្រតិភូសហភាពអឺរ៉ុបប្រចាំកម្ពុជា

*“ការចាប់យកនូវបច្ចេកវិទ្យាថ្មីៗ ទាំងដោយវិស័យឯកជន និងទាំងរាជរដ្ឋាភិបាលនឹងរួមចំណែកយ៉ាងសំខាន់ក្នុងការបង្កើនផលិតភាព និងប្រសិទ្ធភាពសេដ្ឋកិច្ច ជាពិសេសការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ច។ ដូចនេះ សេដ្ឋកិច្ចកម្ពុជាទាំងមូលត្រូវត្រៀមឱ្យបានល្អរួចជាស្រេចដើម្បីប្រឈមមុខទៅទល់នឹងផលប៉ះពាល់នៃបច្ចេកវិទ្យា ទន្ទឹមគ្នានឹងការបង្កើនកាលានុវត្តភាពធុរកិច្ច និងការបង្កើតទីផ្សារថ្មីៗបន្ថែមទៀត ។”*



ឯកឧត្តម **វង្សី វិស្សុត** រដ្ឋលេខាធិការប្រចាំការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានប្រចាំការគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ




*ដកស្រង់ចេញពីសៀវភៅ Toward Next Generation Performance Budgeting*

*“ការរំពឹងទុក និងការគាំទ្រពីស្ថាប័ន សម្រាប់ការអនុវត្តថវិកាសមិទ្ធកម្មគឺមានលក្ខណៈខុសគ្នាទាំងរវាងបណ្តាប្រទេស និងនៅក្នុងប្រទេសហើយប្រព័ន្ធចាំបាច់ត្រូវសមស្រប និងមានភាពប្រាកដនិយមទៅនឹងបរិការណ៍នៃសមត្ថភាពជាក់ស្តែង ។”*

# អគ្គលេខាធិការដ្ឋានគណៈកម្មាធិការ
# ដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

## គណៈគ្រប់គ្រង ៖

| | |
|---|---|
| រស់ សីលវ៉ា | អគ្គលេខាធិការ **អ.គ.ហ.** |
| បណ្ឌិត ហ៊ែល ចំរើន | អគ្គលេខាធិការរង **អ.គ.ហ.** |
| មាស សុខសេនសាន | អគ្គលេខាធិការរង **អ.គ.ហ.** |
| ប៉ែន ធីរុង្គ | អគ្គលេខាធិការរង **អ.គ.ហ.** |
| ប៊ូ វង្សសុខា | អគ្គលេខាធិការរង **អ.គ.ហ.** |
| អ៊ុង លុយណា | អគ្គលេខាធិការរង **អ.គ.ហ.** |
| យ៉េត វីណែល | អគ្គលេខាធិការរង **អ.គ.ហ.** |

## រៀបចំអត្ថបទដោយ ៖

ផ្នែកការងារកែទម្រង់ទាំង៣, គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ

| | |
|---|---|
| លី វ៉ុង | មន្ត្រីជំនាញជាន់ខ្ពស់ |
| វុទ្ធី សត្រា | មន្ត្រីជំនាញ |

ផ្នែកនវានុវត្តន៍ ផ្សព្វផ្សាយ និងកសាងសមត្ថភាព

| | |
|---|---|
| សុគន្ធ ចរិយា | មន្ត្រីជំនាញជាន់ខ្ពស់ |
| ឈុន ម៉ារឌី | មន្ត្រីជំនាញ |
| គង់ ឆោមកែវវរលក្ខណ៍ | មន្ត្រីជំនាញ |
| ស្រុន រដ្ឋា | ជំនួយការ |

ផ្នែកអនុវត្តថវិកា

| | |
|---|---|
| ប៉ុម លៃហេង | មន្ត្រីជំនាញជាន់ខ្ពស់ |
| ហៀង សូយ៉ារ៉ូ | មន្ត្រីជំនាញជាន់ខ្ពស់ |
| លឹម សុខហេង | ជំនួយការ |

ផ្នែកចំណូលសារពើពន្ធ

| | |
|---|---|
| អ៊ុង មករា | មន្ត្រីជំនាញជាន់ខ្ពស់ |
| រស់ ដាលីន | មន្ត្រីជំនាញ |

ផ្នែកគោលនយោបាយ និងរៀបចំថវិកា

| | |
|---|---|
| ម៉េត រ៉ាម៉ន | មន្ត្រីជំនាញ |
| ផេង សុខម៉ៃ | មន្ត្រីជំនាញ |

ផ្នែករដ្ឋបាល ហិរញ្ញវត្ថុ ត្រួតពិនិត្យតាមដាន និងវាយតម្លៃ

| | |
|---|---|
| អ៊ុំ យុទ្ធី | ប្រធានផ្នែករដ្ឋបាល ហិរញ្ញវត្ថុ ត្រួតពិនិត្យតាមដាន និងវាយតម្លៃ |
| អ៊ូច សោភ័ណ | មន្ត្រីត្រួតពិនិត្យតាមដាន និងវាយតម្លៃគម្រោង |
| អ៊ុង វលក្ខទេវី | ជំនួយការមន្ត្រីត្រួតពិនិត្យតាមដាន និងវាយតម្លៃគម្រោង |

ការចូលរួមផ្សេងៗ៖

ក្រុមការងារកែទម្រង់នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

ក្រុមការងារកែទម្រង់នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ

ក្រុមការងារកែទម្រង់នៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

ក្រុមការងារកែទម្រង់នៃអគ្គនាយកដ្ឋានគោលនយោបាយ

ក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

## នវានុវត្ត និងកែសម្រួលដោយ ៖

ផ្នែកនវានុវត្តន៍ ផ្សព្វផ្សាយ និងកសាងសមត្ថភាព

| | |
|---|---|
| សុគន្ធ ចរិយា | មន្ត្រីជំនាញជាន់ខ្ពស់ |
| ឈុន ម៉ារឌី | មន្ត្រីជំនាញ |
| គង់ ឆោមកែវវរលក្ខណ៍ | មន្ត្រីជំនាញ |
| ស្រុន រដ្ឋា | ជំនួយការ |


២០០៥
ជំហានទី
១
ភាពជឿទុកចិត្តនៃថវិកា
វឌ្ឍនភាពសំខាន់ៗគួឱ្យកត់សម្គាល់រួមមាន ចំណូលសារពើពន្ធមានកំណើន១៧,៥% ក្នុងមួយឆ្នាំ និងចំណូលមិនមែនសារពើពន្ធកើនឡើង១៦,៩% ក្នុងមួយឆ្នាំ។ កំណើនចំណូលចរន្តសម្រេចបាន ០,៥ពិន្ទុភាគរយ នៃផសស ការអនុវត្តចំណាយថវិកាសម្រេចបាន ៩៩,០% នៃច្បាប់ថវិកា។
២០០៨
២០០៩
ជំហានទី
២
ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ
វឌ្ឍនភាពសំខាន់ៗគួឱ្យកត់សម្គាល់រួមមាន ចំណូលសារពើពន្ធមានកំណើន១៧,៥% ក្នុងមួយឆ្នាំ និងចំណូលមិនមែនសារពើពន្ធកើនឡើង១៦,៩% ក្នុងមួយឆ្នាំ។ ការដាក់ឱ្យអនុវត្តនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) និងការរៀបចំផែនការយុទ្ធសាស្ត្រស្ដីពីការកសាងនិងអភិវឌ្ឍន៍សមត្ថភាព។
២០១៥
២០១៦
ជំហានទី
៣
ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ
គឺការផ្លាស់ប្តូរពីប្រព័ន្ធគ្រប់គ្រងដែលផ្អែកលើធាតុចូលនិងមជ្ឈការ ឆ្ពោះទៅជាប្រព័ន្ធដែលផ្ដោតលើលទ្ធផល ឬសមិទ្ធកម្ម និងវិមជ្ឈការ តាមរយៈការពង្រឹងនិងពង្រីកការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា ការអនុវត្តថវិកាកម្មវិធី ការអនុវត្តអង្គភាពថវិកា ពង្រឹងការរៀបចំគោលនយោបាយ ការព្យាករណ៍ និងការរៀបចំផែនការហិរញ្ញវត្ថុសាធារណៈ ។
២០២០
២០២១
ជំហានទី
៤
គណនេយ្យភាពសមិទ្ធកម្ម
ដើម្បីសម្រេចបាននូវគណនេយ្យភាពចំពោះសមិទ្ធកម្មដែលជាលទ្ធផលចុងក្រោយនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។
២០២៥

អាសយដ្ឋានទំនាក់ទំនង÷
ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ: (៨៥៥) ៨៥ ៧៧៧ ៩២០
admin@pfm.gov.kh
www.pfm.gov.kh
www.facebook.com/gscpfm